ISSN 1560-7615

# ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា

ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ឆ្នាំទី៩ លេខ ៣ | កក្កដា - កញ្ញា ឆ្នាំ២០០៥ | តម្លៃ ១.៥០០៛

## ការផ្ដល់សេវានៅមូលដ្ឋាន និងក្រុមប្រឹក្សាឃុំ/សង្កាត់

**ហ៊ីង វុទ្ធី និង អាន សុវត្ថា វិភាគលើ សេវា បួន និងបកស្រាយពីស្ថានភាពអំណោយផលល្អរបស់ក្រុមប្រឹក្សាឃុំ/សង្កាត់ ក្នុងការជួយ កែលំអការផ្ដល់សេវានៅកំរិតមូលដ្ឋាន ។***

ការកែលំអជីវភាពនៅជនបទ ជាសកម្មភាពមួយក្នុងចំនោមសកម្មភាពជាអាទិភាពនានានៃយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាលកម្ពុជា ។ តាមគំនិតយល់ឃើញជាទូទៅ ការផ្ដល់សេវាមានប្រសិទ្ធភាពល្អនៅកំរិតមូលដ្ឋាន មានសារៈសំខាន់បំផុតសំរាប់ជោគជ័យនៃសកម្មភាពនេះ ។ ច្បាប់ស្ដីពីការគ្រប់គ្រង និងរដ្ឋបាលឃុំ/សង្កាត់ (LAMC) គ្រោងអោយក្រុមប្រឹក្សាមូលដ្ឋានទទួលតួនាទីនាំមុខគេក្នុងការផ្ដល់សេវា និងធ្វើការអភិវឌ្ឍន៍មូលដ្ឋាន ។ រឿងនេះសំខាន់បំផុតសំរាប់ការកសាងប្រព័ន្ធគណនេយ្យភាពនៅកំរិតមូលដ្ឋាន ពីព្រោះដរាបណាក្រុមប្រឹក្សាឃុំ/សង្កាត់ (CC) បានទទួលភារកិច្ចផ្ដល់សេវាច្បាស់លាស់ (និងធនធានគ្រប់គ្រាន់) ទើបគេអាចចាប់ឱ្យ CC ទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួនបាន ។ ប៉ុន្តែ ច្បាប់មានចែងទូលាយពេកពីសិទ្ធិអំណាចសំរាប់ការទទួលខុសត្រូវដ៏ជាក់លាក់នានា ។ ហេតុនេះ គួរតែយល់ដឹងពីរបៀបផ្ដល់សេវានាបច្ចុប្បន្ន និងរបៀបដែល CC អាចធ្វើអន្តរាគមន៍បាន ដើម្បីកែលំអលំហូរនៃការផ្ដល់សេវា ។



សមាជិកក្រុមប្រឹក្សាឃុំកំពុងធ្វើបញ្ជីអត្រានុកូលដ្ឋាន ។

ដំណើរការផ្ដល់សេវាសាធារណៈនៅមូលដ្ឋានដែលសក្ដិសិទ្ធិ ត្រូវមានពាក់ព័ន្ធនឹងសកម្មភាពមួយចំនួន ដូចជា ការធ្វើផែនការនិងគំរោងថវិកា ហិរញ្ញវត្ថុ, ផលិតកម្ម បទប្បញ្ញត្តិ ការត្រួតពិនិត្យ និងការវាយតំលៃ ។ ការផ្ដល់សេវាសាធារណៈ ត្រូវមានទាំង "អ្នកមានតំរូវការ" និង "អ្នកផ្គត់ផ្គង់" ។ ក្នុងនេះមិនមែនបុគ្គលម្នាក់ៗត្រូវរៀបរាប់ពី "តំរូវការ" របស់ខ្លួនផ្ទាល់នោះទេ ប៉ុន្តែត្រូវមានការរៀបចំបែបណាមួយដើម្បីកំណត់តំរូវការជារួមរបស់អ្នកប្រើប្រាស់ផ្សេងៗជាច្រើននាក់ ។ តួនាទីមួយដែលអាជ្ញាធរមូលដ្ឋានអាចធ្វើបានក្នុងដំណើរការនេះ គឺបូកសរុបពីតំរូវការ ការផ្គត់ផ្គង់សេវាសាធារណៈនៅមូលដ្ឋាន របស់ប្រជាជនរស់នៅក្នុងឃុំ ។ ដោយសារអាជ្ញាធរមូលដ្ឋាននៅជិតស្និទ្ធនឹងប្រជាជន ជាងមន្ត្រីថ្នាក់ខេត្ត រឺថ្នាក់មជ្ឈិម គេរំពឹងថា ថ្នាក់មូលដ្ឋានអាចកំណត់ពីតំរូវការជាក់លាក់នានានៅក្នុងមូលដ្ឋាន បានល្អជាងអង្គការដែលនៅឆ្ងាយៗ ។

ក្នុងអត្ថបទនេះ បានជ្រើសមកពិភាក្សានូវសេវាចំនួនបួន ដែលផ្ដល់នូវមូលដ្ឋានៈ ការថែទាំជួសជុលផ្លូវជនបទ, ការប្រមូលចោលកាកសំណល់រឹង, សេវាថែទាំសុខភាពមបឋម និងការអប់រំ (ដូចជា ការអប់រំក្នុងប្រព័ន្ធ នៅកំរិតបឋម, ការអប់រំក្រៅប្រព័ន្ធ និងការអប់រំកុមារក្នុងវ័យដំបូងៗ) ។ ការស្រាវជ្រាវបង្ហាញថា CC អាចដើរតួយ៉ាងសំខាន់ក្នុងការផ្ដល់សេវាទាំងនេះ ។

* អត្ថបទនេះ ផ្អែកលើរបាយការណ៍សំរេចរបស់ វបសអ បញ្ជូនទៅមូលនិធិអភិវឌ្ឍន៍មូលធននៃអង្គការសហប្រជាជាតិ (UNCDF) ដែលមានចំណងជើងថា ការសិក្សាលើការផ្ដល់សេវានៅមូលដ្ឋាន (ឯកសារជិតចេញផ្សាយរបស់ Eng, Horng, Ann, and Ngo 2005) ។ ចំពោះព័ត៌មានលំអិត សូមអានរបាយការណ៍ពេញលេញ ។

### មាតិកា

ការផ្ដល់សេវានៅមូលដ្ឋាន និងក្រុមប្រឹក្សាឃុំ/សង្កាត់ ....................១
ដំណើរការធ្វើវិមជ្ឈការ .................................... ៥
ទំរង់បុរាណនៃមូលធនសង្គមកិច្ចនៅកម្ពុជា .................... ៩
តាមដានសេដ្ឋកិច្ច — ស្ថានភាពក្រៅប្រទេស .................... ១២
— ស្ថានភាពក្នុងប្រទេស .................... ១៤
— សន្ទស្សន៍សេដ្ឋកិច្ច .................... ១៧
យន្តការបង្ការទំនាស់ក្នុងការបោះឆ្នោតនៅកម្ពុជា (ខប់សែល).......... ១៩
ព័ត៌មានថ្មីៗពី វបសអ .................................... ២០

ការពិភាក្សាដូចតទៅ បង្ហាញពីកត្តា/លក្ខខណ្ឌផ្សេងៗនៃការផ្តល់សេវា ដែលអាចឱ្យ CC បំពេញតួនាទីដ៏មានប្រយោជន៍, ផ្តល់អនុសាសន៍ពីមុខងារផ្តល់សេវានានាដែល CC អាចធ្វើបាន, ព្រមទាំងលើកពីបញ្ហានានាដែលត្រូវដោះស្រាយ ។

## ការផ្តល់សេវានៅមូលដ្ឋាន និងក្រុមប្រឹក្សាឃុំ

ក្នុងផ្នែកនេះ មានការពិភាក្សាពីកត្តា និងលក្ខខណ្ឌផ្សេងៗដែលផ្តល់ "ឱកាសបើកចំហ" សំរាប់អោយ CC ដើរតួដ៏មានប្រយោជន៍ជាអ្នកផ្តល់សេវា ។ សេវាពីរគឺ ការថែទាំជួសជុលផ្លូវជនបទ និងការប្រមូលចោលកាកសំណល់រឹង អាចចាត់ទុកជា "សេវាផ្នែករឹង" ឯសេវាពីរទៀតគឺជា "សេវាផ្នែកទន់" ។ សេវាផ្នែករឹង ជាសេវាដែល CC អាចចុះប្រឡូកដោយផ្ទាល់ដៃក្នុងការផ្តល់វា (ឧទាហរណ៍ ការកសាងផ្លូវជនបទ, ការប្រមូលសំរាម) ។ ចំពោះសេវាផ្នែកទន់ CC មិនចូលពាក់ព័ន្ធដោយផ្ទាល់ក្នុងការផ្តល់វាទេ (ឧទាហរណ៍ ការត្រួតពិនិត្យវត្តមានគ្រូបង្រៀន/ម៉ោងធ្វើការរបស់មណ្ឌលសុខភាព) ។

ចំណុចប្លែកគ្នានេះ គួបផ្សំនឹងកត្តានានា ដូចជា ការរៀបចំសេវា និងបច្ចេកវិទ្យាដែលត្រូវការសំរាប់ការផ្តល់សេវាមានប្រសិទ្ធភាពល្អ ធ្វើអោយយើងអាចវាយតំលៃថាតើសេវាអ្វីខ្លះដែលសមស្របសំរាប់ឱ្យ CC ទទួលគ្រប់គ្រង ។ ដោយសារ CC មានជំនាញទាំងការរៀបចំសេវា និងគ្រប់គ្រងបច្ចេកវិទ្យា ដូច្នេះវាសមស្របនឹងស្នើអោយពួកគេធ្វើជាអ្នកផ្តល់សេវាផ្នែករឹង ។ ប៉ុន្តែចំពោះសេវាផ្នែកទន់ លក្ខណៈបច្ចេកទេសនៃការរៀបចំសេវា និងកំរិតបច្ចេកវិទ្យាត្រូវប្រើប្រាស់ វាខ្ពស់ហួសសមត្ថភាពរបស់ CC ។ ដូច្នេះវាសមរម្យហើយបើសិនរំពឹងថា CC គ្រាន់តែត្រូវចូលពាក់ព័ន្ធនឹងការផ្តល់សេវាផ្នែកទន់នេះ ។

### *ការថែទាំផ្លូវជនបទ*

ការផ្តល់ និងថែទាំជួសជុលផ្លូវជនបទ ជាទំនួលខុសត្រូវរបស់ក្រសួងអភិវឌ្ឍន៍ជនបទ (MRD) ។ គោលនយោបាយជាតិស្តីពីផ្លូវជនបទ (២០០២) បានកំណត់ថា កំរិតឃុំមានសក្តានុពលច្រើនដើម្បីទទួលខុសត្រូវផ្តល់សេវាផ្លូវជនបទ ។ ប៉ុន្តែ មិនទាន់ច្បាស់ទេថា តើមានផ្លូវជនបទប្រភេទអ្វីខ្លះ (ដូចជាផ្លូវក្រាលអ្វី និងមានចរាចរទំហំប៉ុណ្ណា) និងប្រវែងណាហើយ ដែលបានកត់ត្រា និងធ្វើសារពើភណ្ឌរួចរាល់ ។

ផ្លូវជនបទ សំដៅដល់ផ្លូវតភ្ជាប់ពីស្រុកទៅស្រុក ពីស្រុកទៅឃុំ ពីឃុំទៅឃុំ ពីឃុំទៅភូមិ និងពីភូមិទៅភូមិ ។ នៅក្រោមការរៀបចំបច្ចុប្បន្ន មន្ទីរអភិវឌ្ឍន៍ជនបទខេត្ត ទទួលខុសត្រូវចំពោះផ្លូវតភ្ជាប់ស្រុកទៅស្រុក ហើយ CC ទទួលខុសត្រូវចំពោះផ្លូវពីស្រុកទៅឃុំ ពីឃុំទៅឃុំ និងពីឃុំទៅភូមិ ។

#### *កត្តា/លក្ខខណ្ឌ បង្កើនការចូលរួមរបស់ក្រុមប្រឹក្សាឃុំ*

បទពិសោធន៍ និងរបៀបរៀបចំស្ថាប័នសព្វថ្ងៃ បង្ហាញថា ការប្រគល់ការងារថែទាំទៀងពេល និងជាប្រចាំលើផ្លូវតូចៗ ទៅអោយ CC ទទួលខុសត្រូវ អាចជាជំរើសល្អមួយ ដោយមូលហេតុថា:

- ច្បាប់បានគ្រោងប្រគល់ភារកិច្ចទាំងនេះទៅឱ្យ CC ហើយ
- CC ជាច្រើន មានបទពិសោធន៍ធំទូលាយក្នុងការគ្រប់គ្រងការថែទាំផ្លូវដោយទៀងពេល ដោយជួលប្រើអ្នកម៉ៅការ តាមការប្រើប្រាស់មូលនិធិឃុំសង្កាត់ (CSF)
- តាមរយៈជំរើសផ្សេងៗទាក់ទិនការបណ្តុះបណ្តាលអំពី CSF មានការបញ្ជាក់ឡើងរួចហើយពីតំរូវការជាអាទិភាពនៃសេវានេះ
- ការសាងសង់ និងថែទាំផ្លូវជនបទទៅតាមស្តង់ដារជាក់លាក់មួយចំនួន (ឧទាហរណ៍ ក្រាលក្រួសក្រហមកំរាស់ ១៥ស.ម.) គឺ CC អាចស្វែងយល់ គ្រប់គ្រង និងត្រួតពិនិត្យបានជាលក្ខណៈបច្ចេកទេស
- មានការយល់ដឹងយ៉ាងល្អស្រាប់អំពី បន្ទុកចំណាយនៃសេវានេះដែលជាជំហានដ៏ចាំបាច់ដើម្បីធានាថា ភារកិច្ចនេះនឹងទទួលបានមូលនិធិ
- ការអនុវត្តន៍ដោយថ្នាក់ឃុំ ហាក់មានប្រសិទ្ធភាពល្អយ៉ាងហោចណាស់ក៏ស្មើគ្នានឹងរបៀបរបបផ្សេងៗទៀតដែលកំពុងអនុវត្តសព្វថ្ងៃដែរ
- CC អាចប្រើប្រាស់សិទ្ធិរបស់ខ្លួន ដើម្បីដាក់អនុវត្តច្បាប់លើការប្រើប្រាស់ផ្លូវនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

#### *ការពិភាក្សាលើកំហិត*

មុនពេល CC អាចទទួលរ៉ាប់រងភារកិច្ចថែទាំផ្លូវជនបទបាន គេត្រូវដោះស្រាយបញ្ហាមួយចំនួនដូចតទៅ:

- តើរដ្ឋាភិបាលត្រៀមផ្តល់មូលនិធិសំរាប់ការថែទាំជាទៀងពេល និងជាប្រចាំនូវផ្លូវឃុំទេ? ប្រសិនបើបញ្ចូលវាទៅក្នុងមូលនិធិឃុំសង្កាត់ ទឹកប្រាក់ត្រូវផ្ទេរទៅអោយឃុំក្នុងមួយឆ្នាំៗ នឹងកើនឡើងទ្វេមួយជាពីរ ។ ក្រសួងអភិវឌ្ឍន៍ជនបទ នឹងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងត្រូវបង្កើតរូបមន្តថ្នាក់ជាតិដើម្បីបែងចែកមូលនិធិផ្លូវជនបទ ទៅឱ្យឃុំទាំងអស់នៅក្នុងប្រទេស ។
- ប្រសិនបើការបែងចែកត្រូវធ្វើឡើងនៅទូទាំងប្រទេសតាមរូបមន្តផ្អែកលើចំនួនគីឡូម៉ែត្រនៃផ្លូវក្នុងមួយឃុំៗ តើអាចធ្វើការកែសំរួលនៅកំរិតស្រុក និងខេត្តបានដែរឬទេ ដើម្បីធានាថា ឃុំដែលមានផ្លូវឆាប់ខូចខាត (ដោយសារមាន ចរាចរច្រើន រឺទឹកជំនន់) គឺអាចទទួលបានមូលនិធិច្រើនជាង ។
- តើអាចពង្រឹងបែបណានូវការត្រួតពិនិត្យរបស់ CC លើការសាងសង់ផ្លូវ ដើម្បីកុំឱ្យមានការធូររលុងខាងគុណភាព?
- តើអាចរៀបចំឡើងវិញបែបណានូវការពិនិត្យតាមដាន និងការទ្រទ្រង់ពីកំរិតខេត្ត ដើម្បីអោយវាកាន់តែមានប្រសិទ្ធភាព?
- តើមានគំរូល្អៗអ្វីខ្លះ សំរាប់ធ្វើការថែទាំជួលជុលផ្លូវជាប្រចាំ?
- ដើម្បីប្រគល់ទំនួលខុសត្រូវលើផ្លូវជនបទទៅឱ្យ CC ត្រូវមានការធ្វើសារពើភណ្ឌផ្លូវជនបទ ។

### *ការប្រមូលចោលកាកសំណល់រឹង*

ប្រកាសអន្តរក្រសួងរបស់ក្រសួងមហាផ្ទៃ និងក្រសួងបរិស្ថាន ស្តីពីការគ្រប់គ្រងកាកសំណល់រឹងចែងថា អាជ្ញាធរមូលដ្ឋានដោយមានការសហការជាមួយមន្ទីរបរិស្ថាន ត្រូវទទួលបន្ទុកលើការគ្រប់គ្រងកាកសំណល់រឹងនៅក្នុងមូលដ្ឋានរបស់ខ្លួន ។ ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) បានជួយសាលាក្រុងភ្នំពេញ (MPP) ក្នុងការអនុវត្តសាកល្បងគំរោងគ្រប់គ្រងកាកសំណល់រឹង ។ គំរោងទាំងនេះព្យាយាមបញ្ចូលសង្កាត់ មិនសូវរៀបចំក្រុងបានល្អទៅជាយក្រុងភ្នំពេញ ឱ្យចូលពាក់ព័ន្ធក្នុងការគ្រប់គ្រងជាក់ស្តែងលើការប្រមូលចោលកាកសំណល់ ។ គំរោងសាកល្បង ត្រូវគ្រប់គ្រងដោយក្រុមគ្រប់គ្រងកាកសំណល់ភ្នំពេញ (PPWM) ដែលជាអាជ្ញាធរពាក់កណ្តាលស្វយ័តស្ថិតនៅក្រោមសាលាក្រុងភ្នំពេញ (MPP) ។ គំរោងសាកល្បងរៀបចំអោយសង្កាត់ជួយដល់ PPWM ក្នុងការប្រមូលសំរាមពីផ្លូវតូចៗ ដែលឡានសំរាម

មិនអាចចូលបាន ។ ពួកគេក៏ត្រូវប្រមូលថ្លៃសេវា ហើយទទួលបានភាគរយលើប្រាក់កំរៃប្រមូលបាន។

*កត្តា/លក្ខខណ្ឌបង្កើនការចូលរួមរបស់ក្រុមប្រឹក្សាឃុំ*

គំរោងសាកល្បងដែលរៀបចំឱ្យ CC ចូលពាក់ព័ន្ធក្នុងការគ្រប់គ្រងកាកសំណល់រឹង បានបង្ហាញយ៉ាងប្រសើរពីលក្ខខណ្ឌដែល CC អាចមានផលប៉ះពាល់គួរកត់សំគាល់ទៅលើការផ្តល់សេវា ។ លក្ខខណ្ឌទាំងនេះ មានជាអាទិ៍:

- គំរោងសាកល្បងដែលរៀបចំឱ្យ CC គ្រប់គ្រងការប្រមូលចោលកាកសំណល់រឹងនៅក្នុងបួនសង្កាត់នៅជាយក្រុងភ្នំពេញ បានទទួលជោគជ័យល្អ។ អ្នកប្រមូលសំរាមដែលជួលដោយសង្កាត់ បានប្រមូលសំរាមនៅតាមផ្លូវតូចៗយកទៅដាក់នៅកន្លែងចាក់សំរាមធំ និងទទួលប្រាក់ឈ្នួលអំពីកំរៃជាភាគរយដែលសង្កាត់ទទួលបាន ។
- ការផ្លាស់ប្តូរទីលំនៅរបស់ប្រជាជនដែលចូល/ចេញពីមូលដ្ឋានជាហូរហែរ ទាមទារអោយមានអន្តរាគមពី CC ដើម្បីកំណត់ពីចំនួនអតិថិជន ។ CC ជាអាជ្ញាធរដែលអាចផ្តល់តួលេខត្រឹមត្រូវជាងគេពីចំនួនអតិថិជន ជាសក្តានុពលនៃសេវាប្រមូលចោលកាកសំណល់រឹង ។
- ការចូលរួមរបស់ CC ហាក់ដូចចាំបាច់បំផុតក្នុងការប្រមូលសំរាមពីផ្លូវតូចៗដែលឡានសំរាមមិនអាចចូលដល់ ដូចបានពិនិត្យឃើញក្នុងគំរោងសាកល្បងខាងលើ ។

CC អាចដោះស្រាយជំលោះស្តីពីការប្រមូលថ្លៃសេវាបានសក្តិសិទ្ធជាង ។ យោងតាមជោគជ័យទទួលបានក្នុងគំរោងសាកល្បងនេះ មានការផ្តល់មតិយ៉ាងខ្លាំងក្លាឱ្យ CC ទទួលការងារធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះប្រជាជន, ប្រមូលសំរាមពីផ្លូវតូចៗដែលឡានសំរាមមិនអាចចូលដល់, ប្រមូលថ្លៃសេវា, និងដោះស្រាយជំលោះពាក់ព័ន្ធនឹងថ្លៃយកសំរាម ។

នៅតាមតំបន់មានលក្ខណៈជនបទជាងនេះ ដែលកាកសំណល់រឹងភាគច្រើន កើតចេញពីផ្សារតូចៗក្នុងមូលដ្ឋាន មានហេតុផលសំខាន់ៗជាច្រើនដែលគួរអោយ CC ទទួលតួនាទីពិនិត្យតាមដាន ។ តាមរបៀបរបបបច្ចុប្បន្នដែលថ្នាក់ខេត្តទទួលគ្រប់គ្រងលើផ្សារទំហំមធ្យមមិនបានធ្វើអោយផ្សារទាំងនេះមានអនាម័យល្អទេ ។ ដូច្នេះ គួរអនុញ្ញាតអោយ CC ទទួលគ្រប់គ្រងផ្សារនៅមូលដ្ឋាន ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងទទួលភារកិច្ចរក្សាអនាម័យនៅផ្សារទាំងនេះ ។ គេជឿថា CC មានឆន្ទៈ និងផលប្រយោជន៍ច្រើនជាងអាជ្ញាធរខេត្ត ក្នុងការត្រួតពិនិត្យគុណភាពសេវារបស់អ្នកម៉ៅការដែល CC បានចុះកិច្ចសន្យាឱ្យធ្វើការផ្គត់ផ្គង់ ហើយ CC ក៏ចង់ឃើញកន្លែងខ្លួនរស់នៅវាក្លាយជាស្អាត និងមានអនាម័យល្អឡើងដែរ ។

*ការពិភាក្សាពីកំហិត*

ក្រៅពីកត្តាអំណោយផលនានាដូចខាងលើ នៅមានបញ្ហាមួយចំនួនដែលត្រូវកំណត់ និងដោះស្រាយ ។ នៅតំបន់ទីក្រុង រឺជាយទីក្រុង ការរៀបចំដូចខាងលើអាចអនុវត្តបាន ប្រសិនបើ ១)ជាតំបន់មានប្រជាជនរស់នៅច្រើន ហើយតំបន់នៅជិតជុំវិញនោះពុំមានផ្លូវទឹក រឺដីបោះបង់/មិនប្រើប្រាស់ ដែលប្រជាជនអាចយកធ្វើកន្លែងចាក់សំរាមបាន, ២)ឃុំ/សង្កាត់ជាក្រុងទាំងនោះចង់ធ្វើសហប្រតិបត្តិការជាមួយអ្នកម៉ៅការដែលមានការអនុញ្ញាត ដើម្បីសំរបសំរួលសកម្មភាពដ៏ចាំបាច់ផ្សេងៗ និង៣) ការទទួលខុសត្រូវចំបងក្នុងការប្រមូលសំរាម គឺជារបស់អ្នកម៉ៅការ រឺភ្នាក់ងារសាធារណៈពាក់កណ្តាលស្វយ័តដែលមានការអនុញ្ញាតត្រឹមត្រូវ ។ នៅតំបន់ជនបទត្រូវមានការផ្ទេរសិទ្ធិអំណាច (ភាពជាម្ចាស់) គ្រប់គ្រងផ្សារនៅមូលដ្ឋាន ពីថ្នាក់ខេត្តទៅថ្នាក់ឃុំ ។ ម្យ៉ាងទៀត ត្រូវប្រគល់សិទ្ធិអំណាចអោយឃុំ ចុះកិច្ចសន្យាប្រមូលសំរាមជាមួយអ្នកម៉ៅការឯកជនបាន ដើម្បីឃុំអាចចាប់ឱ្យអ្នកម៉ៅការមានការទទួលខុសត្រូវចំពោះមុខខ្លួន ។

*សេវាថែទាំសុខភាពបឋម និងការអប់រំ*

ក្នុងឋានៈជាហត្ថលេខី នៃឯកសារគោលដៅអភិវឌ្ឍន៍សហសវត្សន៍ (MDGs) ប្រទេសកម្ពុជាបានប្តេជ្ញា កែលំអសេវាសាធារណៈរបស់ខ្លួនដូចជា ការអប់រំ និងសុខភាព ហើយការកែលំអនេះនឹងជួយបង្កើនលទ្ធភាពដើម្បី MDGs ភាគច្រើន (គោលដៅ ១-៦) ។ ការប្តេជ្ញានេះ អាចមើលឃើញតាមរយៈគោលនយោបាយនានារបស់រដ្ឋាភិបាល ជាអាទិ៍គោលនយោបាយជាតិស្តីពីការថែទាំសុខភាពបឋម និងការអប់រំសំរាប់ទាំងអស់គ្នា ដែលធានាអោយប្រជាពលរដ្ឋទាំងអស់មានលទ្ធភាពទទួលបានសេវាអប់រំ និងថែទាំសុខភាព (RGC ២000, RGC ២00៣) ។ គោលនយោបាយទាំងនេះ ចាត់ទុកការចូលរួមរបស់សហគមន៍ជាធាតុផ្សំដ៏ចាំបាច់ ដូចអាចមើលឃើញតាមរយៈវត្តមានអង្គភាពមូលដ្ឋាននានា ដូចជាគណៈកម្មាធិការគ្រប់គ្រងមណ្ឌលសុខភាព (HCMC) គណៈកម្មាធិការអប់រំសំរាប់ទាំងអស់គ្នារបស់ឃុំ (EFAC) និងគណៈកម្មាធិការទ្រទ្រង់កំរងសាលារៀន (SSC) ។ គណៈកម្មាធិការនិមួយៗមានការចូលរួមពី CC និង/រឺអ្នកតំណាងពី CC ដែលជាប់ឆ្នោត ។

សេវាសុខភាពបឋមកំរិតមូលដ្ឋាន ដែលត្រូវបានសិក្សានេះ គឺជាសេវាទាំង ១៤ នៃកញ្ចប់សកម្មភាពអប្បរមា (MPA) និងសេវាដទៃទៀត (ដូចជាសកម្មភាពចុះផ្ទាល់ដល់មូលដ្ឋាន) ដែលមានផ្តល់នៅមណ្ឌលសុខភាពសំរាប់ប្រជាជនពី ៨.000 ទៅ ១២.000នាក់ ។ សេវាអប់រំរួមមាន ការអប់រំក្នុងប្រព័ន្ធនៅកំរិតបឋម (ថ្នាក់ទី ១-៦), ការអប់រំក្រៅប្រព័ន្ធ (ថ្នាក់អក្ខរកម្ម) និងការអប់រំកុមារតូចៗ (សាលាមតេយ្យសហគមន៍) ។

*កត្តា/លក្ខខណ្ឌបង្កើនការចូលរួមរបស់ក្រុមប្រឹក្សាឃុំ*

កត្តាចំបងៗដែលញ៉ាំងអោយអាជ្ញាធរមូលដ្ឋាន អាចជួយបានដល់ការផ្តល់សេវាមានជាអាទិ៍ បរិយាកាសគោលនយោបាយ, គំនិតផ្តួចផ្តើមសាកល្បង និងការអនុវត្តន៍ជាក់ស្តែង ។

ទីមួយ ដូចបានរៀបរាប់ខាងលើ គោលនយោបាយនានាទាំងខាងអប់រំ និងសុខាភិបាល បានគ្រោងថា អាជ្ញាធរមូលដ្ឋានគឺមានតួនាទីត្រូវបំពេញទាក់ទិននឹងការផ្តល់សេវាទាំងនោះ ។ ទីពីរ គំនិតផ្តួចផ្តើមសាកល្បង សព្វថ្ងៃរបស់ UNICEF បានផ្តល់សិទ្ធិអំណាចអោយ CC ដើរតួនាទីច្រើនជាងមុនទាំងក្នុងវិស័យអប់រំ និងសុខាភិបាល ។ គំនិតផ្តួចផ្តើមទាំងនេះ រួមមានការទ្រទ្រង់ដល់អង្គភាពទីប្រឹក្សាឃុំនានា ដូចជា គណៈកម្មាធិការឃុំខាងនារី និងកុមារ ព្រមទាំងការកំណត់គ្រួសារក្រីក្រ ដើម្បីមិនបាច់អោយបង់ថ្លៃសេវានៅមណ្ឌលសុខភាព ។ សង្កេតដំបូងៗនូវគំនិតផ្តួចផ្តើមនេះបានបង្ហាញថាការចូលរួមរបស់ CC ក្នុងការផ្តល់សេវា បានជួយកែលំអការផ្គត់ផ្គង់សេវានានា ។ ជាចុងក្រោយ CC ជាច្រើនបានផ្តល់សេវាខាងសង្គមកិច្ចដល់ម្ចាស់ឆ្នោតរួចទៅហើយ ដូចជាការសាងសង់សាលារៀន បង្គន់ និងអណ្តូង ព្រមទាំងសេវាដល់កន្លែងមួយចំនួន (ការចាក់ថ្នាំការពារចល័ត) ដោយប្រើមូលនិធិឃុំ ។

ការសិក្សាបង្ហាញច្បាស់ថា CC អាចបំពេញតួនាទីសំខាន់ៗបន្ថែមទៀតច្រើនណាស់ក្នុងការផ្តល់សេវា ។ គោលគំនិតយ៉ាងសាមញ្ញ និងងាយអនុវត្តមួយគឺអោយ CC ធ្វើការពិនិត្យតាមដាន មិនមែនបច្ចេកទេសដោយទៀង

ពេល និងធ្វើការវាយតំលៃលើការផ្តល់សេវា ដើម្បីបំពេញបន្ថែមដល់ការងារបច្ចេកទេសរបស់ស្ថាប័នអធិការកិច្ចថ្នាក់មជ្ឈឹម ។ ការប្រៀបធៀបលទ្ធផលវាយតំលៃរបស់ឃុំជាច្រើននិងលើកបង្ហាញវាក្នុងវេទិកាខេត្ត ជាវិធានការមួយជួយឱ្យសំលេង CC កាន់តែមានអនុភាពក្នុងការទាមទារគណនេយ្យភាព ។

*ការពិភាក្សាពីកំហិតផ្សេងៗ*

ទោះបីមានកត្តាអំណោយផលជាច្រើនដូច្នេះក្តី ក៏ការផ្តល់សេវាផ្នែកអប់រំ និងថែទាំសុខភាពមិនទាន់ឈានដល់កំរិតគួរពេញចិត្តនៅឡើយទេ ។ កំហិតនានារួមមានការរំពឹងទុករបស់អ្នកប្រើសេវា, សមត្ថភាពរបស់ CC, ការជួយទ្រទ្រង់ដល់ CC, បន្ទុកការងារបច្ចុប្បន្ន និងប្រព័ន្ធអភិបាលកិច្ចទូទៅ ។

*ការរំពឹងទុករបស់អ្នកប្រើសេវា:* ករណីសិក្សាបានបង្ហាញភស្តុតាងថាប្រជាជនមិនចាត់ទុក CC ជាស្ថាប័នគន្លឹះសំរាប់ដោះស្រាយបញ្ហាពាក់ព័ន្ធនឹងការអប់រំ និងសុខាភិបាលនោះទេ ។ ពួកគេមិនជួប CC ដើម្បីប្តឹង រឺក៏វាយការណ៍ពីការមិនពេញចិត្តចំពោះគុណភាពសេវានោះទេ ។ ដូច្នេះគេមានអារម្មណ៍ថា CC មានតួនាទីតិចតួចក្នុងការទាមទារគណនេយ្យភាពពីអ្នកផ្តល់សេវា ដើម្បីទទួលបានសេវាល្អ ។ ប្រសិនបើអ្នកប្រើសេវាមានគំនិតថា CC គឺជាវេទិកាសំរាប់ទាមទារគណនេយ្យភាព គឺមានរឿងពីរ អាចកើតឡើង ។ ទីមួយ មានការដាក់សំពាធដល់ CC អោយធ្វើអ្វីមួយក្នុងបញ្ហាសេវានេះ ។ ទីពីរ អ្នកគ្រប់គ្រងមណ្ឌលសុខភាព រឺសាលាបឋមសិក្សាអាចដឹងខ្លួនពីសំពាធនេះ ហើយចាប់ផ្តើមដោះស្រាយបញ្ហាពីព្រោះសំលេងត្អូញត្អែរពីគុណភាពអន់ កាន់មានរបៀបរៀបចំល្អ និងច្បាស់លាស់ឡើង ទោះជា CC ពុំមានសមត្ថកិច្ចលើសាលាបឋមសិក្សា និងមណ្ឌលសុខភាពក៏ដោយ ។

*សមត្ថភាពនិងការទ្រទ្រង់:* ដូចបានបញ្ជាក់រួចហើយ ច្បាប់បានតំរូវត្រឹមតែឱ្យសមាជិក CC ចេះអាន និងសរសេរ ។ ជាញឹកញាប់ណាស់ចំណេះដឹង និងសមត្ថភាពមិនគ្រប់គ្រាន់ជាបញ្ហាមួយសំរាប់ CC (Rusten *et al.*, 2004) ។ CC ពុំមានចំណេះដឹងគ្រប់គ្រាន់ទេ ដើម្បីទាមទារគណនេយ្យភាពពីអ្នកផ្តល់សេវាខាងអប់រំ និងថែទាំសុខភាព ដោយធ្វើការចូលរួមឱ្យបានជាប់លាប់ និងមានប្រយោជន៍ ក្នុងកិច្ចប្រជុំរបស់គណៈកម្មាធិការគ្រប់គ្រងមណ្ឌលសុខភាព (HCMC) និងគណៈកម្មាធិការទ្រទ្រង់កំរងសាលារៀន (SSC) ។ ម្យ៉ាងទៀត ការទ្រទ្រង់ដែល CC បានទទួលពីក្រុមអ្នកសំរបសំរួលថ្នាក់ខេត្ត និងស្រុក គឺផ្តោតខាងគំរោងហេដ្ឋារចនាសម្ព័ន្ធ ដោយជួយផ្តល់យោបល់ និងការទ្រទ្រង់ភាគច្រើនពាក់ព័ន្ធនឹងសេវាខាងហេដ្ឋារចនាសម្ព័ន្ធ មិនមែនសេវាខាងសង្គមកិច្ចទេ (ibid.) ។

*បន្ទុកការងារ:* តួនាទីកំណត់ដោយច្បាប់បច្ចុប្បន្នរបស់ CC គឺចុះបញ្ជីអត្រានុកូលដ្ឋាន និងបញ្ជីបោះឆ្នោត ។ តួនាទីសំខាន់ និងជាប្រចាំមួយទៀតដែល CC ទទួលបន្ទុក គឺសកម្មភាពអភិវឌ្ឍន៍មូលដ្ឋាន ដែលមានតាំងពីការកំណត់អាទិភាពនៅមូលដ្ឋាន, អនុវត្តអាទិភាពមួយចំនួន (ដោយជួលអ្នកម៉ៅការ និងប្រើមូលនិធិឃុំ), ពិនិត្យតាមដាន និងវាយតំលៃគំរោងនានា (មានការជំនួយពីបុគ្គលិកទ្រទ្រង់បច្ចេកទេសថ្នាក់ខេត្ត) ។ ពិនិត្យតាមចំនួនសមាជិកជាមធ្យម និងបន្ទុកការងាររបស់ CC ដែលមានការទ្រទ្រង់ការងាររដ្ឋបាលតែពីស្មៀនឃុំម្នាក់គត់, គេត្រូវប្រុងប្រយ័ត្នក្នុងការផ្តល់ការងារបន្ថែមដល់ CC ដែលអាចដាក់បន្ទុកធ្ងន់ពេកលើប្រព័ន្ធការងារ ។

*ប្រព័ន្ធអភិបាលកិច្ចទូទៅ:* បច្ចុប្បន្ន មិនទាន់មានអនុវត្តយន្តការអ្វីសំរាប់អោយ CC បញ្ជាក់ការពេញចិត្ត រឺមិនពេញចិត្តរបស់ខ្លួន លើសេវាទាំងពីរប្រភេទទៅកាន់មន្ទីរខេត្តនោះទេ ។ ក្រសួងនានាក៏ពុំមានយន្តការអ្វីសំរាប់បញ្ចូលការវាយតំលៃរបស់អ្នកក្រៅក្រសួង ទៅក្នុងការងារពិនិត្យតាមដាន និងវាយតំលៃរបស់ខ្លួនដែរ ។ បញ្ហានេះបានរាំងស្ទះដល់គណនេយ្យភាពរបស់អ្នកផ្តល់សេវាចំពោះមុខអ្នកប្រើប្រាស់ ។

## សេចក្តីសង្ខេប និងផ្លូវខាងមុខ

យោងតាមការពិភាក្សាខាងលើ គេអាចធ្វើការកត់សំគាល់ពីរបែប ។ ទីមួយ *ការរៀបចំ* សេវាផ្នែករឹង ដែលមានការថែទាំផ្លូវជនបទ និងការប្រមូលចោលកាកសំណល់រឹង និង *បច្ចេកវិទ្យា* សំរាប់ផ្តល់សេវាទាំងនេះ គឺវាសាមញ្ញគួរសម (មិនបច្ចេកទេសខ្លាំងពេក) សំរាប់ឱ្យ CC គ្រប់គ្រងបាន ហេតុនេះ CC អាចដើរតួនាទីដ៏មានប្រយោជន៍ និងធ្វើផ្ទាល់ដៃជាងមុនក្នុងការផ្គត់ផ្គង់វា ។ គឺបានន័យថា សមត្ថភាពបច្ចេកទេសបច្ចុប្បន្នរបស់ CC វាសមស្របនឹងកំរិតជំនាញដែលត្រូវមាន សំរាប់គ្រប់គ្រងការផ្តល់សេវាទាំងពីរនេះ ។ ភាពស៊ីគ្នាល្អរវាងសមត្ថភាពដែល CC មានសព្វថ្ងៃ ហើយនិងកំរិតជំនាញដែលត្រូវមាន វាសំខាន់បំផុតដើម្បីឱ្យការផ្តល់សេវាបានជោគជ័យ ហើយវាកំណត់ថា តើមានសេវាអ្វីខ្លះដែល CC អាចទទួលយក និងដោះស្រាយបានដោយជោគជ័យ ។

ការកត់សំគាល់ទីពីរ ពាក់ព័ន្ធនឹងការផ្តល់សេវាផ្នែកទន់ ខាងថែទាំសុខភាព និងការអប់រំកំរិតបឋម ។ លក្ខណៈបច្ចេកទេសខ្ពស់នៃសេវាផ្នែកទន់ទាំងនេះ រារាំង CC មិនអោយដើរតួនាទីផ្គត់ផ្គង់ដោយផ្ទាល់បាន ។ ប៉ុន្តែយោងតាមសមត្ថភាពសព្វថ្ងៃរបស់ខ្លួន CC ក៏នៅតែអាចដើរតួជួយគាំទ្រក៏មានប្រយោជន៍ ដូចជា កេណ្ឌប្រមូលកុមារឱ្យមកទទួលថ្នាំការពារ និងចុះឈ្មោះកុមារឱ្យចូលសាលារៀន ព្រមទាំងជួយធ្វើយុទ្ធនាការបង្កើនការយល់ដឹង (ពីអនាម័យ, សុខភាពបន្តពូជ និងជំងឺអេដស៍) ។

ការកត់សំគាល់ទាំងពីរនេះបង្ហាញថា មុនពេលកំណត់អោយ CC ទទួលភារកិច្ចផ្តល់សេវាអ្វីមួយ និងចាប់ឱ្យ CC មានការទទួលខុសត្រូវគេចាំបាច់ត្រូវពិនិត្យពីលក្ខណៈនៃសេវានោះ (ផ្នែករឹង រឺផ្នែកទន់) ព្រមទាំងការរៀបចំ និងបច្ចេកវិទ្យាដែលត្រូវមានសំរាប់ផ្តល់វា ។

## កំណត់សំគាល់

១. ដោយសារនេះជាអត្ថបទមួយខ្លី ដូច្នេះក្នុងចំណោម ៧វិស័យដែលបានសិក្សាបានលើកយកតែ ៤វិស័យប៉ុណ្ណោះមកពិភាក្សាក្នុងពេលនេះ ។

២. សំរាប់ព័ត៌មានលំអិតស្តីពីគោលនយោបាយ និងបទប្បញ្ញត្តិទាក់ទិននឹងការផ្តល់សេវាតាមវិស័យ សូមអានរបាយការណ៍ចុងក្រោយអំពី "ការសិក្សាពីការផ្តល់សេវានៅមូលដ្ឋាន" (ឯកសារជិតចេញផ្សាយរបស់ Eng, Horng, Ann, and Ngo 2005) ។

៣. សូមអានរបាយការណ៍ពេញលេញអំពីការផ្តល់សេវានៅមូលដ្ឋាន (ជិតចេញផ្សាយ ២០០៥) សំរាប់ព័ត៌មានលំអិតទាក់ទិននឹងគំរោងសាកល្បង

៤. មានផ្សារធំៗដែលអាចទាក់ទាញអ្នកទិញ និងអ្នកលក់ចំនួនច្រើន ហើយបំរើអោយឃុំ/សង្កាត់ច្រើន (MEF ២០០៥)

៥. ផ្សារមូលដ្ឋាន ជាផ្សារតូច លក់ផលិតផលតិច ហើយទាក់ទាញអ្នកលក់នៅក្នុងមូលដ្ឋាន (ibid.)

៦. មិនមែនបច្ចេកទេសមានន័យថា ក្រុមប្រឹក្សាឃុំនឹងប្រើទំរង់សាមញ្ញដូចជាគ្រាន់តែគូសសញ្ញាប្រាប់ថា "មែន" រឺ "ទេ" ជាដើម ។ ភាពសាមញ្ញនេះ វាសំខាន់ណាស់ ពីព្រោះក្រុមប្រឹក្សាអាចធ្វើបានយ៉ាងលឿន ។

*សូមអានឯកសារយោងនៅក្នុងអត្ថបទជាអង់គ្លេស*

# ដំណើរការធ្វើវិមជ្ឈការៈ តើសង្គមស៊ីវិលអាចជួយជំរុញដំណើរការបង្កើនគណនេយ្យភាពរបស់អាជ្ញាធរមូលដ្ឋាននៅកម្ពុជាដែរឬទេ?

**ដោយ គីម សេតារា និង អាន សុវត្ថា ពិនិត្យទៅលើតួនាទីនៃក្រុមជាប្រពៃណី, គណៈកម្មការទ្រទ្រង់សាលារៀន (SSC) និងក្រុមទទួលបានសិទ្ធិអំណាចសហគមន៍នេសាទ (FC) ក្នុងការបង្កើនគណនេយ្យភាពរវាងសមាជិកក្រុមប្រឹក្សាឃុំដែលជាប់ឆ្នោតទៅដល់ប្រជាជនម្ចាស់ឆ្នោត ។***

សង្គមកម្ពុជាក្រោយពេលបញ្ចប់ទំនាស់ ទើបចាប់អនុវត្តក្នុងពេលថ្មីៗនូវដំណាក់កាលនានាដើម្បីកសាង របបប្រជាធិបតេយ្យឱ្យបានពេញលេញ ។ ឆ្លងតាមការបោះឆ្នោតឃុំ-សង្កាត់លើកទី១នៅឆ្នាំ២០០២ ប្រទេសកម្ពុជាបានចាប់ផ្តើមកំណែទំរង់វិមជ្ឈការសំដៅជំរុញការកសាងរបបប្រជាធិបតេយ្យ ព្រមទាំងវប្បធម៌នៃការចូលរួម និងទំនុកចិត្តរវាងរដ្ឋ និងសង្គម ។ នៅតាមមូលដ្ឋាន វត្តមានសង្គមស៊ីវិល និងសមាគមនានា មានសារៈសំខាន់ណាស់ ដើម្បីជួយទ្រទ្រង់ និងពង្រឹងក្រុមប្រឹក្សាឃុំ (CC) (Mansfield and Macleod, Rusten *et al* 2004, Ojendal 2005, Blunt and Turner 2005, Hughes 2005) ។ កត្តាគន្លឹះមួយដែលបង្កជោគជ័យរឺបរាជ័យនៃកំណែទំរង់វិមជ្ឈការ វាជាប់ទាក់ទិននឹងកំរិតចូលរួមជាដៃគូ និងកិច្ចសហការរវាងសង្គមស៊ីវិល និងអាជ្ញាធរមូលដ្ឋាន ។ វិមជ្ឈការនៅកម្ពុជាប្រឈមមុខនឹងឧបសគ្គមួយចំនួន ដូចជា កង្វះអន្តរកម្មរវាងក្រុមសង្គមស៊ីវិល និង CC, កង្វះការផ្ទេរធនធាន និងអំណាចពីរដ្ឋាភិបាលមជ្ឈឹម (Ninh and Henke 2005, CCC Special Research Report 2004, Rusten et al 2004, Hughes 2005) ។ កត្តាទាំងនេះ បានរារាំង CC មិនឱ្យមានគណនេយ្យភាព (ការទទួលខុសត្រូវ) និងការឆ្លើយតបបានពេញលេញ ចំពោះតំរូវការនានារបស់ប្រជាជនម្ចាស់ឆ្នោត ។

សំនួរសំខាន់មួយទាក់ទិននឹង *កំរិតដែលអង្គការសង្គមស៊ីវិលសព្វថ្ងៃអាចជួយបង្កើនគណនេយ្យភាពរបស់អាជ្ញាធរមូលដ្ឋាន ចំពោះប្រជាជនម្ចាស់ឆ្នោត* ។ ថ្វីបើមានសមាគមជាច្រើននៅតាមមូលដ្ឋានក្នុងជនបទកម្ពុជាក្តី ប៉ុន្តែអត្ថបទនេះ នឹងពិនិត្យតែគណៈកម្មការពីរប៉ុណ្ណោះដែលបានកើតឡើងតាមអនុក្រឹត្យ និងប្រកាសរបស់រដ្ឋាភិបាល ។ ចំណុចស្នូលនៃការវិភាគ គឺប្រៀបធៀបក្រុមពីរនៅមូលដ្ឋាន ដើម្បីស្វែងយល់ពីគោលគំនិតនៃការចូលរួម និងចីរភាព ។ គណៈកម្មការទ្រទ្រង់សាលារៀន (SSC) គឺជា "ក្រុមជាប្រពៃណី" មួយដែលតែងឃើញមានក្នុងជនបទកម្ពុជាភាគច្រើន ។ សហគមន៍នេសាទ (FC) គឺជា "ក្រុមទទួលបានសិទ្ធិអំណាចពីរដ្ឋ" ដែលមានតែក្នុងតំបន់មានកន្លែងនេសាទ ។ គណៈកម្មការទាំងពីរ មានលក្ខណៈខុសប្លែកពីគ្នា ។ SSC មានចីរភាពល្អណាស់ មានការចូលរួមច្រើនពីមាតាបិតាសិស្ស និងគ្រូបង្រៀន ពីព្រោះសមាជិកទាំងអស់ និងមាតាបិតា មានការប្តេជ្ញាចិត្តខ្ពស់ ។ ប៉ុន្តែសហគមន៍នេសាទ (FC) មានកំលាំងខ្សោយ ពីព្រោះមានប្រជាជនចូលរួមតិច, សមាជិកពុំមានសិទ្ធិអំណាចសំរេចអាជ្ញាកាត់គ្រប់គ្រាន់ និងខ្វះខាតជំនួយទ្រទ្រង់បច្ចេកទេសពីក្រសួងជំនាញ ។ ចំណុចទាំងអស់នេះបង្ហាញពីបញ្ហាចោទខាងចីរភាព និងការរក្សាទំនុកចិត្តពីសំណាក់ប្រជាជនម្ចាស់ឆ្នោត ។

## ក្រុម/គណៈកម្មការនៅមូលដ្ឋានដែលមានស្រាប់

នៅតាមសហគមន៍នានាក្នុងជនបទកម្ពុជា គេឃើញមានក្រុមសង្គមស៊ីវិល

---

* អត្ថបទនេះស្រង់ចេញពីការសិក្សាស្តីពីកម្មវិធីអភិបាលកិច្ច និងវិមជ្ឈការរបស់ វិបសអ ។ ការសិក្សានេះផ្តល់ថវិកាដោយទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិស៊ុយអែត (SIDA) និងនាយកដ្ឋានសំរាប់ការអភិវឌ្ឍន៍អន្តរជាតិ (DIFID), ហើយលោក គីម សេតារា និង Joakim Ojendal នឹងសរសេររបាយការណ៍ពេញលេញដើម្បីបោះពុម្ពផ្សាយជាឯកសារពិភាក្សារបស់ វិបសអ ។ សំរាប់ការសិក្សានេះ បានចុះធ្វើអង្កេតដល់កន្លែងក្នុង ៤ឃុំ នៅ ៤ខេត្ត ចាប់ពីខែតុលា-វិច្ឆិកា ២០០៤ ដោយបានធ្វើសំភាសន៍ជាមួយ សមាជិកក្រុមប្រឹក្សាឃុំ មន្ត្រីរាជការ សមាជិកគណៈកម្មការនៅមូលដ្ឋាន និងអ្នកភូមិជាច្រើន ។

| ក្រុមជាប្រពៃណី | ក្រុមទទួលបានសិទ្ធិអំណាច |
|---|---|
| គណៈកម្មការវត្តដែលតាមធម្មតាតំណាងឱ្យច្រើនភូមិ រួមមាន អ្នកស្ម័គ្រចិត្តជាចាស់ទុំមានគេគោរពច្រើន និងអ្នកឯទៀតដែលជួយធ្វើការ និងតំណាងឱ្យវត្ត ។ តាមធម្មតា គ្មានការបោះឆ្នោតទេ ។ | សមាគមអ្នកប្រើប្រាស់ទឹក ដែលបង្កើតឡើងសំរាប់ចាត់ចែងបែងចែក ទឹកក្នុង ចំណោមកសិករ និងកសាង/ថែទាំប្រព័ន្ធស្រោចស្រពក្នុងសហគមន៍ ។ |
| *គណៈកម្មការទ្រទ្រង់សាលា* (SSC) តាមធម្មតារួមមាន អ្នកមានគេគោរពច្រើន គ្រូបង្រៀន នាយកសាលា តំណាងអាជ្ញាធរមូលដ្ឋាន និងមាតាបិតាសិស្ស ។ ភារកិច្ច ចំបងគឺ ថែរក្សា និងធានាឱ្យសាលារៀនមានដំណើរការទៅមុខ ។ | *សហគមន៍ព្រៃឈើ* ត្រូវបានបង្កើតឡើងសំរាប់ថែរក្សាព្រៃឈើ ការពារព្រៃឈើទប់ទល់នឹងការកាប់ឈើខុសច្បាប់ និងដាំដើមឈើឡើងវិញ ។ គណៈកម្មការនេះទទួលជំនួយបច្ចេកទេសភាគច្រើនពី NGOs អន្តរជាតិ ប៉ុន្តែមិនមែនជាចំណែកមួយនៃដែនសមត្ថកិច្ចឃុំទេ ។ |
| *ក្រុមភ្លេងប្រពៃណី:* តាមធម្មតាគឺជាចំណែកមួយនៃគណៈកម្មការវត្ត ដែលជួយបង្រៀនភ្លេងប្រពៃណីដល់ពួកក្មេងៗ ជួយគ្រួសារក្រីក្រ និងសហគមន៍ពេលមានបុណ្យសព និងបុណ្យទាន/ពិធីផ្សេងៗ ។ | សហគមន៍នេសាទ ស្ថិតនៅជិត រឺក្នុងតំបន់នេសាទ, ជាក្រុមសំរាប់ឃ្លាំ មើលដែលកើត ចេញពីចំណាត់ការរបស់រដ្ឋាភិបាលនៅឆ្នាំ២០០១ ដែលបានប្រគល់ឡូត៍នេសាទឯកជន ៥២% ទៅឱ្យសហគមន៍នានា ។ គណៈកម្មការនេះមានភារកិច្ចចំបង ការពារតំបន់នេសាទទប់ទល់នឹងការនេសាទខុសច្បាប់ និងធ្វើសហការជាមួយការិយាល័យនេសាទ និងអាជ្ញាធរមូលដ្ឋាន ។ ជារឿយៗគណៈកម្មការបានទទួលជំនួយបច្ចេកទេសពី NGOs អន្តរជាតិ ។ |
| *គណៈកម្មការបុណ្យសព:* មិនមែនជាក្រុមអចិន្ត្រៃយ៍ទេ និងសំរាប់ជួយគ្រួសារក្រីក្រដែលខ្វះលទ្ធភាពរៀបចំបុណ្យសពឱ្យបានសមរម្យ ។ | *សមាគមនារី* មានគោលដៅលើកទឹកចិត្តនារីឱ្យចូលរួមក្នុងការងារអភិវឌ្ឍន៍សហគមន៍ និងបង្កើនការយល់ដឹងរបស់នារីពីបញ្ហាយេនឌ័រ ។ តាមធម្មតា សមាគមនេះកកើតឡើងដោយមានជំនួយហិរញ្ញវត្ថុ និងបច្ចេកទេសពី NGOs ។ |

កំរិតមូលដ្ឋានជាច្រើន ដែលអាចបែងចែកជា ២ប្រភេទធំៗ: ១) ក្រុមជាប្រពៃណីសំដៅដល់សមាគម/គណៈកម្មការនានាដែលមានជាយូរមក ហើយនៅក្នុងសហគមន៍ និងដែលប្រជាជនក្នុងមូលដ្ឋានបានផ្ដួចផ្ដើមធ្វើជាសមូហភាព ។ ស្ថាប័ននេះឃើញមានក្នុងគ្រប់ឃុំ (គណៈកម្មការវត្ត និងគណៈកម្មការទ្រទ្រង់សាលា) និង ២) ក្រុមទទួលបានសិទ្ធិអំណាច សំដៅដល់សមាគម រឺអង្គការនានាដែលត្រូវបានបង្កើតឡើងដោយ NGOs អន្តរជាតិ រឺបទប្បញ្ញត្តិច្បាប់របស់រដ្ឋ ។ ក្រុមប្រភេទនេះ ឃើញមានក្នុងឃុំជាក់លាក់មួយចំនួនដែលមានស្ថានភាពភូមិសាស្ត្រសមស្រប (ឧទាហរណ៍ សហគមន៍ព្រៃឈើ និងសហគមន៍នេសាទ) (Kim 2004) ។ តារាងនៅទំព័រ ៥ មានបង្ហាញពីក្រុមទាំងពីរប្រភេទនេះ ។

ក្រៅពីក្រុមនានាខាងលើនេះ នៅមានសមាគមក្នុងមូលដ្ឋានជាច្រើនប្រភេទទៀត ដូចជា សមាគមសន្សំប្រាក់ សមាគមធ្នូប សមាគមយុវជនក្រុមភ្លេងប្រពៃណី សមាគមជួយចាស់ជរា សមាគមដាំដុះស្រូវប្រាំងជាដើម ។ រីឯគណៈកម្មាធិការផែនការនិងថវិកា (PBC) និងគណៈកម្មាធិការថែទាំ និងលទ្ធកម្ម (PC), មិនស្ថិតក្នុងបញ្ជីខាងលើទេ ពីព្រោះត្រូវបានបង្កើតឡើងតាមការកំណត់ក្នុងច្បាប់ឃុំ/សង្កាត់ ។

**គណៈកម្មការទ្រទ្រង់សាលា** (SSC)

ថ្វីបើ SSC មិនទាន់មានចំណាស់ដូច គណៈកម្មការវត្តក្ដី ប៉ុន្តែក៏ដំណើរការបានច្រើនឆ្នាំហើយនៅតាមមូលដ្ឋាន ។ តាមធម្មតាគណៈកម្មការរួមមាន ចាស់ទុំដែលមានគេគោរពច្រើន គ្រូបង្រៀន ប្រធានភូមិ សមាជិក គណៈកម្មការអភិវឌ្ឍន៍ សមាជិកCC និងឪពុកម្ដាយសិស្ស (Kim 2004) ។ អ្នកភូមិបោះឆ្នោតជ្រើសរើសប្រធាន និងសមាជិក SSC ។ SSC និមួយៗមានសមាជិកអចិន្ត្រៃយ៍ ៨-១៥នាក់ ដោយភូមិនិមួយៗច្រើនមានតំណាង ២-៣នាក់ក្នុងនេះ ។ សមាជិកធម្មតាគឺជាមាតាបិតាដែលមានកូនរៀនក្នុងសាលា ។ ការជ្រើសរើសគឺផ្អែកលើការមូលមតិរបស់អ្នកភូមិ ។ តាមធម្មតា ប្រធានភូមិ និងសមាជិក CC រកមើលបេក្ខជនដោយផ្ទាល់ ហើយសួរចិត្តគាត់តើព្រមចូលក្នុង SSC រឺទេ ។ ម្នាក់ៗត្រូវបំពេញលក្ខខណ្ឌមួយចំនួន ដូចជា មានការអប់រំ មានប្រជាប្រិយភាព និងទទួលការគោរពរាប់អានពីអ្នកភូមិភាគច្រើន ។ គេចង់បានអ្នកមានប្រជាប្រិយភាព ពីព្រោះសមាជិក SSC នឹងត្រូវជួយរៃអង្គាសប្រាក់ ។ កាលពីមុន និងក្នុងពេលសព្វថ្ងៃផងដែរ សាលាបឋមសិក្សាភាគច្រើនស្ថិតក្នុងបរិវេណវត្ត ។ ជារឿយៗប្រជាជននៅមូលដ្ឋាន មិនយល់ពី SSC និងសមាគមមាតាបិតាសិស្ស (PA) ទេ ។ គួរកត់សំគាល់ថាមានករណីតិចតួចខ្លះដែរ ដែល PA គឺដាច់ដោយឡែកពី SSC ។

*កំលាំងនៃSSC*

មានកត្តាមួយចំនួនដែលជួយឱ្យ SSC មានជោគជ័យ ។ ទីមួយ ជាប្រពៃណី SSC តែងផ្សារភ្ជាប់ខ្លួនក្នុងសហគមន៍មូលដ្ឋាន ដូច្នេះមានទំនាក់ទំនងល្អជាមួយអាជ្ញាធរឃុំ នឹងមាតាបិតា ហើយមិនសូវជួបបញ្ហាទេក្នុងការរៃអង្គាសប្រាក់។ ម្យ៉ាងទៀត ដោយសារទំនាក់ទំនងល្អនេះ ការផ្ដល់ព័ត៌មានចុះឡើងជាមួយ SSC អាចធ្វើឡើងយ៉ាងទៀងទាត់ក្នុងរូបភាពជាការប្រជុំដែលក្នុងនេះគេអាចសុំមតិយោបល់របស់សហគមន៍ ។ CC ចង់ឃើញ SSC ធ្វើការជួយសហគមន៍បានសក្ដិសិទ្ធិ ហើយ CC និង SSC អាចកសាងទំនុកចិត្តជាមួយគ្នាបាន ។ ទីពីរ ពុំមានស្ថាប័នអ្វីមករាំងស្ទះប្រតិបត្តិការ SSC ទេ ។ ក្រសួងជំនាញ បានជួយទ្រទ្រង់ដល់ SSC ក៏ពិតមែន ប៉ុន្តែមិនលូកដៃក្នុងការសំរេចផ្សេងៗរបស់ SSC ទេ គឺបានន័យថា គ្មានការប្រើអំណាចរំលោភឡើយ ។ ទីបី ក្នុងគោលគំនិតជួយទ្រទ្រង់ និងលើកកំពស់ការអប់រំ ដែលផ្ដល់អត្ថប្រយោជន៍ដល់សហគមន៍ទាំងមូល SSC បានទទួលជោគជ័យក្នុងការទាក់ទាញឱ្យប្រជាជនចូលរួម និងប្ដេជ្ញាចិត្តជួយជ្រោមជ្រែង ។ នេះជាកត្តាសំខាន់មួយ ជួយឱ្យ SSC មានចីរភាព ។

*បញ្ហាប្រឈមរបស់ SSC*

ថ្វីបើ SSC អនុវត្តតួនាទីរបស់ខ្លួនបានជោគជ័យក្ដី ក៏នៅមានបញ្ហាប្រឈមមួយចំនួន ។ ទីមួយ SSC ជាក្រុមអ្នកស្ម័គ្រចិត្ត ដូច្នេះវាពិបាកនឹងរក្សាអោយសមាជិកនានាមានការប្ដេជ្ញាចិត្តយូរអង្វែង និងស្មោះត្រង់ ។ ដោយសារជីវភាពរស់នៅមានកំរិតទាប សមាជិកមិនអាចធ្វើការយ៉ាងទៀងទាត់បានទាំងអស់គ្នាទេ ។ មានតែប្រធាន និងអនុប្រធានប៉ុណ្ណោះដែលសកម្ម និងដឹងរឿងច្រើន ។ ទីពីរ មូលធនខាងសង្គមកិច្ចទន់ខ្សោយ ដូចជា ការកសាងបណ្ដាញទំនុកចិត្ត ចំណងទាក់ទងខាងស្ថាប័ននៅជនបទជាដើម បានបង្កឧបសគ្គជាច្រើនដល់ SSC ។ ជាការកំណាស់ដែល SSC អាចកសាងទំនាក់ទំនងជាមួយគណៈកម្មការឯទៀតៗនៅក្នុងឃុំជាមួយគ្នា រឺនៅឃុំផ្សេង (មូលធនខាងសង្គមកិច្ច រឺអន្តរកម្មរវាងគណៈកម្មការនៅខ្សោយ) ។ ទំនាក់ទំនងជាមួយអង្គការ កើតមានតែជាមួយ NGOs ។ ទីបី លំហូរព័ត៌មានមិនគ្រប់គ្រាន់ រឺគ្មានសោះ រវាងសាលារៀន, SSC, និងអាជ្ញាធរ គឺជាការបារម្ភមួយ ។ ដោយសារកង្វះការផ្ដល់ព័ត៌មានចុះឡើងនេះ ជារឿយៗ SSC និងសាលារៀន មិនបានដឹងច្បាស់ពីគោលនយោបាយរបស់រដ្ឋាភិបាលទេ ។ កង្វះការចែករំលែកព័ត៌មានរវាង SSC និងសាលារៀន ក៏បង្កការយល់ខុសម្ដងម្កាលដែរ ។ ដូច្នេះ SSC មានចំណុចខ្លាំងមួយចំនួនក៏ពិតមែន ប៉ុន្តែនៅប្រឈមនឹងបញ្ហាខ្លះទៀត ដូចជា កង្វះគ្រឿងលើកទឹកចិត្តខាងហិរញ្ញវត្ថុ អវត្តមានកិច្ចសហការអន្តរ-ក្រុម និងការចែករំលែកព័ត៌មានមិនគ្រប់គ្រាន់ ។

*អន្តរកម្មរវាងអង្គការ*

អន្តរកម្មរវាងអង្គការ គឺជាកត្តាគន្លឹះនៃជោគជ័យរបស់ក្រុមសង្គមស៊ីវិលកំរិតមូលដ្ឋាននានា ហើយគួរមានធ្វើឡើងរវាងក្រុមនានានៅមូលដ្ឋាន និងរវាងក្រុមនៅមូលដ្ឋាន និងអាជ្ញាធរ (CC) ។ ធ្វើដូច្នេះ SSC អាចមានជោគជ័យពីព្រោះមានទំនាក់ទំនងល្អជាមួយ CC ។ អន្តរកម្មមិនគ្រប់គ្រាន់រវាង CC និងអង្គការនៅមូលដ្ឋាន គឺជាសញ្ញានៃកង្វះមូលធនសង្គមកិច្ចក្នុងសង្គមជនបទនៅកម្ពុជា ។ អង្គការនៅមូលដ្ឋាននានា ពុំមានឆន្ទៈធ្វើការជាមួយគ្នានៅក្នុងក្របខ័ណ្ឌចំណងទាក់ទងខាងស្ថាប័ននោះទេ ហើយចំពោះ SSC ក៏ដូច្នេះដែរ ។ មនុស្សជាប់ពាក់ព័ន្ធនឹង SSC គ្រប់គ្នាដែលយើងជួបបាននិយាយថា ខ្លួនមិនចង់ធ្វើការជាមួយ រឺចង់ដឹងពីសកម្មភាពរបស់អង្គការឯទៀតៗទេ ថ្វីបើឃុំនីមួយៗមានអង្គការ និងសមាគមប្រហាក់ប្រហែលគ្នា ។ មូលហេតុនៃកង្វះអន្តរកម្មបែបនេះ គឺការមិនចង់ឱ្យមានការចោទប្រកាន់ពីរឿងលូកដៃចូលក្នុងការងាររបស់អង្គការឯទៀត ។ ទំនាក់ទំនងគឺមានតែជាមួយ NGO រឺអាជ្ញាធរជាប់ទាក់ទិនដែលធ្វើការជាដៃគូជាមួយ SSC ដូចជា ការិយាល័យអប់រំស្រុក និង CC ជាដើម ។ កង្វះអន្តរកម្មរវាងសហគមន៍ អាចមកពីកង្វះទំនុកចិត្តលើខ្លួនឯង, វប្បធម៌ស្ដាប់តាមការគ្រប់គ្រងផ្ដាច់ការ, និងបំណងមិនចង់លូកដៃក្នុងកិច្ចការរបស់គេ ។

សរុបមក ជោគជ័យរបស់ SSC ពឹងផ្អែកលើការចូលរួមរបស់ប្រជាជន, ការចែករំលែកព័ត៌មានក្នុងក្រុម, ការទទួលបានជំនួយបច្ចេកទេសពីក្រសួង

ជំនាញ, ការកសាងទំនាក់ទំនងល្អជាមួយ CC ។ ប៉ុន្ដែជោគជ័យនេះ មិនអាចរួមចំណែកបានពេញលេញដល់ការអភិវឌ្ឍន៍មានចីរភាពរយៈពេលវែងនោះទេ ដោយសារបញ្ហាមួយចំនួន ដូចជា ការចែករំលែកព័ត៌មានរវាងតួអង្គជាប់ទាក់ទិននានា និងកិច្ចសហការខ្សោយខាងស្ថាប័នក្នុងការជួយឱ្យសហគមន៍អភិវឌ្ឍន៍ឡើង ។

**សហគមន៍នេសាទ** (FC)

អនុក្រឹត្យរបស់រាជរដ្ឋាភិបាលកម្ពុជា (RGC, 27/5/2003) បានចែងថា សហគមន៍នេសាទត្រូវបានបង្កើតឡើងដោយមានការទ្រទ្រង់បច្ចេកទេស និងរដ្ឋបាលពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF) ព្រមទាំងគំនិតផ្ដួចផ្ដើមក្នុងមូលដ្ឋាន ។ FC ភាគច្រើន ត្រូវបានបង្កើតដោយមានកិច្ចសហការជាមួយ NGO អន្ដរជាតិ ដោយទទួលបានការទ្រទ្រង់បច្ចេកទេសពីក្រសួងជំនាញ និងការគាំទ្រយ៉ាងជិតដល់ពីអាជ្ញាធរមូលដ្ឋាន ។ FC ភាគច្រើន បានបង្កើតឡើងក្នុងឆ្នាំ២០០១-២០០២ ប៉ុន្ដែមានខ្លះទើបចាប់ផ្ដើមធ្វើនៅឆ្នាំ២០០៤ ។

មានតែភូមិនៅជាប់នឹងតំបន់នេសាទប៉ុណ្ណោះដែលស្ថិតក្នុង FC ។ តាមធម្មតា គ្រួសារទាំងអស់ក្នុងភូមិទាំងនេះមានសិទ្ធិធ្វើជាសមាជិក FC ។ ទំហំគណៈកម្មការ FC គឺផ្អែកតាមចំនួនគ្រួសារ ហើយចំនួនសមាជិកមធ្យមមានពី៥-១៤នាក់ ។ សមាជិកទាំងអស់ជាអ្នកស្ម័គ្រចិត្ត នឹងត្រូវបានបោះឆ្នោតជ្រើសរើសចេញពីភូមិនីមួយៗដោយសមាជិកឯទៀតៗ ។ នៅពេលបោះឆ្នោតជ្រើសរើសបានហើយ សមាជិកគណៈកម្មការត្រូវជ្រើសរើសប្រធាន អនុប្រធាននានា ហិរញ្ញិកម្នាក់ និងលេខាធិការម្នាក់ ។ តាមធម្មតា ប្រធាន និងអនុប្រធានតែងត្រូវបានអញ្ជើញឱ្យទៅទទួលការបណ្ដុះបណ្ដាលខាងគ្រប់គ្រង និងបច្ចេកទេសដែលមានជំនួយទ្រទ្រង់ពី NGO អន្ដរជាតិ ។ ប្រសិទ្ធភាពការងាររបស់សមាជិក FC ជាប់ទាក់ទិននឹងកំរិតនៃការយល់ដឹងពីស្ថានភាពនេសាទក្នុងសហគមន៍ ។ សមាជិកគណៈកម្មការជាច្រើននាក់ បានឆ្លើយសំភាសន៍ប្រាប់ពីការបារម្ភពីការថយចុះស្តុកត្រីក្នុងស្ទឹង បឹងបួរ ។ ជាច្រើននាក់បានប្រាប់ថា ការថយចុះត្រីគឺបណ្ដាលពីការនេសាទត្រីខុសច្បាប់ និងការងារគ្រប់គ្រងគ្មានដំណើរការរបស់អាជ្ញាធរជាប់ទាក់ទិន ។

*ក្រុមប្រឹក្សាឃុំ នៅតែចង់ឃើញ ចង់ដឹងពីលទ្ធផលការងាររបស់សមាគមទាំងអស់ក្នុងមូលដ្ឋាន ។ ប៉ុន្ដែ ជាប្រពៃណីអ្នកភូមិមិនសូវចង់ស្វែងរកជំនួយទ្រទ្រង់ រឺ ផ្ដល់ព័ត៌មានចុះឡើងជាមួយអាជ្ញាធរទេ លើកលែងតែមានជួបបញ្ហាចោទធ្ងន់ធ្ងរ ។ ចំណុចខ្សោយរបស់សង្គមស៊ីវិលនៅជនបទកម្ពុជា គឺសមាគមនីមួយៗ ធ្វើការងារដាច់ដោយឡែកពីគ្នា ។*

ការពិភាក្សាតាមក្រុមស្នូលបានបង្ហាញថា សមាជិកជាច្រើនក្នុងសហគមន៍មានគោលដៅដូចគ្នាក្នុងការថែរក្សាធនធានធម្មជាតិ និងបរិស្ថាននៅក្នុងសហគមន៍ ។ លទ្ធផលអង្កេតបានបង្ហាញថា ក្នុងគោលដៅនេះ FC បានបំពេញតួនាទីមួយចំនួនដូចជា ឃ្លាំមើលដើម្បីទប់ស្កាត់ការនាសាទខុសច្បាប់ក្នុងសហគមន៍, រាយការណ៍/ផ្ដល់ព័ត៌មាន ដល់អាជ្ញាធរជាប់ទាក់ទិន, និងធ្វើជាអង្គភាពទទួលទាក់ទងសំរាប់នាយកដ្ឋានជលផល និង CC ។ FC ក៏ធ្វើសហប្រតិបត្តិការផងដែរជាមួយអាជ្ញាធរមូលដ្ឋាន ដើម្បីបំពេញតួនាទីឱ្យកាន់តែបានសក្ដិសិទ្ធិ ក្នុងការទប់ស្កាត់ការនេសាទខុសច្បាប់ ។

គណៈកម្មការបាន បំពេញតួនាទីអប់រំ និងផ្សព្វផ្សាយព័ត៌មានដល់ប្រជាជនកុំឱ្យធ្វើអ្វីដែលបង្កការខូចខាតដល់ធនធានក្នុងសហគមន៍ ។ ក្នុងអនុក្រឹត្យមានបញ្ជីមួយយ៉ាងវែងនៃភារកិច្ចដែល FC ត្រូវអនុវត្ត ។ ប៉ុន្ដែតួនាទីជាក់ស្ដែងរបស់ FC គឺ ផ្ដល់ព័ត៌មានឱ្យអាជ្ញាធរជាប់ទាក់ទិន និងផ្សព្វផ្សាយព័ត៌មានដល់អ្នកភូមិ ។

*បញ្ហាប្រឈមរបស់* ***FC***

FC មានបញ្ហាប្រឈមមួយចំនួន ។ ទីមួយ FC ពុំមានឯករាជភាពខាងហិរញ្ញវត្ថុទេ ។ ការអនុវត្តន៍មានការយឺតយ៉ាវដោយសារកង្វះធនធាន និងបរិក្ខារសំរាប់ទប់ស្កាត់បទល្មើសនេសាទ ។ កង្វះការជួយទ្រទ្រង់ពិតៗអំពីអាជ្ញាធរជាប់ទាក់ទិន ក៏មានចំណែកក្នុងបញ្ហានេះដែរ ។ ទីពីរ ការងារ FC កាន់តែស្មុគ្រស្មាញថែម ដោយសារកង្វះការចូលរួមពេញលេញ និងដោយសុទ្ធចិត្តរបស់សមាជិកនានា ដោយអ្នកខ្លះខ្លាចមានការសងសឹកពីជនល្មើស បើសិនខ្លួនចូលពាក់ព័ន្ធក្នុងការកំចាត់បទល្មើសនេសាទ ។ កង្វះយន្ដការសំរាប់ការពារពួកសមាជិកអំពីការសងសឹកផ្សេងៗ បានធ្វើឱ្យ FC ជួបការលំបាក និងមានបញ្ហាចោទខាងចីរភាព ។ បើសិនគ្មានការចូលរួមពិតៗ និងការទ្រទ្រង់ដោយសុទ្ធចិត្តអំពីអាជ្ញាធរទេ ការបំពេញតួនាទីរបស់ FC ឱ្យបានសក្ដិសិទ្ធិក្នុងពេលអនាគត នៅតែជារឿងត្រូវបារម្ភ ។

*អន្ដរកម្មរវាងអង្គការ*

ទាំង FC និង SSC សុទ្ធតែខ្វះខាតការទ្រទ្រង់ខាងស្ថាប័ន ។ ស្ថាប័នតែមួយដែល FC តែងស្វែងរកជំនួយទ្រទ្រង់គឺ CC ប៉ុន្ដែ FC មានសង្ឃឹមតិចតួច ណាស់ពីព្រោះ CC ពុំមានសិទ្ធិអំណាចគ្រប់គ្រាន់ ដើម្បីដោះស្រាយបញ្ហា ។ FC និង CC កំរជួបប្រជុំគ្នាណាស់ ។ សមាជិក CC បានឆ្លើយសំភាសន៍ប្រាប់ថា CC នៅតែចង់ឃើញចង់ដឹងពីលទ្ធផលការងាររបស់សមាគមទាំងអស់ក្នុងមូលដ្ឋាន ។ ប៉ុន្ដែ ជាប្រពៃណី អ្នកភូមិមិនសូវចង់ស្វែងរកជំនួយទ្រទ្រង់ រឺផ្ដល់ព័ត៌មានចុះឡើងជាមួយអាជ្ញាធរទេលើកលែងតែមានជួបបញ្ហាចោទធ្ងន់ធ្ងរ ។ ចំណុចខ្សោយរបស់សង្គមស៊ីវិលនៅជនបទកម្ពុជា គឺសមាគមនីមួយៗ ធ្វើការងារដាច់ដោយឡែកពីគ្នា ។

ថ្វីបើការបង្កើត FC ត្រូវមានការផ្ដួចផ្ដើមគំនិតក្នុងមូលដ្ឋានរួមផ្សំក្ដី ក៏វាជាការតំរូវឡើងរបស់រដ្ឋាភិបាលផងដែរ ។ តាមការយល់ឃើញរបស់សង្គមស៊ីវិល FC មិនមែនផុសចេញជាបណ្ដើរៗពីសង្គមមួយដែលមានមូលធនខាងសង្គមកិច្ចច្រើនកុះករនោះទេ ។ ក្រុមអ្នកនិពន្ធបានកត់សំគាល់ឃើញសមាជិក FC ភាគច្រើនមានអារម្មណ៍ថា ពួកខ្លួនជាខ្សែរយៈ រឺជាបុគ្គលិករបស់អាជ្ញាធរមូលដ្ឋាន ។ សមាជិក FC អះអាងថាពួកខ្លួន មានសិទ្ធិអំណាចពិតៗ ដើម្បីសំរេចអារកាត់ (នេះជាការពិត) ប៉ុន្ដែថាពួកខ្លួនមានការទទួលខុសត្រូវចំពោះមុខអាជ្ញាធរ ជាជាងចំពោះមុខអ្នកភូមិ ។ FC ពឹងផ្អែកខ្លាំងពេកលើស្ថាប័នថ្នាក់លើនានាដែលបង្កើតខ្លួនឡើង ហើយភ្លេចថាប្រជាជនបានបោះឆ្នោតជ្រើសរើសពួកខ្លួនឡើង ។ នេះជាការទទួលខុសត្រូវចំពោះអំណាចថ្នាក់លើ ។ FC បានប្រឹងប្រែងខ្លាំងណាស់ ដើម្បីដោះស្រាយការតវ៉ាផ្សេងៗរបស់អ្នកភូមិដោយរាយការណ៍ និងសុំអន្ដរាគមន៍ពីនាយដ្ឋានជំនាញ ប៉ុន្ដែគ្មានការតវ៉ាបែបនេះណាមួយត្រូវបានប្រកាសចេញមកសោះ ។ ដូច្នេះ FC កំពុង ជួបបញ្ហាបាត់បង់ទំនុកចិត្តពីសំណាក់អ្នកភូមិ ។

FC ពុំមានកំលាំងច្រើនទេ ដោយសារកង្វះទំនុកចិត្ត និងការចូលរួមរបស់ប្រជាជន ឯចីរភាពក៏មានតិចតួចដែរ ដោយសារ FC ដំណើរការមិនបានល្អ ហើយកិច្ចសហការរវាងអង្គការ និងសិទ្ធិអំណាចក្នុងការសំរេចអារកាត់ ក៏នៅខ្សោយដែរ ។ តាមរូបភាពខាងក្រៅ FC ជាក្រុមសង្គមស៊ីវិលមួយដែលកើតចេញពីគំនិតផ្ដួចផ្ដើមនៅមូលដ្ឋាន ។ ប៉ុន្ដែ FC ភាគច្រើន គឺ NGO ជាអ្នកបង្កើតឡើងដោយមានក្របខ័ណ្ឌច្បាប់កំណត់ដោយរដ្ឋាភិបាល ហើយគំនិតផ្ដួចផ្ដើមក្នុងមូលដ្ឋានក៏មានចំណែកខ្លះដែរក្នុងការកកើតនេះ ។ មានការច្របូកច្របល់ច្រើនក្នុងចំណោមសមាជិក FC ដោយសារមិនច្បាស់ថាត្រូវគោរពតាមអ្នកណា ពីព្រោះតើត្រូវទទួលខុសត្រូវបែបណាចំពោះមុខប្រជាជនក្នុងមូលដ្ឋាន ខណៈដែលខ្លួនជាខ្សែរយៈរបស់ NGO រឺស្ថាប័នផ្សេងទៀត និងអ្នកណាជាមេកើយលើ FC ។ FC គិតថាខ្លួនត្រូវជំពាក់គុណអ្នកណាដែលបង្កើតអង្គការខ្លួនឡើង ។ រឿងនេះធ្វើឱ្យ FC ពឹងផ្អែកលើស្ថាប័នខាងក្រៅជាជាងលើប្រជាជនរបស់ខ្លួនផ្ទាល់ ។

## សេចក្ដីសន្និដ្ឋាន

សេចក្ដីសន្និដ្ឋានមួយចំនួនអាចទាញយកបានពីការប្រៀបធៀបរវាង SSC ដែលជាក្រុមជាប្រពៃណី និង FC ដែលជាក្រុមទទួលបានសិទ្ធិអំណាច ។ ក្នុង SSC មានការចូលរួមខ្លាំងក្លា ពីព្រោះសមាជិកភាគច្រើនសុទ្ធតែបានដឹងច្បាស់ពីសិទ្ធិអំណាចរបស់ខ្លួនដែលធ្វើការក្នុងក្រុមនេះ ។ ដោយសារក្នុងក្រុមមានប្រាក់កាសតិចណាស់ ដូច្នេះគ្មានការប្រកួតប្រជែងដណ្ដើមផលប្រយោជន៍ជាបុគ្គលនោះទេ ។ ចំពោះក្រុមទទួលបានសិទ្ធិអំណាច FC វិញ តាមធម្មតា គឺអ្នកខាងក្រៅជាពិសេស NGO និងរដ្ឋាភិបាលដែលបង្កើតក្រុមនេះឡើង ។ គេតែងមើលឃើញថា FC មានផលប្រយោជន៍មួយចំនួន ដូច្នេះមានប្រជាប្រិយភាពច្រើនជាមួយស្ថាប័នរឺអ្នកឯទៀតៗដែលចង់ទាញយកផលប្រយោជន៍ពីក្រុមនេះ ។ ដោយហេតុថា FC ច្រើនតែជំរុញឡើងដោយអ្នកខាងក្រៅមានសិទ្ធិអំណាចមិនគ្រប់គ្រាន់ និងមានការទទួលខុសត្រូវមិនច្បាស់លាស់ ដូច្នេះក្រុមនេះពិបាកទាក់ទាញ និងរក្សាឱ្យមានការចូលរួមរបស់ប្រជាជនបានយូរអង្វែង ។ ទាំងនេះគឺជាកត្តាចំបងៗដែលធ្វើឱ្យ FC បាត់បង់ទំនុកចិត្ត និងការគាំទ្រ ។

ចំពោះគោលគំនិតអំពីការចូលរួម និងចីរភាព SSC និង FC ខុសប្លែកគ្នាខ្លាំងណាស់ ។ ការប្រៀបធៀបក្រុមទាំងពីរក្នុងចំនុចគោលនៃការកសាងបណ្ដាញរវាងក្រុមនានាក្នុងមូលដ្ឋានវាមានសារៈសំខាន់ខ្លាំងណាស់ ដើម្បីស្វែងយល់ពីមូលធនខាងសង្គមកិច្ច ។ ក្រុមនានានៃសហគមន៍មូលដ្ឋានមានឆន្ទៈ និងសមត្ថភាពដើម្បីចរចាជាមួយអាជ្ញាធរមូលដ្ឋានពីរឿងគោលនយោបាយ និងការសំរេចចិត្តផ្សេងៗ ហើយទាំងសហគមន៍មូលដ្ឋាន និងអាជ្ញាធរមូលដ្ឋាន នឹងទទួលបានផលចំណេញទៅវិញទៅមក ។ ប៉ុន្ដែ អន្ដរកម្មខាងសង្គមកិច្ចច្រើនកើតឡើងជាលក្ខណៈក្រៅផ្លូវការ ហើយទាប់ទាក់ទិនខ្លាំងនឹងផលប្រយោជន៍ជាបុគ្គល ។

សមាជិក CC និងមន្ដ្រីជាច្រើនបានត្អូញត្អែរពីការពិបាកនឹងបំផុសឱ្យប្រជាជនមានការប្ដេជ្ញាចិត្តជួយសហគមន៍ ពីព្រោះពួកគាត់មើលឃើញថាជារបស់រួម ។ ប៉ុន្ដែម្នាក់ៗមានសន្ទុះចិត្តខ្លាំង ក្នុងការទាញយកចំណេញសំរាប់ផលប្រយោជន៍ផ្ទាល់ខ្លួន ។ អារម្មណ៏សំខាន់មួយទៀតគឺ កិច្ចសហការបុគ្គល-ស្ថាប័ន (មូលធនសង្គមកិច្ចជាស្ពានចំលង) ។ សំរាប់ប្រជាជនកម្ពុជាភាគច្រើន ការជួបទាក់ទងជាមួយមន្ដ្រីរាជការនៅគ្រប់កំរិត គឺជារឿងគ្រោះថ្នាក់ និងត្រូវចៀសវាងតាមអាចធ្វើបាន លើកលែងតែមានទំនាក់ទំនងជាសាច់ញាតិ រឺមិត្តភ័ក្ដិ ។ ចំណុចនេះស្របនឹងលទ្ធផលរកឃើញក្នុងការសិក្សាពីសង្គមជនបទនៅកម្ពុជា ។ អ្នកភូមិនៅតាមមូលដ្ឋានយល់ច្បាស់ណាស់ថាកង្វះអន្ដរកម្ម និងការពាក់ព័ន្ធជាមួយរដ្ឋ នឹងធ្វើឱ្យខ្លួនគ្មានសិទ្ធិអំណាច ។ ប៉ុន្ដែពួកគាត់នៅតែរារែកខ្លាំងណាស់ ក្នុងការកសាងខ្សែរយៈអន្ដរកម្មជាមួយអាជ្ញាធរ ។ ក្នុងនេះ SSC គឺជាករណីដោយឡែកមួយ ពីព្រោះទាំងមាតាបិតាសិស្ស និង CC សុទ្ធតែមានការប្ដេជ្ញាចិត្តខ្ពស់ជួយកែលំអការងារ SSC ។

## ឯកសារយោង


Blunt, Peter and Turner, Mark.

2005. *Decentralization, Democracy and Development in a Post-Conflict Society: Commune Council in Cambodia. Public Admin. Development*. 25, 75-87 (2005).

Cooperation Committee for Cambodia (CCC)

2004.*Experiences of Commune Councils in Promoting Participatory Local Governance.* Special Research Report: Analyzing Development Issues Team and Research Participants, CCC Phnom Penh, Cambodia.

Hughes, Caroline.

2005.*A Case Study of the Seila Program in Cambodia.* In "Making aid work in fragile states: Case Studies of Effective aid-financed programs" Background document, World Bank.

Kim, Sedara.

2004.*Local Government Responsiveness: Can Building Civil Society Enhance Accountability in Cambodia's Political Context?* Conference Report on Civil Society in Southeast Asia: Scope and Concepts. Organized by MISS and HBF, June 7-8, 2004, Phnom Penh, Cambodia

Mansfield, Cristina and Macleod, Kurt.

2004. *Commune Councils and Civil Society: Promoting Decentralization Through Partnerships.* PACT Cambodia, Phnom Penh, Cambodia.

Ninh, Kim and Henke, Roger.

2005. *Commune Councils in Cambodia: A national Survey on their Functions and Performance, with a Special Focus on Conflict Resolution.* The Asia Foundation and Center for Advanced Study, Phnom Penh, Cambodia.

Ojendal, Joakim.

2005.*A New Local State in Cambodia? Decentralization as a Political Commodity.* In "Southeast Asian Responses to Globalization: Restructuring Governance and Deepening Democracy" by Loh Kok Wash, Francis and Ojendal Joakim (edt.). NIAS Press, Copenhagen, Denmark.

Rusten, Caroline, Kim, Sedara, Eng, Netra, and Pak, Kimchoeun. 2004. *The Challenges of Decentralization Design in Cambodia.* Monograph, CDRI, Phnom Penh, Cambodia.

Royal Government of Cambodia (RGC).

2003. *Subdecree on Fishery Community Management.* Phnom Penh, Cambodia.

# ទំរង់បុរាណនៃមូលធនសង្គមកិច្ច នៅកម្ពុជា និងចំណងទាក់ទង ជាមួយដំណើរអភិវឌ្ឍន៍មូលដ្ឋាន

**លោក Arnaldo Pellini អធិប្បាយពីលក្ខណៈសំខាន់ៗនៃសមាគមជាប្រពៃណីតាមវត្តនៅជនបទ និងលទ្ធភាពរបស់សមាគមក្នុងការដើរតួយ៉ាងសកម្មពង្រឹងអភិបាលកិច្ចនៅមូលដ្ឋាន ហើយអ្នកនិពន្ធបានប្រើប្រាស់ទ្រឹស្ដីអំពីមូលធនសង្គមកិច្ច ដើម្បីធ្វើការវាយតំលៃពីសមាគមនានាដែលបានកកើត ឡើងនៅវត្តបទុម ក្នុងខេត្តកំពង់ធំ ។***

ការចូលរួម និងសហគមន៏ គឺជាពាក្យប្រើក្នុងផ្នែកអភិវឌ្ឍន៏តាំងពីទសវត្សរ៏១៩៦០ ។ បច្ចុប្បន្ន រាជរដ្ឋាភិបាលកម្ពុជាកំពុងធ្វើកំណែទំរង់ស្ថាប័ន ហើយក្នុងនេះមានការទទួលស្គាល់ថា ការចូលរួមគឺជាគោលដៅដ៏ចំបងមួយ ។ ប៉ុន្តែជារឿយៗ ការចូលរួមនៅមានកំរិតទាបនៅកម្ពុជា ដោយសារបញ្ហាឋានានុក្រមក្នុងសង្គម និងការបាត់បង់ *ទំនុកចិត្ត និងទំនាក់ទំនងក្នុងសង្គម* ដែលបង្កឡើងដោយសង្គ្រាម និងរបបខ្មែរក្រហម (Ovesen *et al* 1996) ។ ជាលទ្ធផល គំនិតផ្ដួចផ្ដើមអភិវឌ្ឍន៏នៅកំរិតភូមិក្នុង ១០ឆ្នាំចុងក្រោយ បានផ្ដោតលើការបង្កើតគណៈកម្មការ និងក្រុមផ្លូវការផ្សេងៗដោយមិនបានយកចិត្តទុកដាក់គ្រប់គ្រាន់ទេចំពោះ *ទំរង់បុរាណនៃការរៀបចំសហគមន៏* ដែលបាននៅគង់វង្សឆ្លងផុតពីក្នុងសម័យសង្គ្រាម ។

ក្នុងពេលថ្មីៗ មានឯកសារកាន់តែច្រើន (e.g. Krishnamurthy 1999; Kim 2001; Lederwood and Vijghen 2002) បានផ្ដោតលើអន្តរកម្មក្នុងសង្គម និងឌីណាមិកសហគមន៏ ដោយបានបង្ហាញថា មូលធនសង្គមកិច្ចនៅកម្ពុជា បានខូចខាត ប៉ុន្តែមិនមែនបំផ្លាញអស់ដោយសារសង្គ្រាម និងរបបខ្មែរក្រហមនោះទេ ។ នោះគឺជាទំរង់ជាប្រពៃណីនៃការកេណ្ឌប្រមូលសហគមន៏ដែលគំរោងអភិវឌ្ឍន៏ និងគំនិតផ្ដួចផ្ដើមនានារបស់អាជ្ញាធរមូលដ្ឋាន អាចយកធ្វើជាដៃគូ ដើម្បីសំរេចបាន *ការអភិវឌ្ឍន៏ផ្អែកលើសហគមន៏* ដែលមានចីរភាព ។ អត្ថបទនេះ បន្តពីអត្ថបទមួយទៀត ដែលបានចុះផ្សាយក្នុង *ទស្សនាវដ្ដីអភិវឌ្ឍន៏កម្ពុជា* (Pellini 2004) និងដែលអធិប្បាយពីលក្ខណៈសំខាន់ៗនៃសមាគមជាប្រពៃណីតាមវត្តនៅជនបទ និងលទ្ធភាពរបស់សមាគមក្នុងការដើរតួយ៉ាងសកម្ម ពង្រឹងអភិបាលកិច្ចនៅមូលដ្ឋាន ។ ឯអត្ថបទនេះវិញ វាផ្ដោតច្រើនជាងទៅលើទ្រឹស្ដីអំពីមូលធនសង្គមកិច្ច ដើម្បីធ្វើការវាយតំលៃពីសមាគមនានាដែលបានកកើតឡើងនៅវត្តបទុម ក្នុងខេត្តកំពង់ធំ ។

## ធាតុផ្សំនៃមូលធនសង្គមកិច្ចនៅកម្ពុជា

ទ្រឹស្ដីអភិវឌ្ឍន៏នៅទសវត្សរ៏១៩៥០ បានសង្កត់ធ្ងន់លើកំនើនសេដ្ឋកិច្ច ។ ប៉ុន្តែនៅពាក់កណ្ដាលទសវត្សរ៏ ១៩៥០ Solow បានបង្ហាញថា *បច្ចេកវិទ្យា* គឺជាអថេរមួយដែលមិនទាន់បានដាក់បញ្ចូលក្នុងគំរូកំនើនសេដ្ឋកិច្ច ។ Singer (១៩៦១) បានណែនាំឱ្យបញ្ចូលធាតុផ្សំមួយទៀត គឺ *សមត្ថភាព* បង្កើតទ្រព្យធន ។ Schultz (១៩៦៣) បានសំគាល់វាជា *មូលធនមនុស្ស* ហើយពិពណ៌នាពីបែបបទដែលចំណេះដឹង និងការអប់រំ អាចជួយឱ្យអត្រាកំណើនសេដ្ឋកិច្ចឡើងខ្ពស់ថែមទៀត ។ នៅចុងទសវត្សរ៏១៩៨០ ពាក្យ *មូលធនសង្គមកិច្ច* ត្រូវបានបង្កើតឡើងដើម្បីពិពណ៌នាពីឥទ្ធិពលជាវិជ្ជមានសំរាប់ការអភិវឌ្ឍន៏ និងប្រជាធិបតេយ្យរូបនីយកម្ម នៃអន្តរកម្ម, និងការដោះដូរផ្សេងៗរវាងបុគ្គល ក្រុមស្ម័គ្រចិត្ត និងស្ថាប័ន (Putnam ១៩៩៣) ។ ក្នុងផ្នែកនេះមានការបង្ហាញពីធាតុផ្សំខ្លះៗដែលជាលក្ខណៈផ្ទាល់នៃមូលធនសង្គមកិច្ចនៅកម្ពុជា ។

### *សង្គម*

Putnam កំណត់និយមន័យ មូលធនសង្គមកិច្ច ជា "លក្ខណៈនៃអង្គការខាងសង្គមកិច្ច ដូចជា បណ្ដាញក្បួនច្បាប់ និងទំនុកចិត្តជាដើម ដែលជួយដល់ការសំរបសំរួល និងកិច្ចសហប្រតិបត្តិការ ដើម្បីបានផលប្រយោជន៏ទៅវិញទៅមក" ។ យោងតាម Krishna (២០០០) និយមន័យរបស់ Putnam ផ្ដោតលើរូបភាពតាមខ្សែផ្ដេកនៃមូលធនសង្គមកិច្ចដែលផ្សំឡើងដោយ តំលៃសីលធម៌ របៀបរបប និងជំនឿផ្សេងៗ ដែលមានរួមគ្នានៅក្នុងសង្គម ។ Krishna បានកំណត់វាថាជា *មូលធនសង្គមកិច្ចខាងទំនាក់ទំនង* ។ ប៉ុន្តែមូលធនសង្គមកិច្ចក៏មានរូបភាពតាមខ្សែបញ្ឈរដែរ ដែលជាការបែងចែកអំណាចមិនស្មើភាពគ្នា និងតាមឋានានុក្រម ។ Krishna កំណត់រូបភាពទីពីរនេះ ជា *មូលធនសង្គមកិច្ចខាងស្ថាប័ន* ។ គួរកត់សំគាល់ជាសំខាន់ថា រូបភាពទាំងពីរនេះមានចំណងទាក់ទងចុះឡើង ហើយ Uphoff (2000) បានលើកបង្ហាញថា *មូលធនសង្គមកិច្ចខាងទំនាក់ទំនង* ជះឥទ្ធិពលឱ្យបុគ្គលចូលចិត្តធ្វើសកម្មភាព ជាសមូហភាព រីឯ *មូលធនសង្គមកិច្ចខាងស្ថាប័ន* បង្កើតលក្ខខណ្ឌចាំបាច់ និងទីកន្លែង សំរាប់ជួយសំរួលដល់សកម្មភាពនេះ ។

សង្គមកម្ពុជាបច្ចុប្បន្នមានលក្ខណៈជាចំណងទាក់ទងតាមខ្សែបញ្ឈរយ៉ាងធូររលុងរវាងក្រុមមនុស្សខុសៗគ្នា និងចំណងទាក់ទងយ៉ាងមាំរវាងពួកសមាជិកដែលមានឋានៈសង្គមស្មើគ្នា ។ ចំណុចនេះ បានបង្កើតឱ្យមានការផាត់មនុស្សចេញពីសង្គម និងការលំបាកបំផុតក្នុងការឡើងចុះឋានៈសង្គម ដោយផ្អែកលើគុណសម្បត្តិនិងជំនាញ ។ លើសពីនេះ គំនិតប្រពៃណីនិយមដែលជ្រាបជោគជាំក្នុងសង្គមកម្ពុជា បានក្លាយជាការបង្អាក់ទឹកចិត្តជាទូទៅដល់ការសាកល្បងអ្វីដែលថ្មី ដោយគេយល់ឃើញថា អ្វីៗត្រូវតែធ្វើឡើងទៅតាមបែបបទដែលធ្លាប់ធ្វើតាំងពីដើមរៀងមក (Chandler 1998; O'Leary and Meas 2001) ។ យោងតាម Gyallay-Pap (2004: 35) សាមគ្គីភាពកំរិតទាប ដូច្នេះ គឺមកពី *បេសកកម្មកសាងអរិយធម៌* របស់បារាំង ។ កាលមុនសម័យអាណានិគម ភូមិនិងកន្លែងតាំងលំនៅនានាមានលក្ខណៈវិមជ្ឈការខ្ពស់ ហើយជីវិតរស់នៅគឺផ្អែកលើ "និមិត្តរូបនៃវប្បធម៌រួម, សាសនានិង

---

* លោក Arnaldo Pellini ធ្លាប់ធ្វើជាទីប្រឹក្សានៅផ្នែកសង្គមស៊ីវិល/អភិបាលកិច្ចមូលដ្ឋានក្នុងគំរោងអភិវឌ្ឍន៏ជនបទរបស់ GTZ នៅខេត្តកំពង់ធំ ពីឆ្នាំ២០០២ ដល់ដើមឆ្នាំ២០០៥ ។ គាត់មានសញ្ញាប័ត្រអនុបណ្ឌិតផ្នែកអភិវឌ្ឍន៏សេដ្ឋកិច្ច និងជានិស្សិតថ្នាក់បណ្ឌិតនៅមហាវិទ្យាល័យ Tampere នៅប្រទេសហ្វាំងឡង់ ។

ទំនួលខុសត្រូវលើគំនិតសត្យានុម័ត និងការបញ្ចេញយោបល់ទាំងឡាយនៅក្នុងអត្ថបទនេះ គឺជាបន្ទុកផ្ទាល់របស់អ្នកនិពន្ធ ។ ការបញ្ចេញយោបល់ និងការបកស្រាយទាំងនោះ មិនមែនជាទស្សនៈរបស់ *វិទ្យាស្ថាន* ទេ ។

បែបបទសីលធម៌ និងសកម្មភាពសហគមន៍" ។ ប៉ុន្តែការដាក់អាណានិគម របស់រដ្ឋបាលកណ្តាល និងសេដ្ឋកិច្ចផ្អែកលើរូបិយវត្ថុ បានលើកស្ទួយជំហរបុគ្គលនិយម ហើយបានកាត់បន្ថយជំហរសាមគ្គីភាពរវាងបុគ្គលនានា ។

ទំនុកចិត្ត គឺជាធាតុផ្សំសំខាន់បំផុតនៃមូលធនសង្គមកិច្ច ។ Uphoff (2000:35) កំណត់វាថាជា "ការដ៏ចាំបាច់ សំរាប់ផ្សារភ្ជាប់សង្គម" ។ ទំនុកចិត្តពឹងផ្អែកលើវត្តមានព័ត៌មាន ព្រមទាំងក្បួនច្បាប់ជាផ្លូវការ និងក្រៅផ្លូវការ ដែលជួយពង្រឹងដល់ការរំពឹងទុកពីបុគ្គលម្នាក់ទៅបុគ្គលម្នាក់ ។ ក្បួនច្បាប់ផ្លូវការពាក់ព័ន្ធនឹងប្រព័ន្ធតុលាការ និងការបំពេញមុខងាររបស់ស្ថាប័នសាធារណៈ ។ ក្បួនច្បាប់ក្រៅផ្លូវការពាក់ព័ន្ធនឹងរង្វាន់ចំពោះឥរិយាបថគួរឱ្យទុកចិត្ត និងទណ្ឌកម្មសង្គម ដូចជា ការថ្កោលទោសឱ្យអ្នកបំពានលើក្បួនច្បាប់មានការអៀនខ្មាស (Pye 1999) ។ ដោយសារសង្គ្រាម និងរបបខ្មែរក្រហម គេគិតថា មានការបាត់បង់ទំនុកចិត្តគ្នាក្នុងសង្គមកម្ពុជា (UNICEF 1996) ។ របបខ្មែរក្រហមបានបំផ្លិចបំផ្លាញជាលក្ខណៈប្រព័ន្ធនូវតំលៃជាប្រពៃណីនានាក្នុងសង្គម ដូចជា គ្រួសារ និងសាសនាជាដើម ប៉ុន្តែអ្នកនិពន្ធបានរំលេចថា ទំនុកចិត្តមិនមែនខូចខាតអស់ទាំងស្រុងទេ គឺមាននៅសេសសល់ខ្លះក្នុងលក្ខណៈជា ទំរង់ជាប្រពៃណីនៃសកម្មភាពសមូហភាព ។

### *សាសនា និងវត្ត ជាកន្លែងសំរាប់អ្នកចូលរួម*

គោលគំនិតទូទៅរបស់សាសនា ដូចជា ទំនុកចិត្ត និងការកសាងបណ្តាញ ត្រូវបាន Putnam ចាត់ទុកជាប្រភពដ៏សំខាន់មួយនៃមូលធនសង្គមកិច្ច ។ ប៉ុន្តែសាសនាក៏អាចដើរតួពីរយ៉ាងដែរ ។ ឧទាហរណ៍ ក្នុងពុទ្ធសាសនាហិនយាននៅកម្ពុជាគឺមាន ម្យ៉ាងការសង្កត់ធ្ងន់លើគោលការណ៍នៃកម្មផល ដើម្បីបញ្ជាក់ពីលក្ខណៈសមហេតុផលនៃភាពខុសគ្នាសព្វថ្ងៃរវាងបុគ្គលនានា និងពីឋានានុក្រមក្នុងសង្គម (Coletta and Cullen 2000), និងម្យ៉ាងទៀត វត្តអារាម ដើរតួជាកន្លែងស្នូលពិតប្រាកដនៃជីវិតរស់នៅក្នុងសហគមន៍ និងគំនិតផ្តួចផ្តើមនានារបស់សហគមន៍ (Aschmoneit 1996) ។ តាមធម្មតាវត្តមួយមានចំណងទាក់ទងនឹង ៦ ទៅ ៨ភូមិ ហើយការប្រជុំរបស់សហគមន៍គឺភាគច្រើនធ្វើនៅក្នុងវត្ត មិនមែននៅក្នុងភូមិទេ ។

*គណៈកម្មការវត្ត* គឺជាស្ថាប័នគ្រប់គ្រងបែបសង្គមកិច្ច និងមិនមែននយោបាយ និងរួមមាន អាចារ្យ ដែលទទួលបានការតែងតាំង រឺការបោះឆ្នោតជ្រើសរើសចេញពីភូមិនៅជិតៗ ។ គណៈកម្មការនេះមានភារកិច្ចដោះស្រាយតំរូវការរបស់ព្រះសង្ឃ ថែទាំវត្ត និងរៀបចំពិធីបុណ្យផ្សេងៗ ។ អាចារ្យទទួលបានទំនុកចិត្តពី សហគមន៍ និងមានតួនាទីដឹកនាំ (Aschmoneit *et al.* 1995) ។ នៅពេលគណៈកម្មការវត្តផ្តើមធ្វើសកម្មភាពអភិវឌ្ឍន៍សហគមន៍ជាក់លាក់អ្វីមួយ មានការបោះឆ្នោតបង្កើត *សមាគមវត្តចំពោះកិច្ច* ដោយមាន *គណៈកម្មការសមាគម* មួយផង សំរាប់គ្រប់គ្រងសកម្មភាពនានា ។ មូលធនហិរញ្ញវត្ថុដំបូងរបស់សមាគមនេះ បានមកពីការចូលប្រាក់នៅក្នុងពិធីបុណ្យផ្សេងៗខាងសាសនា ។ ក្រោយមកទៀត ការប្រាក់បានមកពីការផ្តល់កំចីផ្សេងៗ គឺជាចំណូលចំបងរបស់សមាគម ។ នៅចុងឆ្នាំ គណៈកម្មការសមាគមជួបប្រជុំគ្នា ដើម្បីសំរេចពីការចូលវិភាគទានជួយដល់ការងារអភិវឌ្ឍន៍ផ្សេងៗ ដែលផ្តួចផ្តើមធ្វើនៅក្នុងមូលដ្ឋាន ។

### **សមាគមរបស់វត្តបទុម**

វត្តបទុមមានទីតាំងនៅក្នុងភូមិបទុមលិច ខេត្តកំពង់ធំ[២] ។ វត្តបទុម មានភូមិជើងវត្តចំនួន ៦ភូមិ[៣] ។ សកម្មភាពអភិវឌ្ឍន៍សហគមន៍មានឫសគល់តាំងពីឆ្នាំ១៩៥២ ដែលកាលនោះចៅអធិការ ធៀង ញ៉ា និងអាចារ្យ ១២នាក់ បានបង្កើតសមាគមសាច់ប្រាក់មួយ ។ នៅឆ្នាំ១៩៥៩ សមាគមនេះ មានទុនគ្រប់គ្រាន់អាចជួយទ្រទ្រង់ ការសាងសង់សាលាបឋមសិក្សាមួយនៅជិតវត្ត ។ នៅឆ្នាំ១៩៧២ នៅពេលភូមិបទុមលិច ធ្លាក់ក្រោមការត្រួតត្រារបស់ខ្មែរក្រហម សមាគមបានផ្អាកសកម្មភាព ។ អាចារ្យនៅវត្តបទុម បានយកឯកសារសំខាន់ៗ និងបដិមាករ ច្រកក្នុងបំពង់ឫស្សីរួចបិទឱ្យជិតហើយកប់លាក់ទុកនៅក្រោមផ្ទះរបស់គាត់ ។ ពួកគាត់បានជីកយកមកវិញ ក្រោយពេលខ្មែរក្រហមបានដួលរលំ ហើយពេលនោះលោកតា ធៀង ញ៉ា បានត្រឡប់មកវត្តបទុមវិញក្នុងឋានៈជាអាចារ្យ ។ ក្នុងទសវត្សរ៍១៩៨០ មានការពិបាកនឹងបង្កើតសមាគមឡើងវិញ ពីព្រោះរដ្ឋាភិបាលបានសំរេចអោយបង្កើតក្រុមសាមគ្គី សំរាប់ទទួលបន្ទុកលើសកម្មភាពផ្សេងៗក្នុងសហគមន៍ និងការស្តារកសាងភូមិនីមួយៗ ។ ប្រជាជនគ្មានប្រាក់ទេ ដូច្នេះជារឿយៗគេយកស្រូវធ្វើការទូទាត់ផ្សេងៗ ។ លោកតា ធៀង ញ៉ា និងអាចារ្យឯទៀត បានបើកដំណើរការសមាគមឡើងវិញនៅចុងឆ្នាំ១៩៨៨ ហើយសមាគមសាលាវត្តបទុមត្រូវបានសម្ពោធជាផ្លូវការនៅខែមករា ១៩៨៩ ។ សមាគមសាលាមួយទៀត ដែលមានចំណងទាក់ទងជាមួយវត្តបទុម បានបង្កើតឡើងនៅភូមិកន្ទុងរ៉ុងនៅក្បែរនោះនៅខែមករា ១៩៩២ ។ ចំពោះជំនួយទ្រទ្រង់ពីខាងក្រៅ គឺសមាគមទទួលបានពី GTZ[៤] តាំងពីឆ្នាំ១៩៩៥ ដែលមានវគ្គបណ្តុះបណ្តាលស្តីពីការគ្រប់គ្រង ស្តីពីរដ្ឋបាល ហើយក្នុងពេលសព្វថ្ងៃគឺ វគ្គបណ្តុះបណ្តាលស្តីពីអភិបាលកិច្ចមូលដ្ឋាន ។

### **ការពិភាក្សា**

មានចំនុចបីចំបងៗដែលផុសចេញពីបទពិសោធន៍នៅវត្តបទុមៈ សារៈសំខាន់នៃភាពជាអ្នកដឹកនាំសំរាប់សកម្មភាពជាសមូហភាព, កំលាំងដ៏ខ្លាំងនៃ *មូលធនសង្គមកិច្ចខាងទំនាក់ទំនង* និងចំណងទាក់ទងតាមខ្សែផ្តេកនៅក្នុងសហគមន៍ ហើយនិងកំលាំងដ៏ខ្សោយនៃ *មូលធនសង្គមកិច្ចខាងស្ថាប័ន* នឹងចំណងទាក់ទងតាមខ្សែបញ្ឈររវាងសហគមន៍ និងអាជ្ញាធរ ។

### *ភាពជាអ្នកដឹកនាំ*

ការដឹកនាំរបស់ព្រះតេជគុណ ធៀង ញ៉ា កន្លងមកមកគឺជាកំលាំងជំរុញធំក្នុងការបង្កើតសមាគមនានានៅវត្តបទុម និងនៅភូមិក្បែរៗនោះ ។ គេនៅចងចាំថា "លោកជាអ្នកដឹកនាំខ្លាំងមួយរូបដែលតែងចុះជួបអ្នកភូមិ, សាកសួរពីតំរូវការរបស់ពួកគេ និងខិតខំរកវិធីជួយគេដោយប្រើឥណទានតូចៗរបស់សមាគមសាច់ប្រាក់" (សំភាសន៍បុគ្គលទី១) ។ រឿងនេះបង្ហាញថា ការគោរព និងទំនុកចិត្តដែលអ្នកភូមិមានចំពោះព្រះសង្ឃ និងអាចារ្យ មិនមែនផ្សារភ្ជាប់តែទៅនឹងមុខតំណែងជាអ្នកដឹកនាំរបស់លោកប៉ុណ្ណោះទេ ប៉ុន្តែផ្សារភ្ជាប់ទៅនឹងភាពសកម្មរបស់លោកនៅក្នុងសហគមន៍ផងដែរ ព្រមទាំងសមត្ថភាពប្រមូលវិភាគទានក្នុងមូលដ្ឋានផង ។

សិទ្ធិអំណាចរបស់អាចារ្យ កំរមានអ្នកណាសង្ស័យ/សើរើណាស់ ហើយពួកគាត់ច្រើនតែអាចរក្សាមុខតំណែង និងការទទួលខុសត្រូវបានយូរអង្វែង ។ ឧទាហរណ៍ ការបោះឆ្នោតជ្រើសតាំងគណៈកម្មការសមាគមធ្វើឡើងមិនទៀងទាត់ទេ ដូចជាករណី សមាគមសាលាវត្តបទុម ដែលបានធ្វើតែពីរដងប៉ុណ្ណោះ ។ គ្រោះថ្នាក់ក្នុងរឿងនេះ គឺអ្នកដឹកនាំអាចមិនសូវយកចិត្តទុកដាក់ពីតម្លាភាព និងគណនេយ្យភាព (ការទទួលខុសត្រូវ) ចំពោះសមាជិករបស់សមាគម ។ ម្យ៉ាងទៀត អាចារ្យច្រើនតែមានឱកាសបានទទួល

ការបណ្ដុះបណ្ដាល និងការអប់រំ ដូច្នេះហើយក៏កាន់តែបង្កើនចំនេះដឹង និងពង្រីងការដឹងនាំរបស់ខ្លួនថែមទៀត ។ ប៉ុន្ដែ Aschmoneit (1996) កត់សំគាល់ថា អាចារ្យច្រើនតែប្រយ័ត្នប្រយែងមិនធ្វើការសំរេចចិត្តអ្វីដែលគ្មានប្រជាប្រិយភាព និងដែលនាំឱ្យខូចខាតដល់ទំនុកចិត្ត និងការមូលមតិនៅក្នុងសហគមន៍នោះទេ ។

### *មូលធនសង្គមកិច្ចខាងទំនាក់ទំនង ដ៏ខ្លាំង*

តំបន់ជនបទកម្ពុជា តាំងពីដើមរៀងមក តែងនៅឆ្ងាយពីអាជ្ញាធរមជ្ឈឹមនៅភ្នំពេញ ។ រឿងនេះផ្ដល់ឱកាសល្អ ដល់ការកកើតទំនាក់ទំនងបែបអ្នកឧបត្ថម្ភ-អ្នកទទួលផលនៅកំរិតមូលដ្ឋាន, និងប្រព័ន្ធរបស់អ្នកភូមិផ្ទាល់សំរាប់ដោះស្រាយបញ្ហា ដែលជួយដល់បុគ្គលនៅពេលមានវិបត្តិ[៥] ។ យន្ដការនេះត្រូវខូចខាតដោយសង្គ្រាម និងរបបខ្មែរក្រហម ប៉ុន្ដែមិនមែនខូចខាតទាំងស្រុងនោះទេ (Coletta and Cullen 2000) ។ បណ្ដាញគ្រួសារធំទូលាយគឺជាយន្ដការដោះស្រាយចំបងក្នុងរបបខ្មែរក្រហម រីឯវត្តគឺជាទីពំនាក់ដ៏សំខាន់សំរាប់សកម្មភាពសហគមន៍នៅក្រោយសម័យខ្មែរក្រហម ។ សាមគ្គីភាពគឺជាមូលដ្ឋាននៃសកម្មភាពឥណទានរបស់សមាគមវត្ត ។ ឧទាហរណ៍ ក្នុងប៉ុន្មានឆ្នាំថ្មីៗ សមាគមសាលាវត្តបទុមបានព្យាយាមផ្ដល់កំចីច្រើនជាងមុនទៅអោយអ្នកក្រ ។ សាសនាក៏បានជួយជំរុញដល់ការចូលរួមដែរ ហើយតាមកិច្ចសំភាសន៍បុគ្គលទី២គឺ "អ្នកភូមិចូលវិភាគទាន ពីព្រោះពួកគេជឿលើពុទ្ធសាសនា ហើយគិតថា ការធ្វើអំពើល្អនឹងទទួលបានកុសលផលបុណ្យ" ។ សមាជិកសមាគមមានអារម្មណ៍ផ្សារភ្ជាប់យ៉ាងជិតស្និទ្ធជាមួយក្រុម និងស្ថាប័ននានាដូចជា Pacoco[៦] ជាដើម ដែលមានចំណងទាក់ទងផ្ទាល់ជាមួយពួកគេ ។ រឿងនេះបង្ហាញពី កំលាំងនៃមូលធនសង្គមកិច្ចខាងទំនាក់ទំនង និងកំលាំងនៃចំណងទាក់ទងផ្អែកលើសាមគ្គីភាព ការគោរពចំពោះថ្នាក់ដឹកនាំ និងទំនុកចិត្តដូចដែល Putnam (1993) បានពិពណ៌នា ។

### *មូលធនសង្គមកិច្ចខាងស្ថាប័ន ដ៏ខ្សោយ*

"យើងមិនទុកចិត្តគ្រូបង្រៀនទេ, សមាជិកសមាគមទុកចិត្ត Pacoco និងសមាជិកគណៈកម្មការជាង" (កិច្ចសំភាសន៍បុគ្គលទី ១) ។ ប្រយោគនេះបង្ហាញពីការមិនទុកចិត្តដែលបំបែកប្រជាជនចេញពីតំណាងរដ្ឋាភិបាល ។ គំលាតនេះមានទំហំធំជាពិសេសនៅតាមតំបន់ជនបទ ដោយសារភាពដាច់ឆ្ងាយពីគេតាំងពីដើមមកនៃតំបន់ទាំងនេះ និងការដែលខ្មែរក្រហមបានធ្វើឱ្យខូចខាតដល់កេរ្តិ៍ឈ្មោះរដ្ឋាភិបាល ។ ក្នុងករណីនៅបទុម ការសន្ទនារវាងគ្រូបង្រៀន និងសមាជិកសមាគមសាលា នៅមានតិច និងមិនហួសពីបញ្ហាការចូលវិភាគទានខាងហិរញ្ញវត្ថុនោះទេ ។ ហេតុផលសំខាន់នៃភាពតានតឹងរវាងសមាគម និងគ្រូបង្រៀន គឺហាក់ដូចជារឿងតម្លាភាពក្នុងការប្រើប្រាស់ថវិកា: "ការប្រើប្រាស់ប្រាក់វិភាគទានក្នុងមូលដ្ឋាន តាមធម្មតាគឺគ្រប់គ្រងដោយគ្រូបង្រៀន និងសមាជិកសមាគម ។ ឆ្នាំមុន (២០០៤) ខាងគ្រូបានសុំជំនួយថវិកាសំរាប់ទិញសំភារៈធ្វើរបងសាលា ប៉ុន្ដែរហូតមកដល់សព្វថ្ងៃមិនទាន់បានធ្វើរបងអ្វីបន្ដិចសោះ ។ ដូច្នេះ ពេលនេះយើងនឹងសុំអោយមេឃុំចូលពាក់ព័ន្ធ ដើម្បីសួរគ្រូបង្រៀនអោយបំភ្លឺពីការប្រើប្រាស់ប្រាក់ដែលពួកយើងបានផ្ដល់" (សំភាសន៍បុគ្គលទី១) ។ ទំនាក់ទំនងល្អជាមួយក្រុមប្រឹក្សាឃុំបានចាប់ផ្ដើមផុសឡើងហើយ ប៉ុន្ដែគ្មានទំនាក់ទំនងអ្វីសោះរវាងសមាគម និងអាជ្ញាធរខេត្ត/ស្រុក ។ រឿងនេះអាចមកពី ការដាក់សម្ពាធលើការិយាល័យអប់រំខេត្ត/ស្រុក ឱ្យបង្កើនការចូលរួមតាមរយៈការបង្កើតគណៈកម្មការចំពោះកិច្ចផ្សេងៗ និងការរារែករបស់សមាជិកសមាគមក្នុងការចូលរួមក្នុងកិច្ចប្រជុំជាសាធារណៈ បើសិនគ្មានការអញ្ជើញជាផ្លូវការ ។

## សេចក្ដីសន្និដ្ឋាន

ក្នុងអត្ថបទនេះ អ្នកនិពន្ធបានរែកញែកថា សមាគមវត្តគឺជាច្រកជាប្រពៃណីសំរាប់សកម្មភាពសហគមន៍ ។ សមាគមទាំងនេះ គឺជាមូលធនសង្គមកិច្ចតាមទំរង់របស់អ្នកភូមិផ្ទាល់ដែល "មិនគ្រាន់តែជាចំណែកមួយនៃសង្គមស៊ីវិលនៅកម្ពុជាប៉ុណ្ណោះទេ ប៉ុន្ដែវាជាចំណែកមួយយ៉ាងធំ និងរឹងប៉ឹងជាងគេ" ផងដែរ (Gyallay-Pap 2004:36) ។ ករណីវត្តបទុមបង្ហាញពីចំណុចវិជ្ជមានព្រមទាំងចំនុចខ្វះខាត នៅក្នុងទំនាក់ទំនងរវាងសហគមន៍ ស្ថាប័នសាធារណៈ និងវត្ត ។ គេបានឃើញថា ទំនុកចិត្ត និងក្បួនច្បាប់ខាងសាសនាផ្សេងៗ វាកំណត់ឡើងនូវមូលធនសង្គមកិច្ចខាងទំនាក់ទំនងរវាងអ្នកភូមិ ហើយនិងវត្ត, រីឯចំណងទាក់ទងតាមខ្សែបញ្ឈរជាមួយស្ថាប័ននានា គឺនៅទន់ខ្សោយនៅឡើយ ។ ការអភិវឌ្ឍន៍បែបប្រជាធិបតេយ្យនិងមានសមធម៌នៅកម្ពុជាទាមទារឱ្យមានតុល្យភាពល្អរវាងរូបភាពទាំងពីរនៃមូលធនសង្គមកិច្ច ។ ចំណងទាក់ទងតាមខ្សែផ្ដេកយ៉ាងរឹងប៉ឹង ដែលផ្អែកលើទំនុកចិត្តនៅកំរិតមូលដ្ឋាន គឺសំខាន់ និងចាំបាច់ណាស់ ពីព្រោះវាអាចជួយកេណ្ឌប្រមូលធនធាន និងរៀបចំសកម្មភាពសមូហភាព ។ ក្នុងពេលជាមួយគ្នាចំណងទាក់ទងតាមខ្សែបញ្ឈរដែលរឹងប៉ឹងជាងនេះរវាងសង្គមស៊ីវិល និងអាជ្ញាធរ អាចជួយពង្រឹងដល់ស្ថាប័នសាធារណៈនានា និងដំណើរការអភិវឌ្ឍន៍ ហើយដើម្បីសំរេចរឿងនេះបាន ចាំបាច់ត្រូវមានការផ្លាស់ប្ដូរឥរិយាបថ ។ សមាជិកសមាគមជាប្រពៃណីនានា អាចចាប់ផ្ដើមកិច្ចសន្ទនាជាមួយអាជ្ញាធរមូលដ្ឋាន (ដូចជាកសាងចំណងទាក់ទងជាមួយក្រុមប្រឹក្សាឃុំជាដើម) ដើម្បីពិភាក្សាពីតំរូវការក៏ដូចជាការចូលរួមវិភាគទានរបស់ខ្លួននៅក្នុងការងារអភិវឌ្ឍន៍មូលដ្ឋាន ។ ម្យ៉ាងទៀត ស្ថាប័នរដ្ឋាភិបាលត្រូវជួយបង្កលក្ខខណ្ឌផ្សេងៗដើម្បីបើកលទ្ធភាពឱ្យមានការចូលរួម ហើយក្នុងនេះការសន្ទនានឹងធ្វើអោយប្រជាជនបានចូលពាក់ព័ន្ធកាន់តែច្រើននៅក្នុងការសំរេចចិត្ត និងដំណើរការអភិវឌ្ឍន៍ ។ ឧទាហរណ៍ដែលលើកឡើងក្នុងអត្ថបទនេះបង្ហាញថា សក្ដានុពលនៅកំរិតមូលដ្ឋាន គឺមានជាស្រេចហើយ ។

## កំណត់សំគាល់

១. សូមអាន Arndt, Heinz W. (1987). Economic Development. The History of an Idea, Chicago University Press, London ។
២. ឃុំរុងរឿង, ស្រុកស្ទោង
៣. បទុមកើត, បទុមលិច, កន្ដុងរ៉ុង, ព្រំស្រី, បុះតាសោម, និងកន្ទើប
៤. Gesellschaff fur Technische Zusammennarbeit – ទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសអាឡឺម៉ង់
៥. ចំពោះពត៌មានលំអិតសូមមើល Scott, James C., 1972; "Patron-Client Politics and Political Change in Southeast Asia" in *The American Political Science Review*, 66: 91-113
៦. ដោយមានជំនួយពី GTZ (Gesellschaft für Technische Zusammenarbeit) មានសមាគមឥណទានកើនយ៉ាងលឿននៅ ស្ទោង ហើយនៅឆ្នាំ១៩៩៧ មានការសំរេចបោះឆ្នោតជ្រើសរើសគណៈកម្មការសំរបសំរួលតែកំរិតស្រុកមួយ (PACOCO) ដើម្បីតំណាងសមាគមនានាចំពោះមុខអ្នកផ្ដល់ជំនួយ និងស្ថាប័នអ្នកក្រៅ ។

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្រៅប្រទេស

## កំណើនសេដ្ឋកិច្ចពិភពលោក

នៅត្រីមាសទីមួយ ២០០៥ សេដ្ឋកិច្ចពិភពលោកមានលទ្ធផលចំរុះគឺថា សេដ្ឋកិច្ច US បន្តកើនឡើង រីឯសេដ្ឋកិច្ចតំបន់អឺរ៉ូ និងជប៉ុន កើនតែបន្តិច ។

ផសស ពិត US មានកំនើន ៣,៥% ក្នុងរយៈមួយឆ្នាំដល់ចុងត្រីមាសទីមួយ ។ កត្តាជំរុញចំបង១នៃកំណើន ផសស ពិត គឺចំណាយប្រើប្រាស់បុគ្គល (PCE), វិនិយោគស្តុកទំនិញឯកជន, ការនាំចេញ, វិនិយោគជាលំនៅដ្ឋាន, គ្រឿងបរិក្ខារ និងសូហ្វវែរ ។ កំនើននេះទាបជាងវាក៏រិត ៣,៨% នៅត្រីមាសទីបួន ២០០៤ ដោយសារការថយកំណើននៃចំណាយប្រើប្រាស់បុគ្គល, ចំណាយលើបរិក្ខារ និងសូហ្វវែរ ។ ប៉ុន្តែការថយចុះនេះត្រូវបានប៉ះប៉ូវវិញដោយកំណើនការនាំចេញ, វិនិយោគជាស្តុកទំនិញឯកជន និងវិនិយោគជាលំនៅដ្ឋាន ព្រមទាំងការថយកំនើនការនាំចូល ។

នៅត្រីមាសទីមួយ ២០០៥ ផសស ពិត នៅតំបន់អឺរ៉ូ កើន ១,៤% បើធៀបនឹងកាលពីមួយឆ្នាំមុន និងកើន ០,៥% បើធៀបនឹងត្រីមាសទីបួន ២០០៤ ។ កំណើនយឺតនេះ គឺដោយសារតំរូវការក្នុងស្រុកមានកំនើនខ្សោយ, កំនើនខ្លាំងនៃថ្លៃប្រេងឆៅ និងការឡើងថ្លៃប្រាក់អឺរ៉ូទល់នឹងដុល្លារUS ដែលកាត់បន្ថយសកម្មភាពនាំចេញផ្នែកឧស្សាហកម្មរបស់អឺរ៉ុប ។ ផសស ពិត ជប៉ុនកើន ១,៣% បើធៀបនឹងកាលពីមួយឆ្នាំមុន និងកើន ០,៨% បើធៀបនឹងត្រីមាសទីបួន ២០០៤ ដោយសារចំណាយប្រើប្រាស់ដែលកើនខ្លាំងដល់ ១,២% បើធៀបនឹងត្រីមាសមុន និងវិនិយោគជាមូលធនខាងអាជីវកម្មដែលកើន ២,០% ។

នៅត្រីមាសទីមួយ ២០០៥ ផសស ពិតរបស់ចិន កើនយ៉ាងខ្លាំងដល់ ៩,៥% បើធៀបនឹងកាលពីមួយឆ្នាំមុន ដោយសារកំណើនយ៉ាងលឿននៃផលិតផលឧស្សាហកម្ម វិនិយោគ និងការនាំចេញ ។ ក្នុងពេលដដែល ផសស ពិត កូរ៉េខាងត្បូង កើន ២,៧% បើធៀបនឹងកាលពីមួយឆ្នាំមុន និង ៣,៣% បើធៀបនឹងត្រីមាសមុន ។ កំណើនខ្សោយនេះ បណ្តាលមកពីកំណើនថេរនៃការនាំចេញ និងចំណាយប្រើប្រាស់ឯកជន និងការថយចុះវិនិយោគផ្នែកសាងសង់ ។ ផសស ពិត ហុងកុងមានកំណើន ៦,០% នៅត្រីមាសទីមួយ ២០០៥ និងកំនើន ៧,២% នៅត្រីមាសទីបួន ២០០៤ ។

ផសស ពិត ម៉ាឡេស៊ីមានកំណើនប្រចាំឆ្នាំ ៥,៧% នៅត្រីមាសទីមួយ ២០០៥ ធៀបនឹងកំណើន ៥,៦% នៅត្រីមាសទីបួន ២០០៤ ។ កំណើននេះជំរុញដោយវិស័យចំបង១ទាំងអស់នៃសេដ្ឋកិច្ចលើកលែងតែវិស័យសំណង់ ។ នៅត្រីមាសទីមួយ ២០០៥ ផសស ពិតរបស់ សិង្ហបុរី និងថៃ មានកំណើនប្រចាំឆ្នាំ ២,៥% និង ៣,៤%រៀងគ្នា ដោយថយក៏រិត ៦,៥% និង ៥,០% នៅត្រីមាសទីបួន ២០០៤ ។ នៅថៃ ផលប៉ះពាល់នៃរលកយក្សស៊ូណាមិ, ការរាំងស្ងួត និងថ្លៃប្រេងខ្ពស់ ប្រហែលនឹងធ្វើអោយធ្លាក់ចុះកំនើនសេដ្ឋកិច្ច ។

## អតិផរណាក្នុងពិភពលោក និងអត្រាប្តូរប្រាក់នៅទីផ្សារអន្តរជាតិ

នៅត្រីមាសទីមួយ ២០០៥ ភាពធូរស្រាលឡើងវិញក្នុងទីផ្សារប្រេងឆៅពិភពលោក គឺជាកត្តាជារួមមួយ ដែលជួយទប់អតិផរណានៅក្នុងប្រទេសមានសេដ្ឋកិច្ចចំបង១ក្នុងពិភពលោក ។ ថ្លៃទំនិញប្រើប្រាស់មានកំណើន ៣% នៅUS -០,២% នៅជប៉ុន និង ២,១%នៅតំបន់អឺរ៉ូ គឺថយចុះពីកំណើន ៣,២%, ០,៥% និង ២,៣% រៀងគ្នា នៅត្រីមាសទី៤ ២០០៤ ។ នៅតាមប្រទេសអាស៊ីនានា អតិផរណាសឹងតែនៅថេរ ។ នៅត្រីមាសទីមួយ ២០០៥ កូរ៉េខាងត្បូង និងសិង្ហបុរី មានអតិផរណា ៣,២% និង ០,៤%រៀងគ្នា ដោយថយចុះពីកំរិត ៣,៤% និង ១,៧% នៅត្រីមាសមុន ។

នៅទីផ្សារប្តូរប្រាក់ពិភពលោក នៅត្រីមាសទីមួយ ២០០៥ ដុល្លារUS ធ្លាក់ថ្លៃទល់នឹងរូបិយវត្ថុភាគច្រើន ដែលអាចបណ្តាលជាសំខាន់ពីកំណើនអត្រាគ្មានការងារធ្វើនៅ US, កំណើនឱនភាពពាណិជ្ជកម្មUS និងការបារម្ភពីរឿងធនាគារកណ្តាលជាច្រើនអាចយករូបិយវត្ថុផ្សេងក្រៅពីដុល្លារUS មកធ្វើជារូបិយប័ណ្ណបំរុងទុករបស់ខ្លួន ។ ទល់នឹងប្រាក់យ៉េនជប៉ុន មួយដុល្លារUS ប្តូរបាន ១០៤,៧យ៉េន គឺចុះពីកំរិត ១០៥,៩យ៉េនកាលពីត្រីមាសទីបួន ២០០៤ ។ ទល់នឹងប្រាក់អឺរ៉ូ មួយដុល្លារUS ប្តូរបាន ០,៧៦អឺរ៉ូ រឺធ្លាក់ថ្លៃបន្តិចពីកំរិត ០,៧៧អឺរ៉ូនៅត្រីមាសមុន ។

## ថ្លៃទំនិញប្រើប្រាស់នៅទីផ្សារពិភពលោក

នៅត្រីមាសទីមួយ ២០០៥ ថ្លៃទំនិញជ្រើសរើសសំខាន់១ នៅលើទីផ្សារពិភពលោកបានឡើងយ៉ាងខ្លាំង ។ អង្ករថៃ ១០០% B ធុនលេខពីរ នៅទីផ្សារបាងកក លក់ថ្លៃ ២៩៥,៦០ដុល្លារ/តោន គឺឡើងថ្លៃ ១១% ធៀបនឹងត្រីមាសមុន រឺ ២៨% បើធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន ។ នៅត្រីមាសទីមួយ ២០០៥ ពោតឡើងថ្លៃបន្តិចបាន ៩៧ដុល្លារ/តោន ប៉ុន្តែចុះថ្លៃយ៉ាងខ្លាំងអស់ ២១%

**តារាង១. កំនើន ផសស ពិត នៃដៃគូពាណិជ្ជកម្មជ្រើសរើសពីឆ្នាំ២០០០-២០០៥ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន)**

| | 2000 | 2001 | 2002 | 2003 | 2004 | | | | 2005 | 2004 |
|---|---|---|---|---|---|---|---|---|---|---|
| | | | | Q4 | Q1 | Q2 | Q3 | Q4 | Q1 | |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | |
| កម្ពុជា | 7.3 | 6.7 | 4.8 | - | - | - | - | - | - | |
| ឥណ្ឌូនេស៊ី | 4.4 | 3.8 | 3.8 | 4.3 | 4.5 | 4.3 | 5.0 | 6.6 | 6.4 | 5.1 |
| ម៉ាឡេស៊ី | 8.7 | 0.5 | 5.6 | 6.4 | 7.6 | 8.0 | 6.8 | 5.6 | 5.7 | 7 |
| សិង្ហបុរី | 9.5 | -2.3 | 2.6 | 3.7 | 7.5 | 12.5 | 7.5 | 6.5 | 2.5 | 8.5 |
| ថៃ | 4.4 | 1.9 | 6.1 | 7.8 | 6.5 | 6.3 | 6.0 | 5.0 | 3.3 | 6 |
| វៀតណាម | | 6.0 | 6.7 | - | - | - | - | - | - | - |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | |
| ចិន | 8.0 | 7.5 | 8.1 | 9.9 | 9.7 | 9.6 | 9.1 | 9.5 | 9.5 | 9.5 |
| ហុងកុង | 10.2 | 0.5 | 5.0 | 4.9 | 6.8 | 12.1 | 7.2 | 7.1 | 6 | 8.3 |
| កូរ៉េខាងត្បូង | 9.1 | 3.0 | 6.1 | 3.9 | 5.3 | 5.5 | 4.6 | 3.3 | 2.7 | 4.7 |
| តៃវ៉ាន់ | 5.8 | -2.2 | 4.2 | 5.4 | 6.3 | 7.7 | 5.3 | 3.3 | 2.5 | 5.7 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | |
| អឺរ៉ុប-១២ | 3.5 | 1.4 | 0.7 | 0.6 | 1.5 | 2.2 | 1.9 | 1.6 | 1.4 | 1.8 |
| ជប៉ុន | 2.8 | 0.4 | 0.4 | 3.1 | 5.6 | 4.4 | 2.6 | 0.8 | 1.3 | 3.4 |
| សហរដ្ឋអាមេរិក | 5.0 | 1.2 | 2.4 | 4.3 | 5.0 | 4.7 | 3.9 | 3.8 | 3.5 | 4.4 |

*Source: The Economist, Country's National Statistics offices and Central Banks, and ADB's Asia Regional Information Center*

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្រៅប្រទេស

បើធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន ។ សណ្តែកសៀងលក់បាន ២២៩,៩ ដុល្លារ/តោន គឺឡើងថ្លៃ ៦% ធៀបនឹងត្រីមាសទីបួន ២០០៤ ប៉ុន្តែចុះថ្លៃអស់ ៣១% បើធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន ។ នៅត្រីមាសទីមួយ ២០០៥ ថ្លៃប្រេងឆៅ និងសាំងឡើងខ្លាំងដល់ ២០% និង ៨% រៀងគ្នា បើធៀបនឹងត្រីមាសមុន ។ ប្រេងឆៅលក់បាន ៤២,៦០ដុល្លារ/ធុង ហើយប្រេងសាំងលក់បាន ៣៤,៤សេន/លីត្រ ។

*រៀបរៀងដោយ ហ៊ីង វុត្ថា និង ភឹម រុនស៊ីណារិទ្ធិ*

**តារាង២. អត្រាអតិផរណានៃដៃគូពាណិជ្ជកម្មជ្រើសរើសពីឆ្នាំ២០០០-២០០៥ ( កំណើនជាភាគរយធៀបនឹងឆ្នាំមុន-មធ្យមភាគតាមការិយបរិច្ឆេទ)**

| | 2000 | 2001 | 2002 | 2003 | | | | 2004 | 2005 | 2004 |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | |
| កម្ពុជា | -0.8 | -0.6 | 3.2 | 1.2 | 0.7 | 2.2 | 6.5 | 6.1 | 5.8 | 4.0 |
| ឥណ្ឌូនេស៊ី | 3.6 | 11.5 | 13.2 | 8.3 | 6.6 | 8.8 | 9.2 | 8.6 | 10.7 | 8.3 |
| ម៉ាឡេស៊ី | 1.5 | 1.4 | 1.8 | 1.1 | 1.0 | 1.2 | 1.5 | 2.4 | 2.5 | 1.6 |
| សិង្ហបុរី | 1.4 | 1.0 | -0.4 | 0.5 | 1.4 | 1.9 | 1.7 | 1.7 | 0.4 | 1.7 |
| ថៃ | 1.5 | 1.7 | 0.6 | 1.8 | 1.9 | 2.6 | 3.3 | 3.1 | 2.8 | 2.7 |
| វៀតណាម | -1.7 | -0.4 | 3.8 | 3.2 | 4.6 | 7.6 | 10.3 | 10.7 | - | 8.3 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | |
| ចិន | 0.3 | 0.9 | -0.7 | 1.2 | 2.8 | 4.4 | 5.2 | 3.2 | 2.8 | 3.9 |
| ហុងកុង | -3.6 | -1.3 | -3.0 | -2.6 | -1.9 | -0.8 | 0.8 | 0.2 | 0.4 | -0.4 |
| កូរ៉េខាងត្បូង | 2.3 | 4.4 | 2.7 | 3.5 | 2.7 | 3.3 | 4.4 | 3.4 | 3.2 | 3.5 |
| តៃវ៉ាន់ | 1.3 | -0.01 | -0.2 | -0.3 | 0.5 | 1.2 | 2.9 | 1.9 | 1.6 | 1.6 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | |
| អឺរ៉ុប-១២ | 2.3 | 2.6 | 2.2 | 2.1 | 1.8 | 2.3 | 2.3 | 2.3 | 2.1 | 2.2 |
| ជប៉ុន | -0.7 | -0.6 | -0.9 | -0.3 | -0.1 | -0.3 | -0.1 | 0.5 | -0.2 | Nil |
| សហរដ្ឋអាមេរិក | 3.3 | 2.8 | 1.6 | 2.3 | 1.8 | 2.9 | 2.7 | 3.3 | 3.0 | 2.7 |

*Source: The International Monetary Fund, the Economist and the National Institute of Statistics*

**តារាង៣. អត្រាប្តូរប្រាក់ធៀបនឹងដុល្លារនៃរូបិយវត្ថុរបស់ដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០០-២០០៥ ( មធ្យមភាគតាមការិយបរិច្ឆេទ)**

| | 2000 | 2001 | 2002 | 2003 | | | | 2004 | 2005 | 2004 |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | |
| កម្ពុជា ( រៀល) | 3,840.8 | 3,916.3 | 3,912.1 | 3,973 | 3,990.3 | 4,005.3 | 4,034.7 | 4,034.7 | 4,027.0 | 4,016.3 |
| ឥណ្ឌូនេស៊ី ( រូពីយ៉ា) | 8,421 | 10,261 | 9,311 | 8,577 | 8,469 | 9,001 | 9,156 | 9,128 | 9,274 | 8,938 |
| ម៉ាឡេស៊ី ( រីងហ្គីត) | 3.80 | 3.80 | 3.80 | 3.80 | 3.80 | 3.80 | 3.80 | 3.80 | 3.80 | 3.80 |
| សិង្ហបុរី ( ដុល្លារសិង្ហបុរី) | 1.72 | 1.79 | 1.79 | 1.74 | 1.69 | 1.70 | 1.70 | 1.65 | 1.63 | 1.69 |
| ថៃ ( បាត) | 40.1 | 44.4 | 42.9 | 41.5 | 39.1 | 40.2 | 41.3 | 40.3 | 38.6 | 40.2 |
| វៀតណាម ( ដុង) | 14,168 | 14,725 | 15,280 | 15,510 | 15,717 | 15,735 | 16,262 | - | - | - |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | |
| ចិន ( យ៉ន់) | 8.28 | 8.28 | 8.28 | 8.28 | 8.28 | 8.28 | 8.28 | 8.28 | 8.28 | 8.28 |
| ហុងកុង ( ដុល្លារហុងកុង) | 7.80 | 7.80 | 7.80 | 7.78 | 7.77 | 7.80 | 7.80 | 7.78 | 7.80 | 7.79 |
| កូរ៉េខាងត្បូង ( វ៉ុន) | 1,131 | 1,291 | 1,251 | 1,192 | 1,171 | 1,162 | 1,155 | 1,093 | 1,022 | 1,145 |
| តៃវ៉ាន់ ( ដុល្លារតៃវ៉ាន់-NT$) | 31.2 | 33.8 | 34.5 | 34.4 | 33.3 | 33.3 | 33.9 | 32.9 | 31.5 | 33.6 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | |
| អឺរ៉ុប-១២ ( អឺរ៉ូ) | 1.09 | 1.12 | 1.06 | 0.89 | 0.80 | 0.83 | 0.82 | 0.77 | 0.76 | 0.80 |
| ជប៉ុន ( យ៉េន) | 107.8 | 121.5 | 125.4 | 115.9 | 107.2 | 109.7 | 109.9 | 105.9 | 104.7 | 108.2 |

*Source: The International Monetary Fund and The Economist and National Bank of Cambodia*

**តារាង៤. ថ្លៃផលិតផលជ្រើសរើសនៅលើទីផ្សារពិភពលោក ពីឆ្នាំ២០០០-២០០៥ ( មធ្យមភាគតាមការិយបរិច្ឆេទ)**

| | 2000 | 2001 | 2002 | 2003 | 2004 | | | | 2005 | 2004 |
|---|---|---|---|---|---|---|---|---|---|---|
| | | | Q4 | Q4 | Q1 | Q2 | Q3 | Q4 | Q1 | |
| ឈើមូលប្រភេទរឹង - ម៉ាឡេស៊ី ($/ម៣) | 88.4 | 89.5 | 108.3 | 108.3 | 122.6 | 128.8 | 102.3 | 94.4 | 97 | 122 |
| ឈើអារប្រភេទរឹង - ម៉ាឡេស៊ី ($/ម៣) | 310.2 | 285.7 | 428.3 | 199.3 | 527 | 497 | 432.3 | 429 | 413.3 | 471.3 |
| កៅស៊ូ - ម៉ាឡេស៊ី ($/តោន) | 720.8 | 602.0 | 834.1 | 1,261.4 | 1,246.4 | 1,333.4 | 1,190.6 | 1238.2 | - | 1252.2 |
| អង្ករ - បាងកក ($/តោន) | 206.7 | 177.3 | 192.2 | 198.7 | 231.4 | 240.7 | 240.5 | 264.9 | 295.6 | 244.4 |
| សណ្តែកសៀង - សហរដ្ឋអាមេរិក ($/តោន) | 193 | 180.7 | 220 | 290.2 | 331.7 | 356.4 | 251.1 | 216.5 | 229.9 | 288.9 |
| ប្រេងឆៅ-ឌូបៃ ($/ធុង) | 26.1 | 22.8 | 26.2 | 27 | 29.3 | 33.3 | 36.09 | 35.5 | 42.6 | 33.5 |
| មាស - London ($/troy ounce) | 21.1 | 19.5 | 19 | 22.2 | 27.4 | 32.1 | 32.1 | 31.8 | 34.4 | 30.9 |

*Source: Food and Agriculture Organization (FAO) and Energy Information Administration*

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្នុងប្រទេស

ដោយមានការគាំទ្រយ៉ាងខ្លាំងពីអ្នកផ្តល់ជំនួយនានា រាជរដ្ឋាភិបាលកម្ពុជាបានព្យាយាមជំរុញប្រភពថ្មីៗនៃកំណើន ដើម្បីធានាអោយមានកំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រជាបន្តទៀតក្រោយពីការលុបរបបកូតាក្នុងវិស័យកាត់ដេរ ។ នៅដើមខែមិថុនា ២០០៥ ធនាគារពិភពលោកបានផ្តល់អំណោយហិរញ្ញវត្ថុចំនួន ១០លានដុល្លារ ជាបន្ថែមលើធនធានរដ្ឋាភិបាលកម្ពុជាចំនួន ០,៣៣លានដុល្លារ ដើម្បីអនុវត្ត "គំរោងស្តីពីការសំរួលពាណិជ្ជកម្ម និងភាពប្រកួតប្រជែងនៅកម្ពុជា" ។ យោងតាមឯកសារចេញផ្សាយថ្មីរបស់ធនាគារពិភពលោក គំរោងនេះមានគោលដៅណែនាំឱ្យមានតម្លាភាពក្នុងដំណើរការវិនិយោគ មានជាអាទិ៍ សម្បទានខាងហេដ្ឋារចនាសម្ព័ន្ធ ព្រមទាំងជួយសំរបសំរួលអោយសហគ្រាសរកបានទីផ្សារនាំចេញ ដោយផ្តោតលើ ៤ផ្នែក គឺ ១) ការសំរបសំរួលខាងពាណិជ្ជកម្ម ២) មូលនិធិស្វែងរកទីផ្សារនាំចេញ (EMAF) ៣) ការចូលរួមរបស់វិស័យឯកជនក្នុងការលើកស្ទួយហេដ្ឋារចនាសម្ព័ន្ធ និងវិនិយោគ និង ៤) សមាសភាគតម្លាភាពផ្នែកច្បាប់ ។

នៅថ្ងៃទី២១ មិថុនា ២០០៥ គណៈកម្មការអឺរ៉ុបបានសន្យាផ្តល់ជំនួយជិតដល់ ៦៦លានដុល្លារឱ្យកម្ពុជា ដើម្បីអភិវឌ្ឍន៍ធនធានទឹក និងលើកកំពស់កំរិតជីវភាពប្រជាជនដែលរស់នៅតាមជនបទក្នុងខេត្តបន្ទាយមានជ័យ បាត់ដំបង និងសៀមរាប ព្រមទាំងជួយទ្រទ្រង់ដល់ការអភិវឌ្ឍន៍ខាងសង្គមកិច្ច និងជួយកែលំអអភិបាលកិច្ច ។

## សកម្មភាពសេដ្ឋកិច្ចសំខាន់ៗ

នៅត្រីមាសទីមួយ ២០០៥ លទ្ធផលសេដ្ឋកិច្ចកម្ពុជាបានបង្ហាញសញ្ញាវិជ្ជមានមួយចំនួនទាក់ទិននឹងវិនិយោគឯកជន ដែលភាគច្រើនជាវិនិយោគក្នុងវិស័យឧស្សាហកម្ម សំណង់ និងទេសចរណ៍ ។ ចំពោះពាណិជ្ជកម្មក្រៅប្រទេសវិញ វាមានឱនភាពខ្លាំងជាងនៅត្រីមាសមុន ។

ទ្រព្យសកម្មជាប់លាប់បានចុះបញ្ជីរបស់គំរោងវិនិយោគឯកជន ដែលត្រូវបានអនុម័តដោយ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា កើនឡើងយ៉ាងខ្លាំងនៅត្រីមាសទីមួយ ២០០៥ ដល់ ៤៧៥,៣លានដុល្លារពីកំរិត ១៦,៤លានដុល្លារនៅត្រីមាសទីបួន ២០០៤ ។ ដោយឡែកវិនិយោគខាងឧស្សាហកម្មមាន ៨៨% (៤១៨,៨ លានដុល្លារ) ក្នុងនេះ វិនិយោគចិនខាងរោងចក្រចំរាញ់ប្រេងកាត មាន ២០០,៩លានដុល្លារ និងខាងរុករករ៉ែដែក និងរោងចក្រដែកថែប មាន ១៥៤លានដុល្លារ ។ វិនិយោគក្នុងវិស័យកាត់ដេរ កើនដល់ ៤៥ លានដុល្លារនៅត្រីមាសទីមួយ ធៀបនឹង ១២,៧លានដុល្លារនៅត្រីមាសមុន ។ យោងតាមក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បើសិនជាគំរោងវិនិយោគខាងឧស្សាហកម្មបានអនុម័តហើយទាំងនេះត្រូវបានអនុវត្តជាក់ស្តែង វាអាចផ្តល់ការងារសំរាប់មនុស្ស ៤១,២១៨នាក់ ។ ម្យ៉ាងទៀត វិនិយោគឯកជនក្នុងវិស័យសេវាកម្ម និងកសិកម្ម កើនពីសូន្យនៅត្រីមាសទីបួន ២០០៤ ដល់ ៥៣,៣លានដុល្លារ និង ៣,២លានដុល្លាររៀងគ្នា នៅត្រីមាសទីមួយ ២០០៥ ។ ធៀបនឹងត្រីមាសទីមួយ ២០០៤ វិនិយោគឯកជនសរុបដែលបានអនុម័ត កើនពី ៦៣,៣លានដុល្លារ ដល់ ៤៧៥,៣លានដុល្លារ ។ ប៉ុន្តែវិនិយោគក្នុងវិស័យកាត់ដេរធ្លាក់ចុះអស់ ១០% ពី ៥០លានដុល្លារ មកត្រឹម ៤៥លានដុល្លារ ខណៈដែលវិនិយោគក្នុងវិស័យឯទៀត បានកើនឡើងព្រមៗគ្នា ។

តំលៃគំរោងសាងសង់បានអនុម័តនៅភ្នំពេញកើនយ៉ាងខ្លាំង នៅត្រីមាសទីបួន ២០០៤ និងត្រីមាសទីមួយ ២០០៥ ដោយកើនបាន ៦៥,៥% ដល់ ១០៦,១លានដុល្លារនៅត្រីមាសទីមួយ ។ ក្នុងនេះ ការសាងសង់ភូមិគ្រឹះ/ផ្ទះកើនពី ៥,៥លានដុល្លារ ដល់ ១៤,៣លានដុល្លារ រីឯការសាងសង់ផ្ទះល្វែងកើនពី ៤៦,៣លានដុល្លារ ដល់ ៤៨,៦លានដុល្លារ ។ ម្យ៉ាងទៀត សំណង់ផ្សេងៗដូចជា រោងចក្រ, ឃ្លាំងកើនខ្លាំងដែរពី ១២,៤លានដុល្លារ នៅត្រីមាសទីបួន ២០០៤ ដល់ ៤៣,១លានដុល្លារនៅត្រីមាសទីមួយ ២០០៥ ។ ធៀបនឹងត្រីមាសទីមួយ ២០០៤ តំលៃគំរោងសាងសង់បានអនុម័តសរុបនៅភ្នំពេញ កើន ៤៥,៥% ពីកំរិត ៧២,៩លានដុល្លារ ។

វិស័យទេសចរណ៍កម្ពុជា រីកដុះដាលល្អបានបីត្រីមាសជាប់ៗគ្នា ប៉ុន្តែចំនួនភ្ញៀវបរទេសមកដល់នៅត្រីមាសទីមួយ ២០០៥ កើនយឺតជាងមុនបានត្រឹម ០,៥% (ដល់ ៣៨០.៥៥៩នាក់) ធៀបនឹងកំណើន ៦៦% នៅត្រីមាសទីបួន ២០០៤ និងកំណើន ១៧,៧%នៅត្រីមាសទីបី ២០០៤ ។ ពីត្រីមាសទីបួន ២០០៤ ដល់ត្រីមាសទីមួយ ២០០៥ ចំនួនភ្ញៀវមកដល់តាមយន្តហោះកើន ១៥% (ដល់ ២៣១.៧៣៦នាក់) ដោយវាបានជួយប៉ះប៉ូវដល់ការធ្លាក់ចុះ ១៦% (មកត្រឹម ១៤៨.៨៦៣នាក់) នៃចំនួនភ្ញៀវចូលតាមផ្លូវគោកនិងផ្លូវទឹក ដែលមានបូកបញ្ចូលទាំងភ្ញៀវមកទស្សនាប្រាសាទព្រះវិហារផង (២៦.២៦៣នាក់) ។ ក្នុងចំណោមភ្ញៀវចូលមកកម្ពុជា ភ្ញៀវមកពីកូរ៉េនៅតែមានច្រើនជាងគេ មានចំនួន ៥៨.៣៨៤នាក់នៅត្រីមាសទីមួយ ២០០៥ បន្ទាប់មកគឺ ជប៉ុន (៣៧.៦២២នាក់) សហរដ្ឋអាមេរិក (៣១.១៣៨នាក់) អង់គ្លេស (២១.៤១៨នាក់) និងបារាំង (២០.៧៥៣នាក់) ។

បើធៀបនឹងត្រីមាសទីមួយ ២០០៤ ចំនួនភ្ញៀវសរុបកើន ៤៥,៦% ពីកំរិត ២៥៤.៤៣៧នាក់ ដោយគេឃើញមានកំណើនទាំងភ្ញៀវចូលតាមយន្តហោះ (៤៦,៧% ពីកំរិត ១៥៧.៩៣៨នាក់) និងភ្ញៀវចូលតាមផ្លូវគោក និងផ្លូវទឹក (៥៤,៣% ពីកំរិត ៩៦.៤៩៩ នាក់) ។

ឱនភាពពាណិជ្ជកម្មក្រៅប្រទេសរបស់កម្ពុជា កើនឡើងពីត្រីមាសទីបួន ២០០៤ ដល់ ត្រីមាសទីមួយ ២០០៥ ។ ឱនភាពមានទំហំ ៥៨ពាន់លានរៀលនៅត្រីមាសទីមួយ ដោយកើនពីកំរិត ៣,៤ពាន់លានរៀលនៅត្រីមាសទីបួន ២០០៤។ ក្នុងកំឡុងពេលនេះ ថ្វីបើការនាំចូលវាថយចុះ ប៉ុន្តែការនាំចេញបានថយចុះខ្លាំងជាងទៀតអស់ដល់ ១៥% មកត្រឹម ៤៦៣លានដុល្លារនៅត្រីមាសទីមួយ ២០០៥ ពីកំរិត ៥៤៥លានដុល្លារនៅត្រីមាសទីបួន ២០០៤ ។ ការនាំចេញសំលៀកបំពាក់ដែលនៅតែតំណាងឱ្យជាង ៩០% នៃការនាំចេញសរុប ធ្លាក់ចុះអស់ ១៤,៥% គឺស្រដៀងនឹងកំឡុងពេលដូចគ្នានៅឆ្នាំមុន ។ ម្យ៉ាងទៀត ការនាំចេញកៅស៊ូ ដែលមានចំណែកធំជាងគេលំដាប់ទីពីរ ក្នុងការនាំចេញសរុប បានថយចុះ ៣៩% មកត្រឹម ៧,៣លានដុល្លារ រីឯការ នាំចេញត្រី ក៏ថយចុះ ៦៦% ដែរ មកត្រឹម ១,៥លានដុល្លារ ។ ប៉ុន្តែនៅត្រី មាសទីមួយ ២០០៥ នេះ ការនាំចេញសរុបរបស់កម្ពុជានៅតែខ្ពស់ជាងកាលពី ត្រីមាសទីមួយឆ្នាំមុន ដល់ទៅ ១៦% ។

នៅត្រីមាសទីមួយ ២០០៥ ការនាំចូលសរុបមាន ៥២០,៩លានដុល្លារ រឺ ៥%ទាបជាងត្រីមាសមុន ។ ក្នុងនេះ តំលៃនៃការនាំចូលម្ហូបអាហារ ភេសជ្ជៈ និងថ្នាំជក់ ថយចុះ ២៦% មកត្រឹម ៣៦,៨លានដុល្លារ ហើយការនាំចូលសំលៀកបំពាក់ និងស្បែកជើង (រួមទាំងក្រណាត់) ថយចុះ ២៣,៥% មកត្រឹម ១៥០,១លានដុល្លារ រីឯការនាំចូលម៉ាស៊ីនម៉ាស៊ូត និងម៉ាស៊ីនភ្លើងថយចុះអស់ ៨% មកត្រឹម ២១,៦លានដុល្លារ ។ យោងតាមទីចាត់ការគយនិងរដ្ឋាករ ការនាំចូលសរុបរបស់កម្ពុជាកើន ១៣,៥% បើធៀបនឹងត្រីមាសដូចគ្នា ឆ្នាំ២០០៤ ។

# តាមដានសេដ្ឋកិច្ច _ ស្ថានភាពក្នុងប្រទេស

## ហិរញ្ញវត្ថុសាធារណៈ

នៅត្រីមាសទីមួយ ២០០៥ ឱនភាពថវិកាទូទៅ គិតលើមូលដ្ឋានសាច់ប្រាក់ (រួមទាំង ការកែតំរូវចំណាយ) មាន ១៣៣,៤ពាន់លានរៀល រឺថយចុះ ៤៦% ពីកំរិត ២៤៧,១ពាន់លានរៀលនៅត្រីមាសមុន និងថយចុះ ៧,៥% ពីកំរិត ១៤៤,២ពាន់លានរៀលនៅត្រីមាសដូចគ្នាឆ្នាំមុន ។ ចំណូលក្នុងស្រុកសរុបមាន ៥៥១,៤ពាន់លានរៀលនៅត្រីមាសទីមួយ ២០០៥ រឺកើន ៥,២% បើធៀបនឹងត្រីមាសដូចគ្នា ឆ្នាំ២០០៤ ។ កំណើនចំណូលថវិកានេះ ពាក់ព័ន្ធជាសំខាន់នឹងកំណើនចំណូលពន្ធ (កើន ១១% ដល់ ៤៥៥ពាន់លានរៀល) ដែលត្រូវបានកាត់កងចុះវិញខ្លះដោយសារការធ្លាក់ចុះចំណូលមិនមែនពន្ធ (ចុះ ១៥,៦% មកត្រឹម ៩៦,២ពាន់លានរៀល) និងចំណូលជាមូលធន (ចុះ ៤៦% មកត្រឹម ០,៣ពាន់លានរៀល) ។

នៅត្រីមាសទីមួយ ២០០៥ ចំណាយថវិកាសរុបកើនដល់ ៦៨៤,៨ពាន់លានរៀល រឺ ២,៥% ខ្ពស់ជាងត្រីមាសដូចគ្នាឆ្នាំមុន ។ ក្នុងនេះ ចំណាយរបស់ក្រសួងអាទិភាពទាំងបួន មានតែ ៨,១% (៥៥,៥ពាន់លានរៀល) ប៉ុណ្ណោះ រឺត្រូវជា ៦០,៧% ខ្ពស់ជាងកាលពីត្រីមាសទីមួយ ២០០៤ ។ នៅក្នុងចំណាយរបស់ក្រសួងអាទិភាពទាំងបួននេះ ៣៧,៧% ជាចំណាយរបស់ក្រសួងសុខាភិបាល (កើនឡើងប្រហែលមួយជាបួន ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន) ៥៦,៩%ជាចំនាយរបស់ក្រសួងអប់រំ យុវជន និងកីឡា (កើន ២០,៦%), ២% ជារបស់ក្រសួងអភិវឌ្ឍន៍ជនបទ (កើន ១៦,៧%), និង ៣,៤% ជារបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (កើន ១៥,៥%) ។

## អតិផរណា និងអត្រាប្តូរប្រាក់

នៅត្រីមាសទីមួយ ២០០៥ ថ្លៃទំនិញប្រើប្រាស់នៅភ្នំពេញ កើនឡើងបន្តិចត្រឹម ០,២៥% ក្រោយពីបានធ្លាក់ចុះអស់ ០,៨% នៅត្រីមាសមុន ។ រឿងនេះបណ្តាលពីការឡើងថ្លៃ សំលៀកបំពាក់និងស្បែកជើង សំភារៈសំរាប់ថែទាំនិងជួសជុលផ្ទះ និងសៀវភៅនិងសំភារៈសិក្សាផ្សេងៗ ។ ប៉ុន្តែ បើធៀបនឹងត្រីមាសទីមួយ ២០០៤ ថ្លៃទំនិញប្រើប្រាស់នៅភ្នំពេញកើនឡើង ៥,៦% ដោយសារទំនិញប្រើប្រាស់ និងសេវាភាគច្រើន បានឡើងថ្លៃក្នុងរយៈពេលនេះ ។

នៅត្រីមាសទីមួយ ២០០៥ ប្រាក់រៀលឡើងថ្លៃបន្តិចទល់នឹងប្រាក់ដុល្លារ និងប្រាក់ដុងវៀតណាម ប៉ុន្តែបន្តធ្លាក់ថ្លៃទល់នឹងប្រាក់បាតថៃ បើធៀបនឹងត្រីមាសមុន ។ ប្រាក់រៀលប្តូរបាន ៤.០២៧រៀល/ដុល្លារ និង ២៥,១រៀល/១០០ដុង នៅត្រីមាសទីមួយ ២០០៥ ធៀបនឹង ៤.០៣៤,៧រៀល/ដុល្លារ និង ២៥,៣រៀល/១០០ដុងនៅត្រីមាសមុន ។ នៅត្រីមាសទីមួយនេះដែរ ប្រាក់រៀលប្តូរបាន ១០៤,៤រៀល/បាត រឺចុះថ្លៃ ៤,៣% ធៀបនឹងត្រីមាសមុន ។ បើធៀបនឹងត្រីមាសទីមួយ ២០០៤ ប្រាក់រៀលបានចុះថ្លៃអស់ ០,៩% ទល់នឹងដុល្លារ, និងចុះ ២,៤% ទល់នឹងប្រាក់បាត ប៉ុន្តែឡើងថ្លៃបន្តិចបាន ១,២% ទល់នឹងប្រាក់ដុងវៀតណាម ។

## ការវិវត្តន៍រូបិយវត្ថុ

នៅឆ្នាំ២០០៥ ធនាគារជាតិនៃកម្ពុជា មានគំរោងបង្កើនរូបិយវត្ថុទូទៅអោយបាន ១០% និងរៀលនៅក្រៅធនាគារអោយបាន ១៨% យោងតាមរបាយការណ៍ប្រចាំឆ្នាំរបស់ធនាគារជាតិ ។

ពីចុងត្រីមាសទីបួន ២០០៤ ដល់ចុងត្រីមាសទីមួយ ២០០៥ រូបិយវត្ថុទូទៅកើនប្រហែល ៤% ដល់ ៤.៤៥៨ពាន់លានរៀល ក្នុងនេះ ១.៣០៧,៤ពាន់លានរៀល គឺជាប្រាក់រៀល (ទាំងនៅក្នុង និងនៅក្រៅធនាគារ) ឯចំនួននៅសល់ ៣.១៥០,៨ពាន់លានរៀល (៧៩១,៦លានដុល្លារ) គឺជាប្រាក់បញ្ញើជារូបិយវត្ថុបរទេស ។ ប្រាក់រៀលកើនបាន ៤,៦% ក្នុងនេះ ប្រាក់រៀលនៅក្រៅធនាគារកើន ៤,៤% ដល់ ១.១៦៣,៨ពាន់លានរៀល និងប្រាក់បញ្ញើជារៀលនៅធនាគារ កើន ៦% ដល់ ១៤៣,៦ពាន់លានរៀល ។ ម្យ៉ាងទៀត ប្រាក់បញ្ញើជារូបិយវត្ថុបរទេសកើន ៣,៦% ។

ចំពោះទ្រព្យសកម្មសុទ្ធក្នុងប្រព័ន្ធធនាគារ ទ្រព្យសកម្មបរទេសសុទ្ធកើនបាន ៨៦,៥ពាន់លានរៀល (កំណើន ១,៨%) ពីចុងត្រីមាសទីបួន ២០០៤ ដល់ចុងត្រីមាសទីមួយ ២០០៥ ។ នៅពេលជាមួយគ្នា ទ្រព្យសកម្មក្នុងស្រុកសុទ្ធ កើនបាន ៨២,៥ពាន់លានរៀល (កំណើន ១៧,៦%) ដោយសារជាសំខាន់ ឥណទានក្នុងស្រុកសំរាប់វិស័យឯកជន ដែលកើន ៩,២% និងឥណទេយ្យសុទ្ធលើរដ្ឋាភិបាលដែលថយចុះអស់ ២០,៩% ។

បើធៀបនឹងត្រីមាសទីមួយ ២០០៤ រូបិយវត្ថុទូទៅ កើនបាន ២៣% ។ ក្នុងកំឡុងពេលដដែល ទ្រព្យសកម្មបរទេសសុទ្ធ កើន ១៤,៥% ឯទ្រព្យសកម្មក្នុងស្រុកសុទ្ធកើន ៣៦,៥% ។

## ស្ថានភាពក្រីក្រ _ ប្រាក់ចំនូលប្រចាំថ្ងៃពិតរបស់ពលករងាយរងគ្រោះ (អង្កេតថ្ងៃទី ០២_២០ ឧសភា ២០០៥)

អង្កេតលើពលករងាយរងគ្រោះ ធ្វើដោយ វិបសអ ពីថ្ងៃទី០២-២០ ឧសភា ២០០៥ បានបង្ហាញពីការធ្លាក់ចុះប្រាក់ចំនូលប្រចាំថ្ងៃពិតរបស់អ្នកធាក់ស៊ីក្លូ អ្នកលីសែង អ្នកស៊ីឈ្នួលធ្វើស្រែ និងកម្មកររោងចក្រកាត់ដេរ បើធៀបនឹងកំឡុងពេលដូចគ្នាឆ្នាំមុន ។ កម្មករកាត់ដេរ មានចំនូលធ្លាក់ចុះខ្លាំងជាងគេ បន្ទាប់មកគឺ អ្នកលីសែង និងអ្នកស៊ីឈ្នួលធ្វើស្រែ ។ ក្នុងពេលជាមួយគ្នា អ្នករត់ម៉ូតូឌុបមានកំណើនចំនូលច្រើនជាងគេ ទោះបីប្រេងឥន្ធនៈឡើងថ្លៃដល់កំរិតខ្ពស់មិនដែលជួបក៏ដោយ ។

យោងតាមលទ្ធផលអង្កេត ចំនូលប្រចាំថ្ងៃពិតរបស់កម្មកររោងចក្រកាត់ដេរធ្លាក់ចុះ ២២% មកត្រឹម ៧.២០០រៀល នៅខែឧសភា ២០០៥ ដែលជាតួលេខទាបបំផុតគិតតាំងពី វិបសអ ចាប់ផ្តើមធ្វើអង្កេតក្នុងវិស័យនេះមក ។ រឿងនេះអាចមកពីមានរោងចក្រកាត់ដេរមួយចំនួន បានបិទទ្វារជាបណ្តោះអាសន្ន រឺជាអចិន្ត្រៃយ៍ ។ ម្យ៉ាងទៀត ម្ចាស់រោងចក្របានផ្លាស់ប្តូរពីការជួលកម្មករគ្មានជំនាញមកជួលកម្មករមានជំនាញខ្ពស់ជាងមុន ។ រឿងនេះនាំអោយចំនូលប្រចាំថ្ងៃពិតរបស់កម្មករកាត់ដេរធ្លាក់ចុះ ពីព្រោះកម្មករមានជំនាញភាគច្រើនត្រូវបានជួលក្នុងលក្ខខណ្ឌដូចគ្នានឹងកម្មករបណ្តោះអាសន្ន ហើយទទួលបានប្រាក់កំរៃប្រហែល ៣៣% ទាបជាងកម្មករអចិន្ត្រៃយ៍ ។ ការសិក្សាមួយធ្វើដោយ វិបសអ នៅឆ្នាំ២០០១ បង្ហាញថា កម្មករកាត់ដេរប្រហែល ៥០% បានបង់ប្រាក់ដើម្បីបានការងារធ្វើ, ឯនៅឆ្នាំ២០០៤ និង ២០០៥ អត្រានេះមានកំរិតតែ ១១% និង ៦,៧% ប៉ុណ្ណោះ ។ លើសពីនេះ ការថយចុះចំនួនម៉ោងធ្វើការរបស់កម្មករ (បូកបញ្ចូលទាំងម៉ោងបន្ថែម) គឺជាមូលហេតុមួយចំណែកទៀតនៃការធ្លាក់ចុះចំនូលប្រចាំថ្ងៃពិតរបស់កម្មករ ។ យោងតាមទិន្នន័យអង្កេតចំនួនម៉ោងធ្វើការជាមធ្យមរបស់កម្មករកាត់ដេរធ្លាក់ចុះពី ៦០ម៉ោង/សប្តាហ៍នៅឆ្នាំ២០០៣ មកត្រឹម ៥៧ម៉ោង/សប្តាហ៍នៅឆ្នាំ២០០៤ និង ៥៥ម៉ោង/សប្តាហ៍ក្នុងកំឡុងពេលធ្វើអង្កេត ។

នៅខែឧសភា ២០០៥ ចំនូលប្រចាំថ្ងៃពិតរបស់អ្នករត់ម៉ូតូឌុបកើន ៣៤%

ខ្ពស់ជាងកាលពីមួយឆ្នាំមុន ដល់ ១១.៤០០រៀល នៅចំពេលដែលថ្លៃសាំងស្ទុះឡើងយ៉ាងខ្លាំង ប៉ុន្តែវាធ្លាក់ចុះអស់ ៣% បើធៀបនឹងអង្កេតមុន ។ រឿងនេះអាចមកពីកំណើនចំនួនអ្នកទេសចរនៅក្នុងក្រុងភ្នំពេញ ។ ថ្វីបើចំនួលប្រចាំថ្ងៃពិតឡើងដល់ ១១.៤០០រៀល ដូច្នេះក្តី ប៉ុន្តែមានអ្នករត់ម៉ូតូឌុប ៩៥% បានបញ្ជាក់ថា វាមិនគ្រប់គ្រាន់សំរាប់ផ្គត់ផ្គង់គ្រួសារទេ ដោយសារការឡើងថ្លៃទំនិញប្រើប្រាស់ ។

នៅខែឧសភា ២០០៥ ចំនួលប្រចាំថ្ងៃពិតរបស់អ្នកធាក់ស៊ីក្លូ និងកម្មករលីសែងធ្លាក់ចុះ ៣,៤% និង ៥,៣%រៀងគ្នា បើធៀបនឹងខែឧសភា ២០០៤ ។ ចំនួលប្រចាំថ្ងៃពិតរបស់អ្នកធាក់ស៊ីក្លូ គឺ ៧.៧០០រៀល ដោយវាធ្លាក់ចុះពីកំរិត ៨.០០០រៀលកាលពីមួយឆ្នាំមុន និងថយចុះ ៩% បើធៀបនឹងខែកុម្ភៈ ២០០៥ ។ ក្នុងនេះ អ្នកធាក់ស៊ីក្លូ ៨៥% ត្អូញត្អែរថា ចំនួនអ្នកធាក់ស៊ីក្លូបានកើនឡើងដែលធ្វើឱ្យចំណូលធ្លាក់ចុះ ។ ចំពោះអ្នកលីសែង ចំនួលប្រចាំថ្ងៃពិត ធ្លាក់ចុះដល់ ៧.១០០រៀល ពីកំរិត ៧.៥០០រៀល កាលពីមួយឆ្នាំមុន ប៉ុន្តែវាកើន ២% បើធៀបនឹងខែកុម្ភៈ ២០០៥ ទោះបីអ្នកលីសែង ៧៧% បានកត់សំគាល់ថា ចំនួនអ្នកលីសែងបានកើនឡើងកំឡុងបីខែកន្លងមកនេះក្តី ។ យោងតាមអង្កេតនៅខែឧសភា ២០០៥ ជាទូទៅ អ្នកធាក់ស៊ីក្លូ និងកម្មករលីសែង ធ្វើការនៅភ្នំពេញតែ ៧ខែក្នុងមួយឆ្នាំ និងប្រហែល ២០ ថ្ងៃក្នុងមួយខែ ។

នៅខែឧសភា ២០០៥ ចំនួលប្រចាំថ្ងៃពិតរបស់អ្នករើសអេតចាយកើនដល់ ៥.៣០០រៀល រីកំនើន ២០% ខ្ពស់ជាងខែដូចគ្នាមួយឆ្នាំមុន និងជាកំនើនធំបំផុតលំដាប់ទីពីរគិតតាំងពីឆ្នាំ១៩៩៨ មក ។ រឿងនេះប្រហែលបណ្តាលពីការឡើងថ្លៃអីវ៉ាន់អេតចាយ និងការថយចុះចំនួនអ្នករើសអេតចាយ ។ម្យ៉ាងទៀត មានអ្នករើសអេតចាយជាង ៨០% បានឆ្លើយសំភាសន៍ប្រាប់ថា អីវ៉ាន់អេតចាយបានឡើងថ្លៃ បើធៀបនឹងបីខែកន្លងមក ។ ក្នុងកំឡុងពេលធ្វើអង្កេត អ្នករើសអេតចាយចំណាយជាមធ្យម ២.១០០រៀល/ថ្ងៃ ដែលខ្ពស់បន្តិចជាងបន្ទាត់ក្រីក្រកំនត់ជាថ្មីគឺ ១.៧១២រៀល សំរាប់តំបន់ទីក្រុង ដែលផ្សព្វផ្សាយដោយកម្មវិធីស្បៀងអាហារពិភពលោក និងក្រសួងផែនការនៅឆ្នាំ២០០២[១] ។ ប៉ុន្តែចំនាយមធ្យមប្រចាំថ្ងៃរបស់អ្នករើសអេតចាយនៅខែឧសភា ២០០៥ នេះ គឺជាចំនាយទាបបំផុតក្នុងចំនោមពលករងាយរងគ្រោះទាំងអស់នៅភ្នំពេញ[២] ។

នៅខែឧសភា ២០០៥ ចំនួលប្រចាំថ្ងៃពិតរបស់កម្មករសំណង់គ្មានជំនាញកើន ២៤%ដល់ ៨.៧៥០រៀលពីកំរិត ៦.០៩៥រៀល នៅខែឧសភា ២០០៤ ។ ក្នុងពេលជាមួយគ្នា ចំនួលប្រចាំថ្ងៃពិតរបស់កម្មករសំណង់មានជំនាញ កើនបន្តិចបាន ៤% បើធៀបនឹងខែឧសភា ២០០៤ ។ រឿងនេះ អាចមកពីកំណើនតំរូវការទាំងកម្មករសំណង់គ្មានជំនាញ និងមានជំនាញ ដោយសារការរីកដុះដាលវិស័យសាងសង់ ។ តបនឹងសំនួរក្នុងអង្កេត ពួកគេបានឆ្លើយប្រាប់ថា អាចរកចំណូលបានច្រើនជាងឆ្នាំមុនពីព្រោះមានការងារធ្វើច្រើនជាង ។

### កំណត់សំគាល់

១. នៅភ្នំពេញ បន្ទាត់ក្រីក្រផ្សព្វផ្សាយដោយកម្មវិធីស្បៀងអាហារពិភពលោក និងក្រសួងផែនការនៅឆ្នាំ២០០២ គឺ ១.៦២៩រៀល ហើយក្រោយមកគេបានកំនត់វាឡើងវិញដល់ ១.៧១២រៀល ដោយសារអតិផរណាបានកើន ៥,០៤% ពីឆ្នាំ២០០២-២០០៤ ។

២. ចំណាយជាមធ្យមរបស់អ្នកបំរើតាមភោជនីយដ្ឋាន គឺ ៩០០រៀល/ថ្ងៃ នៅខែឧសភា ២០០៥ ។ ប៉ុន្តែតួលេខនេះមិនតំណាងឱ្យចំនួលទាំងមូលទេ ពីព្រោះអាហារមួយភាគធំរបស់ពួកគេ គឺផ្តល់ឱ្យដោយម្ចាស់ហាង ។

*រៀបរៀងដោយ អ៊ូច ច័ន្ទតារាទី និង ប៊ុន ដូរីណា*

---

*តពីទំព័រទី ២៤* **ពត៌មានពី...**

ក្រុមសេដ្ឋកិច្ចកំពុងធ្វើឯកសារគោលសំរាប់ បណ្តាញវិភាគអភិវឌ្ឍន៍ (DAN 5) ដែលនឹងផ្តោតលើផលប៉ះពាល់ខាងសេដ្ឋកិច្ចពីចិន ទៅលើប្រទេសជាដៃគូក្នុងបណ្តាញ DAN ។ កិច្ចប្រជុំពិគ្រោះយោបល់លើកទីមួយពី DAN 5 នឹងធ្វើនៅពាក់កណ្តាលខែតុលា ដោយមានវិទ្យាស្ថានស្រាវជ្រាវនៅគុនមីង (ចិន) ជាសមាជិកថ្មី ។ ក្នុងពេលជាមួយគ្នា ការសិក្សាស្តីពីតំរូវការកសាងសមត្ថភាពខាងពាណិជ្ជកម្មនៃវិទ្យាស្ថានស្រាវជ្រាវនានានៅតំបន់អាស៊ី-ប៉ាស៊ីហ្វិក ត្រូវបានបញ្ចប់ ហើយការសិក្សាមួយថ្មីពីផលប៉ះពាល់នៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ចិន ទៅលើវិស័យកសិកម្មនៅកម្ពុជាបានចាប់ផ្តើមឡើង ។ វបសអ បានចូលរួមក្នុងការសិក្សាជាលក្ខណៈតំបន់មួយទៀតដែលពិនិត្យពីផលប៉ះពាល់នៃសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់លើភាពក្រីក្រ ។

ការសិក្សាធំៗពីរទៀតដែលបានចុះផ្សាយក្នុងទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជាលេខមុនៗរួចហើយ គឺមានការចេញឱ្យផុតពីភាពក្រីក្រ និងការវាយតំលៃពីភាពក្រីក្រដោយមានការចូលរួមនៅទន្លេសាប ។ ចំពោះការសិក្សាទីមួយ ការងារវិភាគបានជឿនលឿនទៅមុខ ហើយលទ្ធផលជាដំបូងៗត្រូវបានចែកចាយទៅអោយភាគីពាក់ព័ន្ធនានា ។ សំរាប់ការសិក្សាទីពីរ គឺកំពុងបូកសរុបដំណាក់កាលទីមួយនៃការធ្វើអង្កេតដល់ទីកន្លែង ក្រោយពីបានបញ្ចប់ការវាយតំលៃពីភាពក្រីក្រក្នុងភូមិទាំង ២៣ រួចហើយ ។ ក្រុមបរិស្ថាននៃ វបសអ បានកើនកំលាំងឡើងវិញ ដោយមានទីប្រឹក្សាបច្ចេកទេសម្នាក់ថ្មីបានមកដល់ ។ សព្វថ្ងៃមានការងារផ្តួចផ្តើមថ្មីសំខាន់ៗមួយចំនួនកំពុងដំណើរការ :

- ការសិក្សាពីការប្រើប្រាស់ និងតំលៃនៃអនុផលព្រៃឈើ
- ការធ្វើផែនការយុទ្ធសាស្រ្តរយៈ ៥ឆ្នាំ នៃការស្រាវជ្រាវខាងបរិស្ថាន និងធនធានធម្មជាតិ
- ការកសាងសំណើមួយសំរាប់ការសិក្សាពីធនធានទឹក ទំនាស់ និងអភិបាលកិច្ច
- វបសអ និងកម្មវិធីខាងសេដ្ឋកិច្ច និងបរិស្ថានសំរាប់អាស៊ីអគ្នេយ៍ (EEPSEA) កំពុងរៀបចំធ្វើសិក្ខាសាលាមួយចំនួនស្តីពីបញ្ហាជាប់ទាក់ទិននឹងសេដ្ឋកិច្ចនៃធនធានធម្មជាតិ
- ការសិក្សាអំពីការវាយតំលៃមូលដ្ឋានទិន្នន័យនៃការកាន់កាប់ដីធ្លី បានចាប់ផ្តើមហើយ (ការចុះអង្កេតដល់កន្លែងបានចប់សព្វគ្រប់ ហើយសេចក្តីព្រាងរបាយការណ៍បានដាក់ជូនអង្គការ FAO រួចជាស្រេច)
- អង្កេតជាមូលដ្ឋានលើការផ្តល់កម្មសិទ្ធិដីធ្លី (សំរាប់ដំណាក់កាលទីក្រុង) កំពុងដំណើរការ ។

ម្យ៉ាងទៀត កិច្ចសហការជាដៃគូជាមួយស្ថាប័នដ៏សំខាន់ៗមួយចំនួន ត្រូវបានរៀបចំហើយ រឺកំពុងពិភាក្សាគ្នា ដូចជា ជាមួយសាកលវិទ្យាល័យស៊ីដនី សាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងមជ្ឈមណ្ឌលដាណឺម៉ាកខាងព្រៃឈើនិងទេសភាព ។

ទំនាក់ទំនងជាដៃគូខាងស្ថាប័នដ៏សំខាន់ បានដំណើរការទៅមុខ/កំពុងត្រូវបានពិភាក្សាយ៉ាងខ្លាំងក្លា ដូចជា ជាមួយសាកលវិទ្យាល័យស៊ីដនី, សាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងមជ្ឈមណ្ឌលដាណឺម៉ាកនៃព្រៃឈើ និងទេសភាព ។

## តារាង១. គំរោងវិនិយោគឯកជនដែលបានអនុម័ត ឆ្នាំ១៩៩៧-២០០៥

| | 1997* | 1998 | 1999 | 2000 | 2001 | 2002 | 2003 | 2004 Q1 | Q2 | Q3 | Q4 | 2005 Q1 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ទ្រព្យសកម្មជាប់លាប់ (លានដុល្លារ) | | | | | | | | | | | |
| កសិកម្ម | 65.6 | 51.6 | 63.9 | 9.8 | 5.6 | 38.9 | 3.7 | 0.0 | 9.4 | 2.9 | 0.0 | 3.2 |
| ឧស្សាហកម្ម | 512.4 | 650.5 | 162.6 | 109.4 | 99.8 | 57.4 | 142.6 | 53.8 | 28.0 | 72.7 | 16.4 | 418.8 |
| កាត់ដេរ | *97.0* | *126.5* | *67.7* | *35.2* | *23.0* | *18.0* | *74.8* | *49.9* | *10.1* | *44.0* | *12.7* | *44.9* |
| សេវាកម្ម | 166.5 | 154.7 | 222.6 | 150.0 | 111.4 | 143.3 | 167.7 | 9.5 | 75.9 | 6.4 | 0.0 | 53.3 |
| សណ្ឋាគារ និងទេសចរណ៍ | *41.5* | *112.0* | *171.8* | *79.8* | *71.9* | *45.1* | *118.6* | *0.0* | *49.5* | *6.4* | *0.0* | *46.4* |
| សរុប | 744.5 | 856.8 | 449.1 | 269.2 | 216.8 | 239.6 | 314.1 | 63.3 | 113.3 | 82.0 | 16.4 | 475.3 |
| | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | - | - | 1.9 | 79.0 | -27.6 | -80.0 | - |
| | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | - | 15.0 | -47.6 | -40.0 | -19.5 | 10.5 | 31.1 | -41.6 | 134.6 | -13.8 | -73.6 | - |

*Source: Cambodian Investment Board. *1997 exclude expansion project approvals.*

## តារាង២. តំលៃគំរោងសំណង់នៅភ្នំពេញដែលបានអនុម័ត ឆ្នាំ១៩៩៧-២០០៥

| | 1997 | 1998 | 1999 | 2000 | 2001 | 2002 | 2003 | 2004 Q1 | Q2 | Q3 | Q4 | 2005 Q1 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | លានដុល្លារ | | | | | | | | | | | |
| ភូមិគ្រឹះ, ផ្ទះ | 17.2 | 21.2 | 20.0 | 16.4 | 15.9 | 23.4 | 20.0 | 8.1 | 9.3 | 7.5 | 5.5 | 14.3 |
| ផ្ទះល្វែង | 19.3 | 227.3 | 290.5 | 174.8 | 167.8 | 179.9 | 91.6 | 48.5 | 28.5 | 44.3 | 46.3 | 48.6 |
| ផ្សេងៗ | 221.2 | 27.0 | 16.4 | 14.2 | 12.6 | 16.6 | 87.3 | 16.3 | 10.8 | 26.1 | 12.4 | 43.1 |
| សរុប | 257.7 | 275.4 | 326.8 | 205.4 | 196.2 | 219.8 | 198.9 | 72.9 | 48.6 | 77.9 | 64.1 | 106.1 |
| | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | - | - | 46.3 | -33.4 | 60.3 | -17.7 | 65.5 |
| | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | - | 6.9 | 18.7 | -37.2 | -4.5 | 12.0 | -9.5 | 103.4 | -23.4 | 56.4 | 28.6 | 45.5 |

*Source: Department of Cadastre and Geography of the Municipality of Phnom Penh*

## តារាង៣. ការនាំចេញ និងនាំចូល ឆ្នាំ១៩៩៧-២០០៥

| | 1997 | 1998 | 1999 | 2000 | 2001 | 2002 | 2003 | 2004 Q1 | Q2 | Q3 | Q4 | 2005 Q1 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | លានដុល្លារ | | | | | | | | | | | |
| ការនាំចេញសរុប | 493.4 | 784.4 | 941.1 | 1,056.2 | 1,268.2 | 1,453.2 | 1,708.1 | 399.5 | 494.7 | 668.8 | 545.1 | 463.0 |
| រួមមានៈ - សំលៀកបំពាក់ | 227.2 | 378.0 | 554.0 | 962.1 | 1,202.2 | 1,355.8 | 1,628.4 | 383.6 | 479.4 | 643.7 | 520.3 | 444.9 |
| - ទៅសហរដ្ឋអាមេរិក | *107.2* | *74.1* | *486.0* | *714.1* | *840.9* | *943.4* | *1,099.8* | *255.8* | *306.3* | *387.6* | *321.2* | *312.5* |
| - ទៅសហគមន៍អ៊ឺរ៉ុប | - | - | - | *228.1* | *323.3* | *356.3* | *414.7* | *95.0* | *135.7* | *200.9* | *159.1* | *89.2* |
| - ប្រទេសផ្សេងទៀត | *120.0* | *82.0* | *68.0* | *19.9* | *38.0* | *56.1* | *113.8* | *32.7* | *37.3* | *55.2* | *40.0* | *43.1* |
| - កសិកម្ម | - | - | - | 94.2 | 66.0 | 97.3 | 79.7 | 16.0 | 15.3 | 25.1 | 24.8 | 18.1 |
| - កៅស៊ូ | - | - | - | *29.6* | *25.9* | *29.7* | *35.1* | *8.0* | *6.6* | *11.6* | *12.0* | *7.3* |
| - ឈើ | - | - | - | *32.9* | *22.3* | *16.0* | *10.2* | *1.8* | *2.8* | *4.2* | *2.4* | *3.3* |
| - ជលផល | - | - | - | *5.4* | *6.0* | *4.3* | *2.8* | *0.8* | *1.2* | *4.3* | *4.4* | *1.5* |
| - ផ្សេងៗ | - | - | - | *26.2* | *11.8* | *47.4* | *31.6* | *5.4* | *4.8* | *5.0* | *6.0* | *6.0* |
| ការនាំចូលសរុប | 1,094.5 | 1,112.2 | 1,237.4 | 1,417.7 | 1,501.4 | 1,674.1 | 1,824.9 | 458.8 | 607.0 | 528.2 | 548.5 | 520.9 |
| រួមមានៈ - សាំង | - | - | - | - | - | 26.0 | 33.2 | 7.1 | 8.6 | 6.6 | 7.8 | 10.3 |
| - ម៉ាស៊ូត | - | - | - | - | - | 102.0 | 109.6 | 30.4 | 27.7 | 27.4 | 23.6 | 21.6 |
| - សំភារៈសំណង់ | - | - | - | - | - | 97.4 | 80.8 | 20.2 | 27.0 | 21.3 | 26.5 | 32.3 |
| - ផ្សេងៗ | - | - | - | - | - | 1,448.7 | 1,601.3 | 401.1 | 543.6 | 472.9 | 490.6 | 456.7 |
| ជញ្ជីងពាណិជ្ជកម្ម | -601.2 | -327.8 | -296.3 | -361.5 | -233.2 | -220.9 | -116.8 | -59.3 | -112.3 | 140.6 | -3.4 | -58.0 |
| | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| ការនាំចេញសំលៀកបំពាក់សរុប | - | - | - | - | - | - | - | -14.5 | 25.0 | 34.3 | -19.2 | -14.5 |
| ការនាំចេញសរុប | - | - | - | - | - | - | - | -16.0 | 23.8 | 35.2 | -18.5 | -15.1 |
| ការនាំចូលសរុប | - | - | - | - | - | - | - | -5.9 | 32.3 | -13.0 | 3.8 | -5.0 |
| | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| ការនាំចេញសំលៀកបំពាក់សរុប | 188.0 | 66.4 | 47.0 | 74.0 | 24.9 | 12.8 | 20.1 | 21.9 | 22.9 | 35.4 | 16.0 | 16.0 |
| ការនាំចេញសរុប | 27.5 | 59.0 | 20.0 | 12.2 | 20.1 | 14.6 | 17.5 | 20.5 | 21.1 | 35.9 | 14.6 | 15.9 |
| ការនាំចូលសរុប | -1.8 | 1.6 | 11.3 | 14.6 | 5.9 | 11.5 | 9.0 | 16.5 | 19.6 | 21.1 | 12.5 | 13.5 |

## តារាង៤. ចំនួនអ្នកដំណើរមកដល់ក្នុងប្រទេសកម្ពុជា ឆ្នាំ១៩៩៧-២០០៥

| | 1997 | 1998 | 1999 | 2000 | 2001 | 2002 | 2003 | 2004 Q1 | Q2 | Q3 | Q4 | 2005 Q1 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | អ្នកដំណើរពាន់នាក់ | | | | | | | | | | | |
| តាមផ្លូវអាកាស | - | 186.3 | 262.9 | 351.7 | 408.4 | 523.0 | 456.0 | 157.9 | 122.8 | 143.9 | 201.5 | 231.7 |
| តាមផ្លូវគោក និងទឹក | - | 100.2 | 104.8 | 114.7 | 196.5 | 263.5 | 245.0 | 96.5 | 71.0 | 84.2 | 177.3 | 148.9 |
| សរុប | 218.8 | 286.5 | 367.7 | 466.4 | 604.9 | 786.5 | 701.0 | 254.4 | 193.8 | 228.1 | 378.8 | 380.6 |
| | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | - | - | 14.2 | -23.8 | 17.7 | 66.1 | 0.5 |
| | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | -16.0 | 30.9 | 28.3 | 26.8 | 29.7 | 30.0 | -10.9 | 21.8 | 74.5 | 44.0 | 70.1 | 49.6 |

*ប្រភពៈ ក្រសួងទេសចរណ៍ ។ តារាង ៣ ប្រភពៈ ក្រសួងពាណិជ្ជកម្ម និងនាយកដ្ឋានគយ និងរដ្ឋាករ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។*

## តារាង៥. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (CPI) អត្រាប្ដូរប្រាក់ និងថ្លៃមាស ឆ្នាំ១៩៩៧-២០០៥ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 1997 | 1998 | 1999 | 2000 | 2001 | 2002 | 2003 | 2004 Q1 | Q2 | Q3 | Q4 | 2005 Q1 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន) | | | | | | | | | | | |
| ខេត្ត | - | - | 5.8 | 5.4 | -0.1 | 0.9 | 4.4 | 4.6 | 7.9 | 22.1 | 23.0 | 20.7 |
| ភ្នំពេញ - ទំនិញគ្រប់ប្រភេទ | 8.0 | 14.8 | 4.0 | -0.8 | -0.6 | 3.3 | 1.2 | 0.8 | 2.2 | 6.7 | 5.8 | 5.6 |
| - ម្ហូបអាហារ | 6.7 | 14.1 | 7.6 | -3.3 | -2.8 | 1.8 | 1.5 | 0.6 | 3.4 | 12.2 | 9.1 | 7.9 |
| - ថាមពល | 20.0 | 15.1 | 3.5 | 6.6 | -1.1 | 0.3 | 4.9 | 4.8 | 8.1 | 11.5 | 14.5 | 12.3 |
| | អត្រាប្ដូរប្រាក់ ថ្លៃមាស ថ្លៃប្រេងឥន្ធនៈ (តាមអត្រាទីផ្សារនៅភ្នំពេញ) | | | | | | | | | | | |
| រៀលក្នុង ១ ដុល្លារ | - | - | - | 3,840.8 | 3,916.3 | 3,912.1 | 3,973.3 | 3,990.3 | 4,005.3 | 4,034.7 | 4,034.7 | 4,027 |
| រៀលក្នុង ១ បាតថៃ | - | - | - | 95.8 | 88.2 | 91.1 | 95.8 | 102.0 | 99.6 | 97.7 | 100.1 | 104.4 |
| រៀលក្នុង ១០០ ដុងវៀតណាម | - | - | - | 27.1 | 26.6 | 25.6 | 25.6 | 25.4 | 25.4 | 24.8 | 25.3 | 25.1 |
| ថ្លៃមាស (ដុល្លារក្នុង១ជី) | 46.3 | 40.4 | 36.0 | 34.0 | 33.3 | 32.7 | 36.8 | 44.4 | 46.0 | 46.0 | 46.3 | 47.0 |
| ថ្លៃម៉ាស៊ូត (រៀល/លីត្រ) | 779 | 883 | 1,065 | 1,105 | 1,329 | 1,521 | 1,508 | 1,700 | 1,867 | 1,983 | 2,150 | 2,350 |
| ថ្លៃសាំង (រៀល/លីត្រ) | 1,118 | 1,378 | 1,613 | 1,760 | 2,113 | 2,084 | 2,150 | 2,400 | 2,567 | 2,767 | 2,950 | 3,050 |

## តារាង៦. ស្ថានភាពរូបិយវត្ថុ ឆ្នាំ១៩៩៧-២០០៥ (តួលេខនៅចុងការិយបរិច្ឆេទ)

| | 1997 | 1998 | 1999 | 2000 | 2001 | 2002 | 2003 | 2004 Q1 | Q2 | Q3 | Q4 | 2005 Q1 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ពាន់លានរៀល | | | | | | | | | | | |
| ទ្រព្យសកម្មបរទេសសុទ្ធ | 1,177 | 1,726 | 2,019 | 2,589 | 3,080 | 3,737 | 4,027 | 4,265 | 4,337 | 4,524 | 4,797 | 4,883 |
| ទ្រព្យសកម្មក្នុងស្រុកសុទ្ធ | -114 | -496 | -576 | -759 | -876 | -849 | -698 | -606 | -493 | -354 | -467 | -385 |
| ឥណទេយ្យសុទ្ធលើរដ្ឋាភិបាល | 54 | 178 | 103 | 3 | -75 | -119 | -128 | -133 | -130 | -96 | -209 | -252 |
| ឥណទានចំពោះផ្នែកឯកជន | 637 | 655 | 763 | 898 | 936 | 1,059 | 1,337 | 1,389 | 1,499 | 1,673 | 1,817 | 1,983 |
| រូបិយវត្ថុទូទៅ M2 | 1,063 | 1,230 | 1,443 | 1,831 | 2,204 | 2,888 | 3,328 | 3,659 | 3,844 | 4,169 | 4,329 | 4,498 |
| រូបិយវត្ថុ M1 | 385 | 543 | 531 | 540 | 609 | 813 | 937 | 1,007 | 1,040 | 1,078 | 1,153 | 1,198 |
| រូបិយវត្ថុផ្សេងៗ | 678 | 687 | 911 | 1,291 | 1,594 | 2,075 | 2,391 | 2,652 | 2,804 | 3,091 | 3,176 | 3,300 |
| | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| រូបិយវត្ថុទូទៅ M2 | 16.6 | 15.7 | 17.3 | 26.9 | 20.4 | 31.0 | 15.2 | 21.8 | 30.2 | 38.7 | 30.0 | 22.9 |
| រូបិយវត្ថុ M1 | 17 | 41 | -2.2 | 1.7 | 12.8 | 33.5 | 15.3 | 21.5 | 17.4 | 21.7 | 23.0 | 19.0 |
| រូបិយវត្ថុផ្សេងៗ | 16.3 | 1.3 | 32.6 | 41.7 | 23.5 | 30.2 | 15.2 | 21.9 | 36.7 | 45.8 | 32.8 | 20.3 |

## តារាង៧. ប្រតិបត្តិការថវិកាជាតិលើមូលដ្ឋានជាសាច់ប្រាក់ ឆ្នាំ១៩៩៧-២០០៥ (ពាន់លានរៀល)

| | 1997 | 1998 | 1999 | 2000 | 2001 | 2002 | 2003 | 2004 Q1 | Q2 | Q3 | Q4 | 2005 Q1 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ចំណូលសរុប | 880 | 920 | 1326 | 1,528 | 1,529 | 1,744 | 1,765 | 523.9 | 488.5 | 452.1 | 662.2 | 551.4 |
| ចំណូលចរន្ត | - | - | - | - | 1,521 | 1,728 | 1,733 | 523.3 | 475.5 | 450.8 | 657.7 | 551.0 |
| ចំណូលពន្ធ | 596 | 676 | 956 | 1,096 | 1,096 | 1,227 | 1,220 | 409.3 | 348.4 | 334.1 | 485.7 | 454.9 |
| ពន្ធគយ | 348 | 376 | 432 | 376 | 376 | 424 | 395 | 137.0 | 108.4 | 99.9 | 168.0 | 129.1 |
| ចំណូលមិនមែនពន្ធ | 272 | 204 | 348 | 424 | 424 | 501 | 513 | 113.9 | 127.1 | 116.7 | 172.1 | 96.2 |
| អាជីវកម្មព្រៃឈើ | 36 | 20 | 36 | 28 | 29 | 15 | 7.0 | 0.9 | 0.3 | 0.2 | 0.5 | 1.3 |
| ប្រៃសណីយ៍ និងទូរគមនាគមន៍ | 84 | 88 | 108 | 124 | 122 | 123 | 120 | 16.1 | 23.1 | 28.8 | 26.3 | 21.9 |
| ចំណូលជាមូលធន | 12 | 36 | 12 | 8 | 9 | 16 | 31 | 0.6 | 13.0 | 1.3 | 4.5 | 0.3 |
| ចំណាយសរុប | 1,260 | 1,296 | 1,792 | 2,332 | 2,332 | 2,948 | 2,757 | 668.1 | 710.6 | 703.4 | 909.3 | 684.8 |
| ចំណាយជាមូលធន | 452 | 368 | 624 | 976 | 977 | 1,388 | 1,171 | 316.6 | 337.1 | 277.3 | 293.5 | 205.3 |
| ចំណាយចរន្ត | 808 | 980 | 1,164 | 1,356 | 1,355 | 1,560 | 1,586 | 351.5 | 373.4 | 426.0 | 615.8 | 479.5 |
| អប់រំ និងសុខាភិបាល | 128 | 132 | 280 | 344 | 343 | 454 | 473 | 31.4 | 80.6 | 116.0 | 290.0 | 52.5 |
| ការពារជាតិ និងសន្តិសុខ | 420 | 448 | 464 | 404 | 405 | 438 | 411 | 67.6 | 66.0 | 91.5 | 197.8 | 74.9 |
| ក្រសួងផ្សេងៗទៀត | 260 | 332 | 412 | 636 | 637 | 668 | 702 | 252.6 | 226.8 | 218.6 | 130.6 | 352.1 |
| ឱនភាពជាទូទៅ | -380 | -380 | -476 | -804 | -803 | -1,204 | -992 | -144.2 | -222.0 | -251.2 | -247.1 | -133.4 |
| ហិរញ្ញប្បទានពីក្រៅប្រទេស | 444 | 268 | 416 | 768 | 766 | 1,249 | 886 | 231.2 | 238.5 | 216.6 | 238.7 | 28.0 |
| ហិរញ្ញប្បទានក្នុងស្រុក | -64 | 112 | 60 | 36 | 37 | -45 | 106 | -87.0 | -16.5 | 34.6 | 8.4 | 105.4 |

## តារាង៨. ចំណូលប្រចាំថ្ងៃជាមធ្យមរបស់ពលករងាយរងគ្រោះ ឆ្នាំ១៩៩៧-២០០៤

| | ចំណូលប្រចាំថ្ងៃ (ជារៀល) | | | | | | | | | បំរែបំរួលធៀបនឹងឆ្នាំមុន (%) | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | 1998 | 2000 | 2003 | 2004 | | | | 2005 | | 2004 | 2005 | |
| | កុម្ភៈ | វិច្ឆិកា | វិច្ឆិកា | ៤-កុម្ភៈ | ៤-ឧសភា | សីហា | វិច្ឆិកា | កុម្ភៈ | ឧសភា | វិច្ឆិកា | កុម្ភៈ | ឧសភា |
| អ្នកធាក់ស៊ីក្លូ | 10,063 | 7,594 | 9,494 | 9,153 | 8,000 | 7,631 | 5,670 | 8,529 | 7,722 | -40.30% | -6.80% | -3.4 |
| អ្នកលីសែង | 7,636 | 6,233 | 6,286 | 8,383 | 7,451 | 6,625 | 5,121 | 6,933 | 7,056 | -18.50% | -17.30% | -5.3 |
| អ្នកលក់បន្លែតូចតាច | 5,695 | 5,256 | 6,480 | 7,130 | 7,240 | 6,650 | 6,767 | 6,385 | 8,574 | 4.40% | -10.40% | 18.4 |
| អ្នករើសអេតចាយ | 3,776 | 2,718 | 3,772 | 4,625 | 4,368 | 4,769 | 4,024 | 5,382 | 5,270 | 6.70% | 16.40% | 20.6 |
| អ្នកបំរើតាមភោជនីយដ្ឋាន* | - | 2,111 | 4,289 | 4,721 | 4,273 | 4,591 | 4,207 | 4,470 | 4,287 | -1.90% | -5.30% | 0.3 |
| អ្នកស៊ីឈ្នួលធ្វើស្រែ | - | 4,198 | 4,947 | 5,190 | 4,038 | 3,628 | 3,788 | 3,997 | 3,822 | -23.40% | -23.00% | -5.3 |
| កម្មកររោងចក្រកាត់ដេរ | - | 6,701 | 9,671 | 9,322 | 9,249 | 9,211 | 9,328 | 9,213 | 7,235 | -3.50% | -1.20% | -21.8 |
| អ្នករត់ម៉ូតូឌុប | - | 8,610 | 9,671 | 10,791 | 8,546 | 8,791 | 8,688 | 11,767 | 11,433 | -10.20% | 9.00% | 33.8 |
| កម្មករសំណង់គ្មានជំនាញ | - | 5,399 | 5,996 | 6,937 | 6,552 | 6,095 | 5,944 | 5,747 | 8,130 | -0.90% | -17.20% | 24.1 |
| កម្មករសំណង់មានជំនាញ | - | 13,127 | 16,344 | 13,297 | 11,822 | 13,527 | 12,071 | 14,367 | 12,326 | -26.10% | 8.00% | 4.3 |

*សំគាល់: ចំនួនអ្នកបំរើតាមភោជនីយដ្ឋាន អ្នកស៊ីឈ្នួលធ្វើស្រែ កម្មករកាត់ដេរ អ្នករត់ម៉ូតូឌុប និងកម្មករសំនង់មាននិងគ្មានជំនាញ ចាប់ធ្វើអង្កេតពីខែកុម្ភៈ២០០០ ។ * ចំនួនអ្នកបំរើតាមហាងមិនរាប់បញ្ចូលអាហារ និងការស្នាក់នៅដែលម្ចាស់ភោជនីយដ្ឋានផ្ដល់ឱ្យទេ ។ ប្រភព: តារាង៥: វិបសអ, IMF, NIS ក្រសួងផែនការ, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (អត្រាប្ដូរប្រាក់បានកែតំរូវ) / តារាង៦: ធនាគារជាតិនៃកម្ពុជា *Q4 2003 បានកែតំរូវ / តារាង៧: ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, * Q1-Q4 2004 បាន កែ តំរូវ, Q1-Q4 & Q12004 ជាតួលេខបណ្ដោះអាសន្ន / តារាង៨: វិបសអ ។*

# ខប់សែល ដំណាក់កាលទី២

## យន្តការបង្ការទំនាស់ក្នុងការបោះឆ្នោតនៅកម្ពុជា

ក្នុងរយៈពេលឈានទៅកាន់ការបោះឆ្នោតទាំងបីលើកខាងមុខនៅកម្ពុជា វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (វបសអ) បានចាប់ដំណើរការយន្តការបង្ការទំនាស់ក្នុងការបោះឆ្នោតនៅកម្ពុជា (ខប់សែល-ដំណាក់កាលទី២) ដើម្បីផ្ដល់នូវវេទិកាចំហ និងអព្យាក្រឹត្យ សំរាប់ការពិភាក្សាពីបញ្ហាផ្សេងៗទាក់ទិននឹងការបោះឆ្នោត ។ គោលដៅចំបងគឺដើម្បីបង្ការទំនាស់ អំពើហិង្សា និងការយល់ច្រឡំពីគ្នាក្នុងដំណើរការបោះឆ្នោត ដោយធ្វើការកសាងទំនុកចិត្ត និងលើកស្ទួយវប្បធម៌សន្ទនាគ្នានៅក្នុងក្របខ័ណ្ឌមួយមានសុវត្ថិភាព និងអព្យាក្រិតភាព ដែលមានសារៈសំខាន់បំផុតសំរាប់ការកសាងសន្តិភាព និងរបបប្រជាធិបតេយ្យឱ្យបានរឹងប៉ឹង ។

ខប់សែល-ដំណាក់កាលទី ២ ដោយមានជំនួយហិរញ្ញវត្ថុពីកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) នឹងដំណើរការក្នុងរយៈ៣ឆ្នាំ បន្ទាប់ពីការធ្វើសន្និសីទបើកនៅថ្ងៃទី១៤ កក្កដា ២០០៥ នៅក្រុងភ្នំពេញ, ដោយត្រូវពាក់ព័ន្ធនឹងការបោះឆ្នោតព្រឹទ្ធសភាឆ្នាំ២០០៦ ការបោះឆ្នោតឃុំឆ្នាំ២០០៧ និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ២០០៨ ។ ខប់សែល-ដំណាក់កាលទី២ បែងចែកចេញជា ៦សណ្ឋាន ក្នុងនេះ *ខប់សែលប្រជុំថ្នាក់ខេត្ត-ក្រុង* (COPCELPROM) សំដៅចុះធ្វើការជាមួយថ្នាក់ខេត្ត និង *ខប់សែលតាមរយៈប្រព័ន្ធផ្សព្វផ្សាយ* (COPCELMED) សំដៅផ្សព្វផ្សាយដល់សាធារណជន ហើយទាំងពីរនេះ ជាសកម្មភាពថ្មីលើសពី ខប់សែល-ដំណាក់កាលទី១ ។

ខប់សែល-ដំណាក់កាលទី២ គឺជាតឹកតាងដ៏សំខាន់នៃនៃកាប្ដេជ្ញាចិត្តរបស់ វបសអ ដើម្បីធ្វើការងារជាដៃគូជាមួយស្ថាប័នកម្ពុជា និងអង្គការឯទៀត សំដៅពង្រីក និងពង្រឹងអភិបាលកិច្ចប្រជាធិបតេយ្យនៅកម្ពុជា និងជាតឹកតាងនៃការប្ដេជ្ញាចិត្តជាបន្តរបស់ UNDP សំដៅកែលំអដំណើរការបោះឆ្នោតនៅកម្ពុជា និងលើកកំពស់លិទ្ធិប្រជាធិបតេយ្យនៅកម្ពុជា តាមរយៈជំនួយទ្រទ្រង់រយៈពេលវែងរបស់ខ្លួនដល់កម្មវិធីនេះ ។ តាមរយៈវេទិកា ខប់សែល អ្នកពាក់ព័ន្ធ និងតួអង្គទាំងអស់ក្នុងការបោះឆ្នោត នឹងមានឱកាសលើកសំនួរផ្សេងៗទាក់ទិននឹងការរៀបចំការបោះឆ្នោតឱ្យមានទំនុកចិត្ត តំលាភាព និងគណនេយ្យភាព ព្រមទាំងការស្វែងរកដំណោះស្រាយចំពោះបញ្ហានានា និងការកែលំអកិច្ចសហប្រតិបត្តិការ និងការផ្លាស់ប្ដូរបទពិសោធន៍និងព័ត៌មាន ។

ខប់សែល-ដំណាក់កាលទី១ ជាយន្តការដ៏ពិសេសមួយផ្ដួចផ្ដើមឡើង និងគ្រប់គ្រងដោយជនកម្ពុជា និងមានដំណើរការតាំងពីខែសីហា ១៩៩៩ ដល់ខែកញ្ញា ២០០៣ ដោយបានពាក់ព័ន្ធនឹងការបោះឆ្នោតឃុំឆ្នាំ២០០២ និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ២០០៣ ។ ខប់សែល បានជួបប្រជុំប្រចាំខែចំនួន ៥០ដង ដោយមានជំនួយទ្រទ្រង់ពី USAID និង មូលនិធិអាស៊ី ។ ក្នុងការប្រជុំទាំងនេះមានការចូលរួមពីតំណាងជាង១០០នាក់ មកពីរដ្ឋាភិបាល គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប.) គណបក្សនយោបាយចំបងៗ និងអង្គការមិនមែនរដ្ឋាភិបាលអ្នកឃ្លាំមើលការបោះឆ្នោត ហើយកំណត់ហេតុនៃការប្រជុំ បានផ្ញើថ្វាយ និងជូន ព្រះមហាក្សត្រ សមាជិកទាំងអស់នៃព្រឹទ្ធសភា រដ្ឋសភា ក្រុមប្រឹក្សាធម្មនុញ្ញ នាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទាំងអស់ដែលពាក់ព័ន្ធនឹងដំណើរការបោះឆ្នោត អភិបាល និងអភិបាលរងខេត្ត-ក្រុងទាំងអស់ ស្ថានទូតបរទេស អង្គការសង្គមស៊ីវិលជាតិ និងអន្តរជាតិផ្សេងៗ ។ អង្កេត និងការស្រាវជ្រាវដោយឯករាជ្យរបស់ វបសអ នៅឆ្នាំ២០០៣ និងការពិគ្រោះយោបល់នានានៅចុងឆ្នាំ២០០៤ និងដើមឆ្នាំ២០០៥ ជាមួយអ្នកចូលរួមក្នុងខប់សែល-ដំណាក់កាលទី១ បានចង្អុលបង្ហាញនូវប្រសិទ្ធភាព និងតួនាទីជាលក្ខណៈស្ថាបនារបស់ខប់សែល ព្រមទាំងមតិគាំទ្រអោយមានដំណើរការខប់សែល ជាថ្មីទៀត ។

ក្នុងឱកាសសន្និសីទបើកនៅថ្ងៃ ១៤ កក្កដា ២០០៥ នៅភ្នំពេញ វាគ្មិនកិត្តិយស វាគ្មិនជំនាញការ និងអ្នកចូលរួមជាច្រើន ថ្លែងបញ្ជាក់ការគាំទ្រយ៉ាងខ្លាំងឱ្យខប់សែល-ដំណាក់កាលទី២ ចាប់ដំណើរការទៅមុខទៀត ។

*"ក្នុងដំណាក់កាលទី១ ខប់សែល បានបំពេញតួនាទីដ៏ខ្ពង់ខ្ពស់ឧត្តមរបស់ខ្លួនក្នុងការស្វែងរកមធ្យោបាយគ្រប់បែបយ៉ាង ដើម្បីបង្ការទំនាស់ក្នុងដំណើរការរៀបចំការបោះឆ្នោតតាមបែបប្រជាធិបតេយ្យសេរីនៅកម្ពុជា ។ ក្រៅពីការបង្ការទំនាស់ ខប់សែល នៅបានជួយសំរួលដល់ដំណើរការរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ឆ្នាំ២០០២ និងដំណើរការរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ២០០៣ អោយប្រព្រឹត្តទៅប្រកបដោយជោគជ័យ ។ តាមរយៈការរៀបចំអោយមានការប្រជុំប្រចាំខែ ជាមួយគ្រប់ភាគីពាក់ព័ន្ធនឹងការបោះឆ្នោតទាំងអស់គ្នាបានបង្ហាញពីឆន្ទៈរួមសហការក្នុងខប់សែល ក្នុងការសំរបសំរួលបញ្ចប់បញ្ហាដែលកើតមានក្នុងកំឡុងពេលនៃការរៀបចំការបោះឆ្នោត" ។*

*ឯ.ឧ. អ៊ឹម សួស្ដី*
*ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត*

---

*"ខប់សែល គឺជាយន្តការដ៏ពិសេសមួយផ្ដួចផ្ដើមឡើងនិងគ្រប់គ្រងដោយជនកម្ពុជា ដែលមានគោលដៅបង្ការទំនាស់ អំពើហិង្សា និងការយល់ច្រឡំពីគ្នាក្នុងដំណើរការបោះឆ្នោត ដោយធ្វើការកសាងទំនុកចិត្ត និងលើកស្ទួយវប្បធម៌សន្ទនាគ្នា ។ ខប់សែល មានសារៈសំខាន់ចំពោះកម្ពុជា និងមានសារៈសំខាន់ចំពោះ វបសអ ឆ្លងតាមការប្ដេជ្ញាចិត្តរបស់ វបសអ ដើម្បីធ្វើការងារជាមួយស្ថាប័នកម្ពុជា និងអង្គការឯទៀត សំដៅពង្រីក និងពង្រឹងអភិបាលកិច្ចប្រជាធិបតេយ្យនៅកម្ពុជា ។ តាងនាមឱ្យ វបសអ ខ្ញុំសូមសំដែងគារវកិច្ចចំពោះអ្នកពាក់ព័ន្ធនានាក្នុងដំណើរការ ខប់សែល ព្រមទាំងការប្ដេជ្ញាចិត្តរបស់ពួកគេក្នុងការប្រើប្រាស់ដំណើរការនេះប្រកបដោយការទទួលខុសត្រូវខ្ពស់ ដើម្បីធ្វើការងារជាមួយគ្នា កសាងទំនុកចិត្តនិងកិច្ចសន្ទនា សំដៅបង្ការទំនាស់ក្នុងការបោះឆ្នោតនានានៅកម្ពុជា នាពេល ៣ឆ្នាំខាងមុខ" ។*

*ឡារី ស្រ្តេន្ទ*
*នាយកប្រតិបត្តិ វបសអ*

---

*"ខប់សែល បានផ្ដល់វេទិកាចំហ និងអព្យាក្រឹត សំរាប់ការពិភាក្សាពីបញ្ហានានាទាក់ទិននឹងការបោះឆ្នោត ។ អ្នកចូលរួមក្នុងការបោះឆ្នោត អាចធ្វើការរួមគ្នាក្នុងបរិយាកាសជាមិត្តភាព បើកចំហ និងអព្យាក្រឹត ដើម្បីលើកយកមកពិនិត្យនូវការបារម្ភផ្សេងៗទាក់ទិននឹងការបោះឆ្នោត និងរកឃើញមូលដ្ឋានរួមមួយសំរាប់ដោះស្រាយទំនាស់ ។ ក្នុងដំណើរការនេះ និងក្នុងការបោះឆ្នោត ការកសាងទំនុកចិត្ត គឺមានសារៈសំខាន់បំផុត ។ នៅក្នុងប្រទេសកម្ពុជា ដែលគំរឃើញមានស្មារតីឯករាជ្យ និងអព្យាក្រឹត, ខប់សែល បានផ្ដល់វេទិកាមិនប្រកាន់បក្សពួកដ៏ពិតប្រាកដមួយដែលជួយបង្កើតទំនុកចិត្តក្នុងចំណោមអ្នកពាក់ព័ន្ធទាំងអស់ ។ នេះជាបទពិសោធន៍ដ៏ពិសេសមួយរបស់កម្ពុជា ស្ដីពីវិធីសាស្ត្រសំរបសំរួលដោយជួយរក្សាមុខមាត់ ដែលក្នុងនេះតួអង្គនានាមានអារម្មណ៍នឹងន ក្នុងការលើកយកបញ្ហារសើបផ្សេងៗខាងនយោបាយមកនិយាយ ដោយមិនខ្លាចអាប់មុខដល់ខ្លួនឯង និងដល់គណបក្សដែលខ្លួនជាតំណាង ។"*

*ឱក សេរី សោភ័ក្តិ*
*អ្នកសំរបសំរួល ខប់សែល*

# សន្និសីទបើកយន្តការខប់សែល

**សុន្ទរកថា**
**ឯកឧត្តម ព្រុំ សុខា**
**រដ្ឋលេខាធិការក្រសួងមហាផ្ទៃ**
**នៅក្នុងពិធីបិទសន្និសីទស្តីពី**
**"ការបង្ការជំលោះនៅក្នុងការបោះឆ្នោតនៅកម្ពុជា"**
(COPCEL II) ។
**នៅសណ្ឋាគារភ្នំពេញ**
**ថ្ងៃទី១៤ កក្កដា ២០០៥**

ជាបឋមក្នុងនាមរាជរដ្ឋាភិបាល ក្នុងនាមឯឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមសំដែងនូវសេចក្តីសោមនស្សរីករាយដែលបានចូលរួមក្នុងពិធីបិទសន្និសីទស្តីពី "ការបង្ការជំលោះនៅក្នុងការបោះឆ្នោតនៅកម្ពុជា" ដែលរៀបចំដោយវិទ្យាស្ថានបណ្តុះបណ្តាលនិងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) និងដោយមានការគាំទ្រ ពីកម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ (UNDP) ។

រូបខ្ញុំផ្ទាល់ បានចូលរួមចំណែកនៅក្នុងការបោះឆ្នោតទាំងបួនលើកនៅកម្ពុជា បន្ទាប់ពីកិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីស ។ ការបោះឆ្នោតទាំងបួនលើកនេះ រួមមានការបោះឆ្នោតជ្រើសសភាធម្មនុញ្ញ នៅខែឧសភា ១៩៩៣ ការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រនៅក្នុងរយៈពេល ៥ឆ្នាំ បន្ទាប់មក គឺនៅខែកក្កដា ឆ្នាំ១៩៩៨ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់នៅទូទាំងប្រទេសនៅខែកុម្ភៈ ឆ្នាំ២០០២ និងការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រនៅពេលចុងក្រោយនេះនៅឆ្នាំ២០០៣ ។ អ្វីដែលលេចធ្លោបំផុតនៅក្នុងចន្លោះរយៈពេល ១២ឆ្នាំកន្លងមកនេះគឺថា ដំណើរការបោះឆ្នោតមិនគ្រាន់តែបានចាកផុតពីភាពតានតឹងផ្នែកនយោបាយប៉ុណ្ណោះទេ ប៉ុន្តែនៅក្នុងពេលនីមួយៗ ដំណើរការបោះឆ្នោតនេះ ត្រូវបានកែលំអ ហើយបានចាក់គ្រឹះយ៉ាងរឹងមាំនៅក្នុងវប្បធម៌នយោបាយសង្គមរបស់កម្ពុជា ហើយបានពង្រីកដល់ថ្នាក់ឃុំសង្កាត់ ឬថ្នាក់មូលដ្ឋានថែមទៀត ។

ជោគជ័យដ៏ធំធេងបំផុតនៅក្នុងការបោះឆ្នោតទាំងនេះ គឺទឹកចិត្តពុះកញ្ជ្រោលចំពោះលទ្ធិប្រជាធិបតេយ្យដែលប្រជាជនកម្ពុជា បានបង្ហាញតាមរយៈការទៅចុះឈ្មោះបោះឆ្នោតយ៉ាងច្រើនកុះករ និងតាមរយៈការចូលរួមយ៉ាងសស្រាក់សស្រាំក្នុងការបោះឆ្នោត ទោះជាពេលខ្លះពួកគេត្រូវប្រឈមនឹងការលំបាកខ្លះដែលបង្កឡើងដោយក្រុមប្រឆាំងនឹងការបោះឆ្នោតក្តី ។

ឧទាហរណ៍ នៅក្នុងការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រនៅឆ្នាំ២០០៣ នៅក្នុងចំណោមប្រជាជនកម្ពុជាទាំងអស់ចំនួន ១២,២៥០លាននាក់ អ្នកដែលមានសិទ្ធិទៅចុះឈ្មោះបោះឆ្នោត ៦,៧៥០លាននាក់ ។ អ្នកមានសិទ្ធិបោះឆ្នោត ៩៤%[១] បានទៅចុះឈ្មោះបោះឆ្នោត[២] ។ នៅថ្ងៃបោះឆ្នោត អ្នកបោះឆ្នោតដែលបានចុះឈ្មោះចំនួន ៨៣,២២%[៣] បានទៅបោះឆ្នោតតាមការិយាល័យ ១២.៨២៦កន្លែងដែលគ្រប់គ្រងដោយមន្ត្រីបោះឆ្នោតជាង ៦៤.០០០នាក់ ។ ពេលនេះប្រជាជនកម្ពុជាចាត់ទុករដ្ឋាភិបាលដែលបោះឆ្នោតជ្រើសរើសឡើងយ៉ាងត្រឹមត្រូវតាមបែបប្រជាធិបតេយ្យថា ជារបស់ពិសេសម្យ៉ាងដែលគាត់មានសិទ្ធិទទួលបានក្នុងជីវិតរស់នៅ ។

## ទិដ្ឋភាពសំខាន់ៗនៅក្នុងការបោះឆ្នោតឆ្នាំ១៩៩៣-២០០៣

នៅពេលនេះ ជាការសមស្របដែលត្រូវលើកឡើងដោយសង្ខេបអំពីទិដ្ឋភាពសំខាន់ៗមួយចំនួននៅក្នុងការបោះឆ្នោតក្នុងរយៈពេល ១២ឆ្នាំកន្លងមកនេះ ប៉ុន្តែ ដោយផ្តោតការយកចិត្តទុកដាក់ជាពិសេសទៅលើការរីកចំរើនដែល សំរេចបាននៅឆ្នាំ២០០២ និងឆ្នាំ២០០៣ ។

### ការបោះឆ្នោតដែលរៀបចំដោយ UNTAC នៅឆ្នាំ១៩៩៣

ការបោះឆ្នោតនៅឆ្នាំ១៩៩៣ ត្រូវបានរៀបចំចាត់ចែងឡើងដោយអាជ្ញាធរបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិនៅកម្ពុជា (UNTAC) ដែលជាផ្នែកមួយនៃការដោះស្រាយសន្តិភាពនៅពេលដំបូង ។ ជាលទ្ធផល ភាគីចំនួនបីនៅក្នុងចំណោមភាគីទាំងបួនក្នុងជំលោះរបស់កម្ពុជាបានបំពេញការងារជាមួយគ្នា ។ ភាគីទីបួន គឺខ្មែរក្រហមបានដកខ្លួនចេញពីស្ថាប័នប្រជាធិតេយ្យទៅកាន់ការបាត់បង់ដ៏ធំមួយរបស់ពួកគេ ។

### ការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រឆ្នាំ១៩៩៨

ភាគច្រើននៃការផ្តួចផ្តើម និងការលើកទឹកចិត្តដល់ការបោះឆ្នោតដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌នៅឆ្នាំ១៩៩៨ ក៏បានមកពីសហគមន៍អន្តរជាតិផងដែរ ដែលជាមធ្យោបាយមួយក្នុងការបង្កើតឱ្យមានសន្តិភាពនៅក្នុងចំណោមភាគី ដែលមានជំលោះនៅខែកក្កដា ឆ្នាំ១៩៩៧ ។ លទ្ធផលនៃការបោះឆ្នោតបង្រួបបង្រួមគ្នានេះ គឺការបង្កើតរាជរដ្ឋាភិបាលចំរុះ ។

អ្វីដែលសំខាន់ជាងនេះនោះគឺថា អាជ្ញាធររៀបចំការបោះឆ្នោតរបស់កម្ពុជាបានបង្ហាញនៅឆ្នាំ១៩៩៨ ថាខ្លួនអាចរៀបចំការបោះឆ្នោតទៅតាមស្តង់ដារបច្ចេកទេសក្នុងកំរិតខ្ពស់ ។

### ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ឆ្នាំ២០០២

នៅខែកុម្ភៈ ឆ្នាំ២០០២ ដំណើរការបោះឆ្នោតត្រូវបានប្រើប្រាស់ ដើម្បីពង្រីកលទ្ធិប្រជាធិតេយ្យនៅថ្នាក់មូលដ្ឋាននៅក្នុងសង្គមកម្ពុជា និងដើម្បីចាក់គ្រឹះមូលដ្ឋាននេះ ។

សហគមន៍អន្តរជាតិមិនបានបង្ខំ ឬកំណត់ឱ្យមានវិមជ្ឈការ ឬការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់នៅមូលដ្ឋានតាមបែបប្រជាធិតេយ្យឡើយ ។ ការបោះឆ្នោតនេះ គឺជាគំនិតផ្តួចផ្តើមរបស់កម្ពុជា ក្នុងការពង្រឹងលទ្ធិប្រជាធិតេយ្យបន្ថែមទៀត និងជំរុញការអភិវឌ្ឍន៍ ។ ការពិតនៅពេលដំបូង មជ្ឈដ្ឋានខ្លះនៅក្នុងសហគមន៍អន្តរជាតិ មានការមន្ទិលសង្ស័យចំពោះ គំនិតផ្តួចផ្តើមនេះ ។ ការបោះឆ្នាតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់នៅឆ្នាំ២០០២ គឺជាដង្ហើមរស់នៃបទពិសោធន៍ដ៏ធំធេងនៅក្នុងវិមជ្ឈការ និងការអភិវឌ្ឍន៍បែបប្រជាធិបតេយ្យ ។ ការប្រឹងប្រែងនេះស្ថិតនៅលើផ្លូវដ៏វែងឆ្ងាយទៀត ប៉ុន្តែវាបានចាប់ផ្តើមយ៉ាងល្អ ហើយកំពុងធ្វើដំណើរទៅមុខជាដរាប ។

### ការកែទំរង់ការបោះឆ្នោតនៅឆ្នាំ២០០២

ក្នុងកំឡុងឆ្នាំ២០០២ ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ ត្រូវបានធ្វើវិសោធនកម្មជាច្រើន សំរាប់ការត្រៀមរៀបចំសំរាប់ឆ្នាំបន្ទាប់ ។ ការកែទំរង់នេះ ធ្វើឡើងក្នុងបំណងកែលំអក្បាលម៉ាស៊ីន រៀបចំការបោះឆ្នោត និងកាត់បន្ថយការចំណាយ ។ ការកែទំរង់ដើម្បីសំរេចឱ្យបាននូវគោលបំណងទាំងនេះ គឺតាមរយៈកាលពិនិត្យមើលឡើងវិញ និងការធ្វើវិសោធនកម្មជាច្រើនលើបទបញ្ជា និងនីតិវិធីនៃការបោះឆ្នោតដែលមានពីមុនមក និងការកែលំអខ្លឹមសារ និងដំណើរការនៃការបោះឆ្នោតនៅឆ្នាំ២០០៣ ។ យើងអាចធ្វើការកែលំអច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ ក៏ដូចជាបទបញ្ជា និងនីតិវិធី ដើម្បីឱ្យកាន់តែងាយស្រួល និងច្បាស់លាស់បន្ថែមទៀត ។

### ការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រឆ្នាំ២០០៣

ការបោះឆ្នោតនៅឆ្នាំ២០០៣[៤] មានលក្ខណៈល្អប្រសើរជាងការបោះឆ្នោតលើកមុន ។ មូលហេតុជាអាទិ៍ រួមមាន :

- ការចូលរួមយ៉ាងសស្រាក់សស្រាំរបស់ប្រជាពលរដ្ឋនៅក្នុងការចុះឈ្មោះបោះឆ្នោត និងការចេញទៅបោះឆ្នោត
- ក្របខ័ណ្ឌច្បាប់ និងបទបញ្ជា ដែលមានលក្ខណៈកាន់តែរឹងមាំ
- គណៈកម្មាធិការជាតិរៀបចំកាបោះឆ្នោតដែលមានប្រសិទ្ធភាព និងមានឯករាជភាពផ្នែកនយោបាយ
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងមន្ត្រីបោះឆ្នោត មានចំណេះដឹង និងមានបទពិសោធន៍ផ្នែកបោះឆ្នោតកាន់តែច្រើន
- វចនាសម្ព័ន្ធ និងការគ្រប់គ្រងនៅក្នុងការបោះឆ្នោតកាន់តែប្រសើរ
- ការកែលំអជាច្រើនលើផ្នែកបច្ចេកទេស និងនីតិវិធី រួមទាំងការបង្កើតឱ្យមានបញ្ជីឈ្មោះអ្នកបោះឆ្នោតអចិន្ត្រៃយ៍

- មានការសន្សំសំចៃផ្នែកសេដ្ឋកិច្ច និងហិរញ្ញវត្ថុយ៉ាងច្រើន
- ការពិនិត្យតាមដាននិងការសង្កេតការណ៍កាន់តែមានប្រសិទ្ធភាព និងមានចំណេះដឹងកាន់តែច្រើន
- មានការគោរពយ៉ាងទូលំទូលាយលើភាពសំងាត់នៃសន្លឹកឆ្នោត
- ការពិគ្រោះយោបល់កាន់តែមានប្រសិទ្ធិភាពនៅក្នុង COPCEL ដែលរួមចំណែកដល់ការបង្ការជំលោះ និងការប្រតិបត្តិបទបញ្ជាកាន់តែប្រសើរ
- យុទ្ធសាស្ត្រថ្មីៗនៃការផ្សព្វផ្សាយពត៌មានដើម្បីផ្តល់លទ្ធភាពប្រើប្រាស់ ដោយមានភាពស្មើគ្នាដល់អ្នកពាក់ព័ន្ធផ្នែកនយោបាយទាំងអស់ ជាពិសេសការប្រើប្រាស់បណ្តាញពត៌មានរបស់រដ្ឋ
- លទ្ធភាពប្រើប្រាស់បណ្តាញពត៌មាន ដែលមានលក្ខណៈកាន់តែបើកចំហ និងមានតុល្យភាពពីសំណាក់គណបក្សនយោបាយទាំងអស់
- ការគាំទ្រកាន់តែខ្លាំងក្លាក្នុងដំណើរការបោះឆ្នោត ពីសំណាក់អង្គការមិនមែនរដ្ឋាភិបាល សង្គមស៊ីវិល និងក្រុមប្រជាពលរដ្ឋផ្សេងទៀត
- អំពើហិង្សា មានការកាត់បន្ថយ

ទិដ្ឋភាពជាក់ស្តែងខ្លះខាងលើនេះត្រូវបានទទួលការកោតសរសើរជាពិសេស ។

## គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតថ្មី

ការបង្កើតគណៈកម្មាធិការរៀបចំការបោះឆ្នោត ដែលមានទំហំកាន់តែតូចដោយមិនមានការពាក់ព័ន្ធផ្នែកនយោបាយនាំឱ្យមានការលើកកំពស់ជាច្រើនដល់ការងារ និងដល់ឋានៈគណៈកម្មាធិការនេះ ជាអាជ្ញាធរបោះឆ្នោតមាន ប្រសិទ្ធភាព និងមិនលំអៀង ។

## ការពិគ្រោះយោបល់ និងការប្រមូលកំលាំង

អ្វីដែលសំខាន់នោះគឺថា គណៈកម្មាធិការរៀបចំការបោះឆ្នោត បានដំណើរការទៅតាមរបៀបដែលមានតម្លាភាព និងដោយមានការចូលរួម ដែលបានរួមចំណែកយ៉ាងច្រើនដល់ការបង្ការជំលោះ និងការកែលំអនៅក្នុងដំណើរការបោះឆ្នោត ។ គណៈកម្មាធិការរៀបចំការបោះឆ្នោតបានប្រឹងប្រែងយ៉ាងសកម្មក្នុងការស្វែងរកការចូលរួមពីសំណាក់គណបក្សនយោបាយ អង្គការមិនមែនរដ្ឋាភិបាល និងអន្តរជាតិ ឱ្យធ្វើជាដៃគូររបស់ខ្លួននៅក្នុងដំណើរការបោះឆ្នោត ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ក៏បានលើកទឹកចិត្ត និងបានចូលរួមនៅក្នុង COPCEL ចាប់តាំងពីចុងឆ្នាំ២០០២ និងបានរៀបចំប្រជុំជាប្រចាំជាមួយតំណាងគណបក្សនយោបាយ អង្គការមិនមែនរដ្ឋាភិបាល និងបណ្តាញផ្សព្វផ្សាយពត៌មានផ្សេងទៀតផងដែរ ។ គណៈកម្មាធិការរៀបចំការបោះឆ្នោត បានផ្តល់ឱ្យអ្នកពាក់ព័ន្ធទាំងឡាយនូវសេចក្តីព្រាងបទបញ្ជានីតិវិធីសំរាប់ឱ្យមានការរួមយោបល់នៅមុនពេលធ្វើការអនុម័ត ។ តាមវិធីនេះ គណៈកម្មាធិការរៀបចំការបោះឆ្នោតបានកែលំអគុណភាពនៃបទបញ្ជារបស់ខ្លួន និងការបង្ហាញនូវការឆ្លើយតប និងការយកចិត្តទុកដាក់ដែលគួរឱ្យកោតសរសើរ ចំពោះកង្វល់នៅក្នុងការបោះឆ្នោតរបស់សង្គមកម្ពុជាទាំងមូល ។

ជាទូទៅ ក៏មានការគោរពគ្នាទៅវិញទៅមកកាន់តែខ្លាំងរវាងអ្នកពាក់ព័ន្ធផងដែរ ។ ទោះជាយ៉ាងណាក៏ដោយ គណបក្សនយោបាយគួរពុះពារស្វែងយល់ឱ្យកាន់តែច្រើនថែមទៀតអំពីតួនាទី និងកាតព្វកិច្ចរបស់ខ្លួននៅក្នុងកំឡុងពេលនៃការឃោសនារកសំលេងឆ្នោត និងបង្កើតទំនាក់ទំនងនៃការជឿទុកចិត្តគ្នាទៅវិញទៅមកជាមួយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតឱ្យកាន់តែចំហថែមទៀត ។

## ការចុះឈ្មោះអ្នកបោះឆ្នោត

នៅឆ្នាំ២០០៣ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានបង្កើតបញ្ជីឈ្មោះអ្នកបោះឆ្នោតអចិន្ត្រៃយ៍ ដោយផ្អែកលើបញ្ជីឈ្មោះដែលបានប្រើប្រាស់នៅក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់នៅឆ្នាំ២០០២ ។ ការទទួលខុសត្រូវនៅក្នុងការចុះឈ្មោះ ត្រូវបានធ្វើប្រតិភូកម្មដល់រដ្ឋបាលឃុំ សង្កាត់ ក្រោមការត្រួតពិនិត្យរបស់គណៈកម្មាធិការរៀបចំការបោះឆ្នោត ។ ដំណើរការចុះឈ្មោះ ដោយគ្មានភាពលំអៀង ក៏ត្រូវបានបង្កើតឡើងផងដែរ ។

ចាប់ពីឆ្នាំ២០០៤ មានបញ្ជីឈ្មោះអ្នកបោះឆ្នោតអចិន្ត្រៃយ៍ ដែលចុះឈ្មោះអ្នកបោះឆ្នោតជារៀងរាល់ឆ្នាំ និងមានការពិនិត្យមើលឡើងវិញលើបញ្ជីឈ្មោះនេះ ។ នៅឆ្នាំ២០០៤ អ្នកបោះឆ្នោតថ្មីជាង ២៩០.០០០នាក់ បាន ចុះឈ្មោះ ។

ការចំណាយលើប្រពន្ធចុះឈ្មោះថ្មី[៦] មានតំលៃទាបជាងការចុះឈ្មោះទៅតាមដំណាក់កាល ។ គុណភាពនៃការដំណើរការនេះ ក៏នឹងកែលំអផងដែរ នៅពេលដែលនីតិវិធីនេះ ក្លាយទៅជាផ្នែកមួយនៃការងារប្រចាំថ្ងៃរបស់រដ្ឋបាលឃុំ សង្កាត់ ។ គំនិតផ្តួចផ្តើមរបស់គណៈកម្មា-ធិការជាតិរៀបចំការបោះឆ្នោតក្នុងការកែលំអកម្មវិធី Software ហើយនិងការបែងចែកគ្រប់គ្រងឧបករណ៍កំព្យូទ័រ ក៏នឹងរួមចំណែកកែលំអផងដែរ ដល់គុណភាពនៃបញ្ជីឈ្មោះ និងកាត់បន្ថយការចំណាយលើការថែទាំផ្នែកបច្ចេកទេស ។

ដំណើរការចុះឈ្មោះ និងបញ្ជីឈ្មោះអ្នកបោះឆ្នោតតាមប្រព័ន្ធកុំព្យូទ័រក៏នៅតែអាចកែលំអបានដែរ ។ អ្នកបោះឆ្នោតម្នាក់ៗ ក៏គួរទទួលបានពត៌មានជាមុនអំពីទីកន្លែងនៃការិយាល័យដែលគាត់អាចបោះឆ្នោត និងរបៀបរកឈ្មោះរបស់គាត់នៅលើបញ្ជីដែលនៅពេលនេះ ត្រូវបានរៀបទៅតាមលំដាប់តួអក្សរ ។

## បណ្តាញផ្សព្វផ្សាយពត៌មាន

តួនាទីរបស់បណ្តាញពត៌មាន បានលេចឡើងជាសូចនាករយ៉ាងសំខាន់ចំពោះភាពដែលអាចជឿទុកចិត្តបាននៃការបោះឆ្នោតនៅឆ្នាំ២០០៣ ។ ការកែលំអយ៉ាងសំខាន់មួយនៅក្នុងការបោះឆ្នោត គឺការបើកចំហលទ្ធភាពប្រើប្រាស់បណ្តាញផ្សព្វផ្សាយពីសំណាក់គណបក្ស និងអ្នកបោះឆ្នោត ។ ប្រការនេះ ធ្វើឱ្យគណបក្សមានលទ្ធភាពឃោសនារកសំលេងឆ្នោតកាន់តែមានប្រសិទ្ធភាព ហើយក៏ធ្វើឱ្យអ្នកបោះឆ្នោត មានលទ្ធភាពទទួលពត៌មានកាន់តែច្រើនផងដែរ ។ ការផ្តល់ម៉ោងផ្សាយដោយឥតគិតថ្លៃដល់គណបក្សនយោបាយទាំងអស់ ស្ថិតនៅក្នុងលំដាប់ខ្ពស់បំផុតនៅអាស៊ី ។

គ្មានអ្វីដែលគួរសង្ស័យទេថា ការឃោសនារកសំឡេងឆ្នោតទទួលបាន ផលពីការពិភាក្សាជាចំហ ដែលមិនធ្លាប់មានពីមុនមកនៅលើបណ្តាញផ្សព្វផ្សាយរបស់រដ្ឋ និងឯកជន និងនៅមូលដ្ឋានគួរមានការប្រឹងប្រែងថែមទៀត ដើម្បីគាំទ្រដំណើរការនេះ ។

## អ្នកសង្កេតការណ៍

វត្តមានរបស់អ្នកសង្កេតការណ៍ មានផលប៉ះពាល់ជាចំបងទៅលើការជំរុញឱ្យមានបរិយាកាសបើកចំហ និងតម្លាភាព និងលើកកំពស់ជំនឿទុកចិត្តរបស់សាធារណជននៅក្នុងដំណើរការបោះឆ្នោត និងលទ្ធផលនៃការបោះឆ្នោត ។ អ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិប្រហែល ៣០.០០០នាក់ បានធ្វើទំនាក់ទំនងជាប្រចាំជាមួយគណៈកម្មការខេត្តក្រុងរៀបចំការបោះឆ្នោត គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត មន្ត្រីគណបក្ស និងអង្គការមិន មែនរដ្ឋភិបាល ។

## ការចំណាយ

ទោះបីមានការប្រុងប្រយ័ត្នផ្នែកហិរញ្ញវត្ថុ និងការខិតខំសន្សំសំចៃយ៉ាងណាក្តី ក៏ការបោះឆ្នោតមានតំលៃខ្ពស់ដែរ ។ នេះគឺការចំណាយយ៉ាងសំខាន់ដែលមិនអាចជៀសផុតបានសំរាប់លទ្ធិប្រជាធិតេយ្យ ។ ទោះជាយ៉ាងណាក៏ដោយ មូលហេតុដែលមាំឱ្យមានការចំណាយខ្ពស់ត្រូវតែធ្វើការពិនិត្យមើល និងវាយតំលៃជាប្រចាំ ហើយត្រូវធ្វើអោយមានការសន្សំសំចៃ ។

នៅលើឆាកអន្តរជាតិ ការបោះឆ្នោតខ្លះមានតំលៃខ្ពស់ជាងការបោះឆ្នោតផ្សេងទៀត ។ កត្តាយ៉ាងសំខាន់មួយដែលពាក់ព័ន្ធនឹងការចំណាយហាក់ដូចជា អាស្រ័យលើរយៈពេលនៃបទពិសោធន៏កន្លងមកនៅក្នុងការបោះឆ្នោតពហុបក្ស ។ មានការចំណាយខុសគ្នាយ៉ាងខ្លាំងរវាងការបោះឆ្នោតនៅក្នុងសង្គមប្រជាធិតេយ្យដែលមានស្ថិរភាព ការបោះឆ្នោតនៅក្នុងសង្គមប្រជាធិតេយ្យអន្តរកាល និងការបោះឆ្នោតនៅក្នុងអំឡុងពេលនៃប្រតិបត្តិការពិសេស[៧] រក្សាសន្តិភាព ។ គេមានការលំបាកក្នុងការប្រៀបធៀបលើការចំណាយ ហើយកាប្រៀបធៀបនេះត្រូវការមានការប្រុងប្រយ័ត្ន ប៉ុន្តែគេអាចធ្វើការសង្កេតមួយចំនួន ។

នៅក្នុងប្រទេសដែលមានបទពិសោធន៏ប្រជាធិតេយ្យពហុបក្សជាយូរមកហើយ ការចំណាយលើការបោះឆ្នោតហាក់ដូចជាមានតំលៃទាបជាងនៅក្នុងប្រទេសដែលទើបតែចាប់ផ្តើមអនុវត្តការបោះឆ្នាត ។ ការចំណាយប្រហែលពី ១ ទៅ ៣ដុល្លារអាមេរិក សំរាប់អ្នកបោះឆ្នោតម្នាក់ គឺស្ថិតក្នុងប្រទេស ដែលមានបទពិសោធន៏នៅក្នុងការបោះឆ្នោតកាន់តែយូរ[៨] ។ នៅ

ពេលនេះ កម្ពុជាហាក់ដូចជាស្ថិតនៅក្នុងចំណោមប្រទេសប្រភេទនេះ ។ នៅក្នុងប្រទេសភាគច្រើនដែលមិនសូវមានបទពិសោធន៍ប្រជាធិបតេយ្យពហុបក្ស ការចំណាយហាក់ដូចជាមានកំរិតកាត់តែខ្ពស់[៩] ចាប់ពី ៣,៧ដុល្លារអាមេរិកទៅ ១១ដុល្លារអាមេរិក ។

ការបោះឆ្នោតដែលត្រូវរៀបចំឡើងជាផ្នែកមួយនៃប្រតិបត្តិការរក្សាសន្តិភាពមានការចំណាយខ្ពស់បំផុត[១០] ។ ឧទហរណ៍ ការបោះឆ្នោតនៅកម្ពុជា នៅឆ្នាំ១៩៩៣ ចំណាយប្រហែល ៤៥ដុល្លារ សំរាប់អ្នកបោះឆ្នោតម្នាក់ ។

នៅកម្ពុជា ការចំណាយសំរាប់ការបោះឆ្នោតនីមួយៗ ចាប់តាំងពីឆ្នាំ១៩៩៣ បានថយចុះជាច្រើន ។ ការចំណាយសំរាប់ការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រនៅឆ្នាំ១៩៩៨ មានទឹកប្រាក់ ២៤,៣៤៣លានដុល្លាអាមេរិក ។ ការចំណាយសំរាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់នៅឆ្នាំ២០០២ (ដែលមានភាពស្មុគស្មាញ និងត្រូវចំណាយផ្នែកភស្តុភារខ្ពស់) មានទឹកប្រាក់ ១៥,០៦២លានដុល្លារអាមេរិក ។ ការចំណាយសំរាប់ការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រនៅឆ្នាំ២០០៣ មានទឹកប្រាក់ ១១,១៦២លានដុល្លារអាមេរិក (ឬ ១,៧៦សំរាប់ការបោះឆ្នោតដែលបានចុះឈ្មោះម្នាក់[១១]) ។ ជាមួយនឹងការកាត់បន្ថយនៅក្នុងការចំណាយនេះ មានការកើនឡើងផ្នែកស្តង់ដារ និងបច្ចេកទេស ។

ជាការច្បាស់ណាស់ថា បទពិសោធន៍នៅក្នុងការងារបោះឆ្នោត គឺជាកត្តាយ៉ាងសំខាន់នៅក្នុងការកាត់បន្ថយការចំណាយ ។ នៅពេលនេះ គេអាចសង្ឃឹមថា ការបោះឆ្នោតនៅកម្ពុជា នឹងមានស្ថិរភាពផ្នែកហិរញ្ញវត្ថុ ហើយនឹងទទួលបានផលពីការវិនិយោគលើបទពិសោធន៍ ។

ការចំណាយដោយប្រយោលមានការលំបាកនឹងវាយតំលៃ ។ ឧទាហរណ៍ មានការប៉ាន់ស្មានថា ការគាំទ្រចំពោះសកម្មភាពរបស់អង្គការមិនមែនរដ្ឋាភិបាល មានទឹកប្រាក់ស្ទើរតែស្មើនឹងថវិកាបោះឆ្នោតជារួមរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត[១២] ។

## ជំនួយហិរញ្ញវត្ថុអន្តរជាតិ

ការវាយតំលៃបូកសរុបលើការបោះឆ្នោតទាំងបួនលើក នឹងពុំមានលក្ខណៈពេញលេញឡើយ ប្រសិនជាមិនមានកាទទួលស្គាល់ពីតួនាទីយ៉ាងសំខាន់របស់សហគមន៍អន្តរជាតិនៅក្នុងការផ្តល់ជំនួយបច្ចេកទេស និងហិរញ្ញវត្ថុ ។ ប្រទេសផ្សេងគ្នាមានរបៀបវារៈដោយឡែកពីគ្នានៅក្នុងការគាំទ្រការបោះឆ្នោតនៅកម្ពុជា ប៉ុន្តែពិនិត្យពីផលជារួមគឺមានលក្ខណៈវិជ្ជមាន ហើយរាជរដ្ឋាភិបាលសូមសំដែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការរួមវិភាគទានដ៏ថ្លៃថ្លាទាំងនោះ ។

ជាការសំខាន់ដែលត្រូវកត់សំគាល់ថា នៅក្នុងការបោះឆ្នោតនៅឆ្នាំ១៩៩៨ អ្នកផ្តល់ជំនួយអន្តរជាតិ បានផ្តល់មូលនិធិជិត ៨០% នៃចំណាយសរុបនៅក្នុងការបោះឆ្នោតនៅកម្ពុជា ។ ការផ្តល់មូលនិធិបានថយមកនៅជិត ៦០% ក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់នៅឆ្នាំ២០០២ និងមានតិចជាង ៥០% សំរាប់ការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រឆ្នាំ២០០៣ ។

មានការលើកទឹកចិត្តយ៉ាងខ្លាំង ចំពោះគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងរាជរដ្ឋាភិបាល ក្នុងការកាត់បន្ថយកាចំណាយលើការបោះឆ្នោតជាទូទៅ និងកាត់បន្ថយការពឹងផ្អែកលើជំនួយអន្តរជាតិសំរាប់ការបោះឆ្នោត ។

## ការវាយតំលៃជារួម

ទោះបីជាមានបញ្ហាផ្សេងៗក្តី ក៏ការបោះឆ្នោតទាំងបួនលើកបានប្រព្រឹត្តិទៅ ដោយមានជំនាញបច្ចេកទេស សុច្ចរិតភាព អព្យាក្រិតភាព និងភាពត្រឹមត្រូវ ដែលត្រូវបានទទួលស្គាល់ជាលក្ខណៈអន្តរជាតិ ។ ការបោះឆ្នោតនៅកម្ពុជា នៅពេលនេះមានភាពដែលអាចជឿទុកចិត្តបានមានសុវត្ថិភាព មានភាពត្រឹមត្រូវតាមច្បាប់ និងភាពដែលអាចទទួលយកបានដែលនៅក្នុងរយៈពេលប៉ុន្មានឆ្នាំមុននេះ គេស្ទើរតែមិននឹកស្មានដល់ឡើយ ។

អតីតឯកអគ្គរដ្ឋទូតប្រទេសសឹង្ហបូរីប្រចាំនៅកម្ពុជាបានមានសាសន៍ថា "ការបោះឆ្នោតនៅកម្ពុជា មានការរីកចំរើនល្អប្រសើររៀងរាល់ពេល ។ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់នៅឆ្នាំ២០០២ បានរៀបចំឡើង ប្រសើរជាងការបោះឆ្នោតនៅឆ្នាំ១៩៩៨ ។ ទោះបីជាយ៉ាងណាក៏ដោយ "ការបោះឆ្នោតនៅឆ្នាំ២០០៣" មានលក្ខណៈល្អប្រសើរជាងគេបំផុត" ។

ទស្សនៈវិស័យសំរាប់ប្រជាធិបតេយ្យភាវូបនីយកម្មជាបន្តទៀតនៅកម្ពុជា គឺមានលក្ខណៈកាន់តែប្រសើរឡើង ។

## ការដោះស្រាយជំលោះ

ការបោះឆ្នោតនៅកម្ពុជា ក៏ដូចជានៅប្រទេសជាច្រើនទៀតផងដែរ គឺបានទទួលជោគជ័យនៅក្នុងការកំណត់ និងការប្រមូលផ្តុំទស្សនៈផ្សេងគ្នា និងកំលាំងនយោបាយដែលមានការប្រកួតប្រជែងគ្នា ។ ការបោះឆ្នោតទាំងនេះ បានរក្សាឱ្យមានការប្រកួតប្រជែងដណ្តើមអំណាចនៅក្នុងបន្ទប់គូសសន្លឹកឆ្នោត និងរក្សាឱ្យអោយមានការអនុវត្តអំណាចនៅក្នុងស្ថាប័នដែលត្រូវបានទទួលស្គាល់ ។

ការបោះឆ្នោតទាំងនេះ ធ្វើឱ្យមានភាពស្របច្បាប់នូវទស្សនៈខុសគ្នា និងការប្រកួតប្រជែងផ្នែកនយោបាយ ហើយមានសារៈសំខាន់ជាសារវ័ន្តសំរាប់ការដោះស្រាយប្រកបដោយសន្តិភាពនូវទំនាស់នៅថ្នាក់ជាតិ និងនៅមូលដ្ឋាន ។ ទោះជាយ៉ាងណាក៏ដោយបុរេល័ក្ខខ័ណ្ឌជាមូលដ្ឋានសំរាប់ការដោះស្រាយជំលោះប្រភេទនេះប្រកបដោយជោគជ័យគឺថា លទ្ធផលនៃការបោះឆ្នោតត្រូវតែបានមើលឃើញថាជាការឆ្លុះបញ្ចាំងជំរើសរបស់ប្រជាជន ។ លទ្ធផលនៃការបោះឆ្នោតត្រូវតែមានលក្ខណៈអាចជឿទុកចិត្តបាន និងអាចទទួលបាន ។ ហើយលទ្ធផលនៃការបោះឆ្នោតដែលអាចជឿទុកចិត្តបាន និងអាចទទួលយកបានអាស្រ័យលើដំណើរកាបោះឆ្នោតដែលអាចជឿទុកចិត្តបាន និងអាចទទួលយកបាន[១៣] ។

ជារួម ដំណើរការបោះឆ្នោតទាំងនេះ កំណត់បទបញ្ជាជាក់លាក់ ហើយផ្តល់នូវច្រកច្បាស់លាស់សំរាប់ការប្រកាន់ឥរិយាបថនៅក្នុងការបោះឆ្នោត ។ ដំណើរការបោះឆ្នោតបានបង្កើតជា "វិធាននៃល្បែង" ។ វិធានទាំងនេះ កំណត់ ឬជួយសំរួលទំនាក់ទំនងពិសេសរវាងមនុស្ស និងសង្គមដែលត្រូវតែទទួលបានការយល់ឃើញជាទូទៅ និងការទទួលយកជារួមពីសំណាក់អ្នកចូលរួមទាំងអស់នៅក្នុងការបោះឆ្នោត ។ ទោះជាយ៉ាងណាក៏ដោយ ដើម្បីឱ្យមានការទទួលយកជារួមនេះ ទីមួយ ដំណើរការនេះត្រូវស្របទៅនឹងតំរូវការរបស់មនុស្ស (រួមមានភាពពេញលេញគ្រប់ជ្រុងជ្រោយ សមធម៌ សមភាពនិងការមូលមតិ ឬកុងសង់ស៊ុស) និងទីពីរ ការលើកកំពស់ និងការការពារផលប្រយោជន៍ ដ៏សំខាន់របស់មនុស្ស (រួមមាន សន្តិភាព និងការបែងចែកយ៉ាងត្រឹមត្រូវនូវអំណាចនយោបាយ) ។

សរុបមក ជាការសំខាន់ណាស់ដែលត្រូវធានាឱ្យមានដំណើរការបោះឆ្នោត ដែលនៅក្នុងដំណើរកានោះ ក្រុមសង្គម និងក្រុមនយោបាយចំរុះ អាចចូលរួមបានទៅតាមបំនងរបស់ខ្លួន ។

អាស្រ័យហេតុនេះ ដំណើរការបោះឆ្នោតដែលមិនមានលក្ខណៈពេញលេញមិនមានសមធម៌ មិនមានសមភាព ឬមិនអាចទទួលយកបាន ឬដែលមានលំអៀង ឬមានលក្ខណៈបំភ្លៃ (ឬហាក់ដូចជា មានភាពលំអៀង ឬបំភ្លៃ) នោះលទ្ធផលត្រឹមត្រូវនៃការបោះឆ្នោត នឹងបង្កឱ្យមានទំនាស់នៅក្នុងអំឡុងពេលនៃការបោះឆ្នោតក្រៅពីការធ្វើឱ្យមានផលប៉ះពាល់ដល់លទ្ធផលដែលមានការខុសឆ្គង ។

ដូច្នេះ យន្តការការចាត់ចែង និងបទបញ្ញត្តិសំរាប់ការបង្ការ និងការដោះស្រាយជំលោះលើដំណើរការបោះឆ្នោត មានសារៈសំខាន់ជាសារវ័ន្ត និងមានលក្ខណៈត្រឹមត្រូវទៅតាមច្បាប់ ។ ដោយជួយសំរួលយន្តការ ការចាត់ចែង និងបទបញ្ញត្តិទាំងនេះខ្ញុំយល់ថា COPCEL អាចផ្តល់ជាការរួមចំណែកដ៏មានតំលៃចំពោះលទ្ធិប្រជាធិបតេយ្យ សន្តិភាព និងការអភិវឌ្ឍន៍កម្ពុជា ។

នៅក្នុងការពិចារណាអំពីការបង្ការជំលោះនិងការដោះស្រាយជំលោះ នៅក្នុងមូលដ្ឋាននយោបាយសង្គមដ៏ទូលំទូលាយនេះប្រហែលជាការចាំបាច់ក្នុងការកត់សំគាល់ថា ទំនាស់សង្គម ឬការមិនចុះសំរុងគ្នា (ដែលខុសពីអំពើហិង្សា ឬអំពើឧក្រិដ្ឋ) មិនមែនជាអំពើខុសឆ្គង ឬជាអំពើអាក្រក់គួរឱ្យស្អប់ខ្ពើមនោះឡើយ ។ ទំនាស់ប្រភេទនេះ ក៏មិនមែនជាប្រការដែលត្រូវចៀសវាងដែរ ។ ទំនាស់អាចផ្តើមចេញ ឬជួយជំរុញទឹកចិត្ត ផលប្រយោជន៍ និងចេតនាល្អ ។

ជាញឹកញាប់ ទំនាស់នៅក្នុងសង្គមផ្តើមចេញមកពីតំរូវការ និងសេចក្តីប៉ងប្រាថ្នារបស់មនុស្សដែលមិនបានឆ្លើយតប ។ ទោះជាយ៉ាងណាក៏ដោយ តំរូវការ និងសេចក្តីប៉ងប្រាថ្នារបស់មនុស្សមិនមែនស្ថិតនៅដដែលជារៀងរហូតឡើយ ។ តំរូវការ និងសេចក្តីប៉ងប្រាថ្នានេះមានការរីកលូតលាស់ និងមានការប្រែប្រួលពីពេលមួយទៅពេលមួយទៀត ហើយក៏បង្កឱ្យមានឥទ្ធិពល និងទទួលរងឥទ្ធិពលពីកាលៈទេសៈរបស់សង្គមនយោបាយ និងសេដ្ឋកិច្ចផងដែរ ។ ដូច្នេះតំរូវការ និងសេចក្តីប៉ងប្រាថ្នារបស់មនុស្សពីអតីតកាលអាចមានលក្ខណៈមិនសមស្រប ឬមិនគ្រប់គ្រាន់សំរាប់តំរូវការ និងសេចក្តីប៉ងប្រាថ្នារបស់មនុស្សបច្ចុប្បន្ន ឬអនាគត ។

ជាផលវិបាក ផ្អែកតាមទស្សនៈនេះ ទំនាស់សង្គមអាចត្រូវមើលឃើញថា ជាបុរេលក្ខខ័ណ្ឌ ឬជាកាតាលីករសំរាប់ការរីកចំរើន និងការអភិវឌ្ឍន៍របស់មនុស្ស ទោះជាក្នុងវិស័យបោះឆ្នោត

គឺការអភិវឌ្ឍន៍សង្គមប្រជាធិបតេយ្យ វិទ្យាសាស្ត្រ វេជ្ជសាស្ត្រ ឬសកម្មភាពផ្សេងទៀតរបស់សង្គមក្តី ។ ក្នុងព្រឹត្តិការណ៍នេះជាការប្រសើរដែលត្រូវកំណត់ និងបំពេញតំរូវការ និងសេចក្តីប៉ងប្រាថ្នារបស់មនុស្សដែលមិនបានឆ្លើយតបជាជាងព្យាយាមបង្ក្រាប ឬលុបបំបាត់តំរូវការ និងសេចក្តីប៉ងប្រាថ្នាទាំងនេះ ។ និយាយម្យ៉ាងទៀតថា ការបង្ការទំនាស់គួរព្យាយាមទប់ស្កាត់ទំនាស់ដោយលុបបំបាត់បុព្វហេតុដំបូង ជាជាងគ្រាន់តែដោះស្រាយរោគសញ្ញានៃទំនាស់ ។

ជាពិសេសនៅក្នុងសង្គមដែលមានការអភិវឌ្ឍន៍យ៉ាងឆាប់រហ័ស ការពិនិត្យមើលជាបន្តបន្ទាប់លើរចនាសម្ព័ន្ធ និងប្រព័ន្ធសង្គមនយោបាយមិនមែន ដោយសារទុក្ខកង្វល់ និងភ័យអាសន្នឡើយ ប៉ុន្តែជាផ្នែកមួយយ៉ាងសំខាន់ និងចាំបាច់នៅក្នុងដំណើរការអភិវឌ្ឍន៍ ការរីកចំរើន និងការកែប្រែ ។ ការកែប្រែសង្គមនយោបាយបែបនេះ អាចកាត់បន្ថយទុក្ខកង្វល់ដែលបង្កឱ្យមានទំនាស់ កសាងឡើងវិញយ៉ាងត្រឹមត្រូវនូវទំនាក់ទំនងដែលមិនមានលក្ខណៈពេញលេញឬដែលបានដួលរលំ ហើយស្របពេលជាមួយគ្នានេះជំរុញអន្តរកាល ឆ្ពោះទៅរកសន្តិភាព និងការអភិវឌ្ឍន៍បន្ថែមទៀត ។ ទំនាស់អាចជាកាតាលីករសំរាប់ការកែប្រែជាវិជ្ជមាន ។

ការពិតនៃមេរៀននេះ មានភស្តុតាងជាច្រើនហើយនៅកម្ពុជា ដែលក្នុងប្រទេសនេះ ការកែប្រែជាបន្តបន្ទាប់លើយន្តការ និងដំណើរការបោះឆ្នោតក្នុងរយៈពេល ១២ឆ្នាំកន្លងមក បានបង្កើនគុណភាពនៃការបោះឆ្នោតនីមួយៗ បានកាត់បន្ថយទោមនស្ស (និងអំពើហិង្សា) និងបានលើកកំពស់វប្បធម៌ថ្មីនៃលទ្ធិប្រជាធិបតេយ្យ និងការអភិវឌ្ឍន៍ដោយមានការចូលរួម ។ COPCEL II នឹងអាចកសាងបន្ថែមទៀតដោយផ្អែកលើមូលដ្ឋានគ្រឹះនេះ ហើយផ្តល់ជាវេទិកាយ៉ាងសំខាន់បែបនេះជាបន្តទៀតក្នុងការជជែក និងការពិភាក្សាជាលក្ខណៈស្ថាបនា ។

**COPCEL/ខប់សែល**

វេទិកាសំរាប់ការបង្ការជំលោះនៅក្នុងការបោះឆ្នោតនៅកម្ពុជា ដែលត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩៩ បានដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្កើតឱ្យមានទីកន្លែងមិនលំអៀងសំរាប់ឱ្យអង្គការសង្គមស៊ីវិល និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតពិភាក្សាការងារទាក់ទងការបោះឆ្នោត និងបង្ការជំលោះ ។ ការជួបជុំទាំងនេះបានបង្កើតសារៈប្រយោជន៍ជាបន្តបន្ទាប់ ហើយបានបន្តរហូតដល់ក្រោយពេលបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រនៅឆ្នាំ២០០៣ ។ ការធ្វើឱ្យអ្នកពាក់ព័ន្ធផ្សេងៗបានជួបជុំគ្នា គឺជាជំហានយ៉ាងសំខាន់ និងមានលក្ខណៈជាវិជ្ជមាន ។

ជាទូទៅ COPCEL គឺជាវេទិកាអព្យាក្រឹត្យដែលមិនអាចខ្វះបានសំរាប់ការពិភាក្សាជាចំហរវាងគណៈកម្មធិការជាតិរៀបចំការបោះឆ្នោត តំណាងរដ្ឋាភិបាល និងអ្នកមកពីសង្គមស៊ីវិលទាក់ទងនឹងសំណើនីតិវិធី និងការកែប្រែ និងព្រឹត្តិការណ៍បោះឆ្នោតផ្សេងទៀត ។

ការអភិវឌ្ឍន៍ដែលគួរឱ្យកត់សំគាល់មួយគឺថា នៅមុនការបោះឆ្នោតឆ្នាំ២០០៣ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានចាប់ផ្តើមបង្ហាញសេចក្តីព្រាងបទបញ្ជារបស់ខ្លួនដល់ COPCEL ដើម្បីឱ្យមានការឆ្លើយតប ។ ជំហាននេះ បានលើកទឹកចិត្តឱ្យមានវប្បធម៌នៃការពិភាក្សាជាចំហនៅក្នុងចំណោមអ្នកចូលរួមនៅក្នុងការបោះឆ្នោតសំខាន់ៗ បានបង្កើតឱ្យមានការយល់ដឹង និងការព្រមព្រៀងជារួមថែមទៀតអំពីតំរូវការ និងទិសដៅនៃការបោះឆ្នោត និងលើកកំពស់គុណភាពបច្ចេកទេសនៃដំណើរការបោះឆ្នោត ។ ផលប៉ះពាល់ជាបន្តបន្ទាប់ គឺការបង្ការជំលោះ និងការដោះស្រាយជំលោះ ។

ការប្រជុំទាំងនេះ ផ្តោតទៅលើអត្ថប្រយោជន៍រួមនៃការចូលរួមពេញលេញ តម្លាភាព និងកិច្ចសហការ ។ ការប្រជុំទាំងនេះ ក៏នឹងផ្តល់ផងដែរនូវការបង្ហាញយ៉ាងច្បាស់ថា ការបោះឆ្នោត និងលទ្ធិប្រជាធិបតេយ្យ មិនមែនជាការទទួលខុសត្រូវតែមួយគត់ ឬការទទួលខុសត្រូវដោយឡែករបស់ស្ថាប័នមួយ ដូចជា គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតឡើយ ។ ទោះជាគណៈកម្មាធិការនេះ អាចមានសមត្ថភាពនិងប្រសិទ្ធិភាពកិច្ចបែបណាក៏ដោយ ។ អង្គការសង្គមស៊ីវិល អង្គការមិនមែនរដ្ឋាភិបាល គណបក្ស អ្នកផ្តល់ជំនួយ រដ្ឋ និងបុគ្គល ទាំងអស់មានតួនាទី និងភារកិច្ចធានាឱ្យការបោះឆ្នោតទទួលបានជោគជ័យ និងថែរក្សាវប្បធម៌ប្រជាធិបតេយ្យ ។ មានទិសដៅជារួម និងតំលៃ ជាស្នូលមួយចំនួនដែលអាច និងត្រូវតែចែករំលែក និងគាំទ្រដោយប្រជាជនកម្ពុជាទាំងអស់ដោយមិនគិតពីការប្រកាន់គណបក្សនយោបាយ ។

ខ្ញុំសង្ឃឹមថា COPCEL II នឹងដើរតួនាទីដ៏មានតំលៃសំរាប់ពិភាក្សាជាចំហ រួមចំណែកចំពោះជោគជ័យនៃការបោះឆ្នោតចំនួនបីនៅពេលខាងមុខនេះ គឺជាការបោះឆ្នោតជ្រើសរើសសមាជិកព្រឹទ្ធសភា ដែលបានគ្រោងឡើងនៅឆ្នាំ២០០៦ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ឆ្នាំ២០០៧ និងការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រនៅឆ្នាំ២០០៨ ។

មុននឹងបញ្ចប់ ខ្ញុំសូមថ្លែងអំណរសារទរ និងការគាំទ្រនៅក្នុងការចាប់ផ្តើមជាផ្លូវការនៃ COPCEL ដំនាក់កាល II នៅថ្ងៃនេះ ។ ការប្រឹងប្រែង របស់ឯកឧត្តម លោកជំទាវ លោកស្រី អស់លោក ក៏នឹងទទួលបានការគាំទ្រយ៉ាងពេញលេញពីសំណាក់រាជរដ្ឋាភិបាលផងដែរ ។

## កំណត់សំគាល់

១. ប្រហែល ៦.៣៤០ លាននាក់ ។
២. អ្នកដែលបានចុះឈ្មោះបោះឆ្នោតជាស្ត្រី មានចំនួន ៥៤% ។
៣. ប្រហែល ៥,២៧៧ លាននាក់ ។
៤. ក្នុងការពិនិត្យវាយតំលៃលើការបោះឆ្នោតទាំងនេះ ជាការសមស្រប ដែលត្រូវធ្វើការបែងចែករវាងបញ្ហាដែលមានក្នុងដំណើរការបោះឆ្នោត និងបញ្ហាដែលមានបន្ទាប់ពីការបោះឆ្នោតបានបញ្ចប់យ៉ាងត្រឹមត្រូវ ។
៥. នៅឆ្នាំ២០០៣ គណបក្សនីមួយៗ មានរយៈពេល ៥នាទីជារៀងរាល់ថ្ងៃ ដើម្បីផ្សព្វផ្សាយតាមវិទ្យុ និងទូរទស្សន៍ក្នុងអំឡុងពេលនៃការប្រើប្រាស់ដោយស្មើភាពគ្នាពេលឃោសនារកសំឡេងឆ្នោត (៣០ថ្ងៃ) ។ កម្មវិធីនេះ ត្រូវបានចាក់ផ្សាយឡើងវិញនៅក្នុងពេលព្រឹក ក្នុងរយៈពេលផ្សាយទាំងអស់ ២៤ម៉ោង/មួយថ្ងៃ ។ ជារួម រដ្ឋបានផ្តល់ម៉ោងផ្សាយដោយឥតគិតថ្លៃរយៈ ១២០ម៉ោងក្នុងកំឡុងពេលនៃការឃោសនារកសំលេងឆ្នោត ។
៦. ការស្មានចំនាយឆ្នាំ២០០៤ ចំនួន ៣.៦៧២.០០០.០០០រៀល ឬ ៩១៩.០០០ដុល្លារ ។
៧. អង្គការគ្រប់គ្រងការបោះឆ្នោតជាស្ថាប័នអភិបាលកិច្ច ។ ការិយាល័យសំរាប់គោលនយោបាយអភិវឌ្ឍន៍នៃកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិខែកញ្ញា ឆ្នាំ២០០០ ។
៨. នៅសហរដ្ឋអាមេរិក ប្រទេសនៅអឺរ៉ុបខាងលិចភាគច្រើន ឈីលី ចំណាយ ១,២ដុល្លារ កូស្តារីកា ចំណាយ ១,៨ដុល្លារ ប្រេស៊ីល ចំនាយ ២,៣ដុល្លារនៅអាហ្វ្រិក ប្រទេសបេនីន ចំណាយ ១,៦ដុល្លារ ប៊ុតស្វាណា ចំណាយ ២,៧ដុល្លារ ហ្គាណា ចំណាយ ០,៧ដុល្លារ និងសេណេហ្គាល់ ចំណាយ ១,២ដុល្លារ នៅអាស៊ីប្រទេសឥណ្ឌា ចំណាយ ១ដុល្លារអាមេ-រិក ហើយប៉ាគីស្ថាន ចំណាយ ០,៥ដុល្លារ និងអូស្ត្រាលី ចំណាយ ៣,២ដុល្លារ ។
៩. នៅអាមេរិកឡាទីន ម៉ិចស៊ិកូ ចំណាយ ៥,៩ដុល្លារអាមេរិក អែល សាល់វ៉ាឌ័រ ចំណាយ ៤,១០ដុល្លាអាមេរិក ប៉ារ៉ាហ្គាយ ចំណាយ ៣,៧០ដុល្លារនៅអាហ្វ្រិក អាហ្វ្រិកខាងត្បូង ចំណាយ ១១ដុល្លារអាមេរិក លេសូតូ ចំណាយ ៦,៩០ដុល្លារអាមេរិក លីបេរី ចំណាយ ៦,១ដុល្លារ អាមេរិក និងយូហ្គង់ដា ចំណាយ ៣,៧ដុល្លារអាមេរិក ហើយនៅអឺរ៉ុបខាងកើត រូស៊ី ចំណាយ ៧,៥ដុល្លារអាមេរិក ។ អែលសាល់វ៉ាឌ័រ ការចំណាយ បានធ្លាក់ចុះមកនៅ ៣,១ដុល្លារអាមេរិកនៅឆ្នាំ១៩៩៧ ។
១០. នៅនីការ៉ាហ្គានៅឆ្នាំ១៩៩០ ការចំនាយមាន ១១ដុល្លារ នៅអង់ហ្គូឡា នៅឆ្នាំ១៩៩២ មាន ២២ដុល្លារ នៅម៉ូហ្សាំប៊ិកនៅឆ្នាំ១៩៩៤ មាន ១០,២ដុល្លារ នៅប៉ាលេស្ទីននៅឆ្នាំ១៩៩៦ មាន ៩,០ដុល្លារអាមេរិក ។
១១. ការសន្សំនេះ រួមមានការទិញ និងការចំណាយតែម្តង ដែលមិនមានទៀតទេនៅឆ្នាំ២០០២ និង ២០០៣ ។ ឧទាហរណ៍ នៅឆ្នាំ១៩៩៨ សហគមន៍អឺរ៉ុបតែឯងបានរួមចំណែក ៧លានដុល្លារអាមេរិកសំរាប់ការបណ្តុះបណ្តាល និងសំភារៈការិយាល័យ ។ នៅឆ្នាំ២០០៣ តួលេខនេះមានចំនួន ៦៦១.០០០ដុល្លារអាមេរិក ។ មានការសន្សំជាច្រើន តាមរយៈប្រតិបត្តិការដែលកាន់តែមានប្រសិទ្ធិភាព ។ ឧទាហរណ៍ គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត ត្រូវបានតែងតាំងឡើងនៅក្នុងរយៈពេល ៥សប្តាហ៍មុនថ្ងៃបោះឆ្នោតនៅឆ្នាំ២០០៣ រីឯនៅឆ្នាំ២០០២ ត្រូវបានតែងតាំងឡើងរយៈពេល ៧ខែ ដើម្បីពិនិត្យមើលការចុះឈ្មោះ ។ ប្រការនេះ បាន សន្សំប្រាក់ចំនួន ២,៥លានដុល្លាអាមេរិក ។
១២. របាយការណ៍របស់ UNDP ស្តីពីការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រនៅកម្ពុជា ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ ២០០៥ ទំព័រ ៥ ។
១៣. រួមមាន រូបមន្តនៅក្នុងការបោះឆ្នោត ការចុះឈ្មោះអ្នកបោះឆ្នោត ការបោះឆ្នោតជាសំងាត់ ការរាប់សន្លឹកឆ្នោត ការ ឃោសនារកសំលេងឆ្នោត លទ្ធភាពប្រើប្រាស់បណ្តាញផ្សព្វផ្សាយ និងសុវត្ថិភាព ព្រមទាំងសន្តិសុខ ។

# ពត៌មានថ្មីៗ ពី វបសអ

## ផ្នែកគ្រប់គ្រង

ក្រុមប្រឹក្សាភិបាល វបសអ បានធ្វើការប្រជុំពាក់កណ្ដាលឆ្នាំ នៅថ្ងៃទី១៦ កក្កដា និងបានស្វាគមន៍ចំពោះដំណឹងថា មានសមាជិកបរទេសពីររូបទៀតនឹងចូលបំរើការ ក្រោយបានការអនុមតិជាផ្លូវការពីការប្រជុំពេញអង្គនៃក្រុមប្រឹក្សាភិបាលនៅខែធ្នូ ២០០៥ ។ អ្នកទាំងពីររូបគឺមានលោក Noritada Morita ជាអតីតមន្ត្រីជាន់ខ្ពស់របស់ធនាគារអភិវឌ្ឍន៍អាស៊ី ហើយគាត់ធ្លាប់មានទំនាក់ទំនងជិតស្និទ្ធ និងយូរឆ្នាំជាមួយកម្ពុជា និងសព្វថ្ងៃធ្វើការនៅក្រុងបាងកក និងលោកសាស្ត្រាចារ្យ Lawrence Haddad ជានាយកនៃវិទ្យាស្ថានសិក្សាពីការអភិវឌ្ឍន៍នៅសាកលវិទ្យាល័យ Sussex ប្រទេសអង់គ្លេស ។ ពួកគេនឹងនាំមកជាមួយនូវជំនាញយ៉ាងខ្ពស់ខាងអភិវឌ្ឍន៍ ហើយនិងចំណេះដឹងពីកម្ពុជា និងពីបញ្ហាប្រឈមផ្សេងៗខាងអភិវឌ្ឍន៍ ។

ការប្រជុំក្រុមប្រឹក្សាភិបាលក៏បានអនុម័តឯកសារទិសដៅមួយ សំរាប់ណែនាំការរៀបចំផែនការយុទ្ធសាស្ត្រឆ្នាំ២០០៦-១០ របស់ វបសអ ដែលនឹងត្រូវដាក់បង្ហាញជូនដល់ការប្រជុំក្រុមប្រឹក្សាភិបាលនៅខែធ្នូ ២០០៥ ។ ក្រុមប្រឹក្សាភិបាលបានឯកភាពថា ផែនការ ៥ឆ្នាំ គួរមានគោលដៅយុទ្ធសាស្ត្រធំៗបីៈ ការអភិវឌ្ឍន៍សមត្ថភាពបុគ្គលិក និងស្ថាប័ន, ការបង្កើនភាពស៊ីជំរៅក្នុងលទ្ធផលស្រាវជ្រាវ និងគោលនយោបាយ ព្រមទាំងការបង្កើនការងារផ្សព្វផ្សាយ និងផលប៉ះពាល់, និងការផ្លាស់ប្តូរទំរង់ វបសអ ទាំងក្នុងរចនាសម្ព័ន្ធ និងប្រតិបត្តិការ ដើម្បីក្លាយជាមជ្ឈមណ្ឌលនៃចំណេះដឹងគ្រប់ផ្នែកខាងអភិវឌ្ឍន៍ ការរួមសហការជាដៃគូជាមួយស្ថាប័នផ្សេងៗ ។

នៅខែកក្កដា ២០០៥ នាយកប្រតិបត្តិ វបសអ ត្រូវបានអញ្ជើញឱ្យទៅធ្វើបទបង្ហាញក្នុងសន្និសីទកំពូលលើកទី៣ ស្តីពីសេដ្ឋកិច្ចអាស៊ីនៅក្រុងកូលាលុមពួរ ដែលរៀបចំដោយវិទ្យាស្ថាននៃការដឹកនាំជាយុទ្ធសាស្ត្រនៅអាស៊ីរបស់ប្រទេសម៉ាឡេស៊ីនៅលើប្រធានបទ *ការកសាងអាស៊ីជាថ្មីៈ បញ្ហាប្រឈម និងការរំពឹងទុកសំរាប់ថ្ងៃអនាគត-ការប្រមើលមើលពីប្រទេសកម្ពុជា* ។ នៅខែកញ្ញា លោកនាយកបានចូលរួមក្នុងទិវាបើក *វេទិកាវិទ្យាស្ថានស្រាវជ្រាវអាស៊ីខាងកើត* រៀបចំដោយវិទ្យាស្ថាននយោបាយសេដ្ឋកិច្ចកូរ៉េ នៅក្រុងសេអ៊ូលស្តីពី *សមាហរណកម្មសេដ្ឋកិច្ចអាស៊ីខាងកើតៈ ស្ថានភាពពិត និងចក្ខុវិស័យ* ។

នៅពាក់កណ្ដាលឆ្នាំ២០០៥ រាជរដ្ឋាភិបាលកម្ពុជា (RGC) បានអញ្ជើញ វបសអ ឱ្យចូលជាសមាជិកនៃក្រុមការងារបច្ចេកទេសរបស់ RGC ខាងកាត់បន្ថយភាពក្រីក្រ និងផែនការ ដែលនឹងជួយពិនិត្យតាមដានការរៀបចំ *ផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ (NSDP) ឆ្នាំ២០០៦-១០* ។ ការសិក្សាចំបងៗពីររបស់ វបសអ ស្តីពីភាពក្រីក្រ (ការចេញឱ្យផុតពីភាពក្រីក្រ ធ្វើជាមួយធនាគារពិភពលោក និងការវាយតំលៃពីភាពក្រីក្រដោយមានការចូលរួមនៅទន្លេសាប ធ្វើជាមួយធនាគារអភិវឌ្ឍន៍អាស៊ី) នឹងយកទៅបញ្ចូលក្នុងការវាយតំលៃពីភាពក្រីក្រថ្មីមួយនៅកម្ពុជា ហើយលទ្ធផលនៃការវាយតំលៃថ្មីនេះ នឹងយកទៅប្រើក្នុង NSDP ក្នុងចំណុចកាត់បន្ថយភាពក្រីក្រ ។

នៅខែសីហា ២០០៥ វបសអ បានបញ្ចប់របាយការណ៍ប្រចាំឆ្នាំសំរាប់ឆ្នាំ២០០៤-៥ ហើយតទៅមុខ របាយការណ៍នឹងគ្របដណ្តប់លើរយៈពេលពីខែមេសា ទៅដល់ខែមេសាឆ្នាំបន្ទាប់ ។ របាយការណ៍ប្រចាំឆ្នាំថ្មី មានធ្វើជាភាសាខ្មែរ និងអង់គ្លេស និងមានចុះក្នុង វេបសាយរបស់ វបសអ ។

## ផ្នែកស្រាវជ្រាវ

ផ្នែកស្រាវជ្រាវនៅ វបសអ បានបន្តរីកធំធាត់ ធ្វើចំរុះកម្ម និងកាន់តែស៊ីជំរៅ ។ ក្រុមវិមជ្ឈការ និងអភិបាលកិច្ច បានបង្ហើយពង្រាងឯកសារគោលដែលផ្តោតលើគណនេយ្យភាពនៅកំរិតខេត្ត សំរាប់ការដាក់អនុវត្តន៍នៅឆ្នាំក្រោយ ។ ការសិក្សាមួយទៀតស្តីពីការឆ្លើយតបនៅកំរិតឃុំ បានចាប់ផ្តើមឡើង ហើយការចុះអង្កេត ដល់កន្លែងក៏បានចាប់ធ្វើដែរ ។

*តទៅទំព័រទី ១៦*

ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា ក៏មានផ្សាយជាភាសាអង់គ្លេសដែរ ។

***Cambodia Development Review*** **is also available in English.**

ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

**ទស្សនាវដ្ដី អភិវឌ្ឍន៍កម្ពុជា**

ឆ្នាំទី៩ លេខ៣ ខែកក្កដា-កញ្ញា ឆ្នាំ២០០៥

**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**
ផ្ទះលេខ៥៦ ផ្លូវ៣១៥ ទួលគោក ភ្នំពេញ កម្ពុជា
អាសយដ្ឋានប្រៃសណីយៈ ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា
ទូរស័ព្ទៈ (៨៥៥-២៣) ៨៨១-៧០១, ៨៨១-៩១៦, ៨៨៣-៦០៣ ទូរសារៈ (៨៥៥-២៣) ៨៨០-៧៣៤
e-mail: cdri@camnet.com.kh / pubs@cdri.forum.org.kh
website: http://www.cdri.org.kh

*ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា*
បោះពុម្ពផ្សាយដោយ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា នៅភ្នំពេញចំនួន ៤ដង/មួយឆ្នាំជាភាសាខ្មែរ និងអង់គ្លេសនៅក្នុងពេលដំណាលគ្នា ។

***ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា*** ផ្តល់ជាវេទិកាមួយ ដើម្បីពិភាក្សាពីបញ្ហានៃការអភិវឌ្ឍន៍ដែលកំពុងតែជះឥទ្ធិពលដល់ប្រទេសកម្ពុជា ។ ***អត្ថបទតាមដានសេដ្ឋកិច្ច*** ផ្តល់ជូននូវមូលវិចារឯករាជ្យស្តីពីដំណើរប្រព្រឹត្តទៅនៃសេដ្ឋកិច្ចប្រទេសកម្ពុជា ។

***ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា*** ស្វាគមន៍អត្ថបទទាំងឡាយពីប្រិយមិត្តអ្នកអាន ។ លិខិតត្រូវចុះហត្ថលេខា ប្រត្យក្សភាព ទូរស័ព្ទ និងមានអាសយដ្ឋានផង ។ អ្នកនិពន្ធទាំងអស់ត្រូវទាក់ទង វបសអ មុននឹងជូនអត្ថបទរបស់ខ្លួន ទោះជាឯកសារនោះមិនទាន់រៀបរយក៏ដោយ ។ ឯកសារទាំងអស់នឹង ត្រូវកែសម្រួលសំរាប់ការបោះពុម្ព ។ វបសអ សូមរក្សាសិទ្ធិបដិសេធការបោះពុម្ព ដោយមិនចាំបាច់បញ្ជាក់ពីហេតុផល ។

គ្រឹះស្ថានផ្សាយៈ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
គ្រប់គ្រងកែសំរួលៈ អែម សូវ៉ានី
កែសំរួលផលិតកម្មៈ អ៊ុំ ចាន់ថា /អ្នកបកប្រែៈ យូ សិទ្ធីរិទ្ធ
រោងពុម្ពជប៉ុន ភ្នំពេញ រូបភាពទំព័រមុខៈ អាន សុវត្ថា

**រក្សាសិទ្ធិ ២០០៥** វិទ្យាស្ថានបណ្តុះបណ្តាលនិង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
រក្សាសិទ្ធិគ្រប់យ៉ាង-គ្មានផ្នែកណាមួយនៃការបោះពុម្ពផ្សាយនេះត្រូវបានចំលងទុក ឬផ្សព្វផ្សាយតាមទម្រង់ និងតាមមធ្យោបាយផ្សេងៗដូចជាៈ អេឡិចត្រូនិក យន្តកម្មថតចម្លង... ដោយគ្មានការអនុញ្ញាតជាលាយល័ក្ខណ៍អក្សរពី វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជាឡើយ ។

**ISSN 1560-7615**

ទំនួលខុសត្រូវលើគំនិត សត្យានុម័ត និងការបញ្ចេញយោបល់ទាំងឡាយនៅក្នុង *ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា* គឺជាបន្ទុកផ្ទាល់របស់អ្នកនិពន្ធ ។ ការបញ្ចេញយោបល់ និងការបកស្រាយទាំងនោះ មិនមែនជាទស្សនៈរបស់ *វបសអ* ទេ ។